# របាយការណ៍ពិនិត្យតាមដាន ការអនុវត្តអនុសញ្ញា ស៊ីដ សម្រាប់ប្រទេសកម្ពុជា ២០២៤

NGO-CEDAW

# សេចក្តីថ្លែងអំណរគុណ


របាយការណ៍នេះត្រូវបានរៀបចំឡើង ដោយគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO-CEDAW) ដោយសហការជាមួយអង្គការសង្គមស៊ីវិលជាសមាជិក និងដៃគូរបស់ខ្លួន ក៏ដូចជា សម្ព័ន្ធសង្គមស៊ីវិលផ្សេងទៀតនៅកម្ពុជា ដែលមានសណ្ដានចិត្តជួយផ្ដល់ជាធាតុចូល និងការប្រឹក្សាផ្នែកបច្ចេកទេសផ្សេងៗ។

(NGO-CEDAW) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែករបស់ អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV) អង្គការបន្ទាយស្រី (BS) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC) សហភាពការកម្ពុជា (CLC) សម្ព័ន្ធខ្មែរជំរឿននឹងការពារសិទ្ធិមនុស្ស (លីកាដូ) សមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA) អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCDO) អង្គការអប់រំសុខភាព និង បរិស្ថាន (EHE) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC) អង្គការក្ដីករុណា (KDK) អង្គការក្លាហាន (Klahaan) សមាគមអភិវឌ្ឍន៍ជនជាតិដើមភាគតិចមណ្ឌលគីរី (MIPAD) អង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ (PSOD) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់) (RHAC) អង្គការជំនួយជនបទ (RAO) អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) អង្គការលើកកម្ពស់គុណភាពជីវិត (WELL) អង្គការមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC) បណ្ដាញការងារស្ត្រីរួបរួមគ្នា (WNU) និងសមាគមមណ្ឌលព័ត៌មានកម្មករ (WIC)។

របាយការណ៍នេះបានទទួលការគាំទ្រថវិកាសប្បុរសធម៌ពីអង្គការ Bread for the World អង្គការ DanChurchAid កម្ពុជា អង្គការមូលនិធិ ហេនរេច បូល កម្ពុជា (HBS) និង UN Trust Fund រាល់ទស្សនៈដែលបានលើកឡើងនៅក្នុងឯកសារនេះ មិនសុទ្ធតែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការ ដែលគាំទ្រថវិកានោះឡើយ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** ........ 1
**អក្សរកាត់** ........ 3
**ទិដ្ឋភាពទូទៅក្នុងឆ្នាំ២០២៤** ........ 4
**ស្ត្រីក្នុងជួរថ្នាក់ដឹកនាំ** ........ 7
**សេរីភាពជាមូលដ្ឋាន និងលំហពលរដ្ឋ** ........ 9
សមាជិកសហជីព ........ 10
សកម្មជនបរិស្ថាន ........ 11
ការបញ្ចេញមតិអំពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ........ 12
ការគាបសង្កត់ឆ្លងដែន ........ 13
សេរីភាពសារព័ត៌មាន និងស្ត្រីក្នុងវិស័យសារព័ត៌មាន ........ 13
**ការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ** ........ 15
ការបណ្តេញចេញពីតំបន់បេតិកភណ្ឌពិភពលោកអង្គររបស់អង្គការយូណេស្កូ ........ 15
ការបៀតបៀនចំពោះសហគមន៍សំរោងត្បូងជាប់បឹងតាមោក ........ 16
អំពើហិង្សានៅខេត្តព្រះវិហារ ........ 16
ការរំលោភយកដីធ្លីនៅខេត្តក្រចេះ ........ 17
សកម្មជនដីធ្លីខេត្តកោះកុងដែលបានជាប់ទោស ........ 17
គម្រោងទូទាត់កាបូនរេដបូក និងការរំលោភសិទ្ធិជនជាតិដើមភាគតិច ........ 18
**បំណុលមីក្រូហិរញ្ញវត្ថុ** ........ 19
**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** ........ 20
ប្រេវ៉ាឡង់ និងទស្សនៈយល់ឃើញ ........ 21
អំពើហិង្សាផ្លូវភេទ និងការព្រមព្រៀង ........ 23
លទ្ធភាពទទួលបានសេវា និងយុត្តិធម៌ ........ 24
ការជួញដូរមនុស្ស និងកន្លែងឆបោកតាមអនឡាញ ........ 26
**សិទ្ធិការងារ និងសិទ្ធិពលកម្ម** ........ 28
លក្ខខណ្ឌការងារសម្រាប់អ្នកបើកបរដឹកជញ្ជូនអាហារ ........ 28
ការតាមដានលើអនុលោមភាពនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងសេរីភាពក្នុងការបង្កើតសមាគម ........ 30
កង្វះសំណង/ដំណោះស្រាយពីក្រុមហ៊ុន Evergreen Apparel (Cambodia) ........ 31
សិទ្ធិការងារក្នុងវិស័យកំសាន្ត ........ 32
**ការរើសអើងអ្នកប្រកបរបរផ្លូវភេទ** ........ 33
**ការពពោះជំនួស** ........ 34
**ការថែទាំសុខភាព** ........ 36
សិទ្ធិ សុខភាពផ្លូវភេទ និងបន្តពូជ ........ 36
ការថែទាំសុខភាពផ្លូវចិត្ត ........ 38
**ការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ** ........ 39
**ការអប់រំ** ........ 41
ការបោះបង់ការសិក្សា ........ 41
ការប្រែប្រួលអាកាសធាតុ និងការអប់រំក្មេងស្រី ........ 42
**ភាពមិនមានរដ្ឋ** ........ 43
**សេរីភាពខាងជំនឿសាសនា** ........ 45
**ស្ត្រី និងក្មេងស្រីដែលជាប់ឃុំឃាំង** ........ 46
**អនុសាសន៍** ........ 47
**ការវិវឌ្ឍនៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយនៃអនុសញ្ញាស៊ីដ ឆ្នាំ២០១៩ (CoBs)** ........ 49

# អក្សរកាត់

| | |
|---|---|
| BFC | គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា |
| C.CAWDU | សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| CamboJA | សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា |
| CATU | សហព័ន្ធសហជីពកម្ពុជា |
| CCDO | អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ |
| CEDAW | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| CENTRAL | មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) |
| CFSWF | សហហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា |
| CHEC | អង្គការកម្ពុជាដើម្បីសុខភាពនិងការអប់រំសហគមន៍ |
| CLV-DTA | តំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម |
| COMFREL | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា |
| CPP | គណបក្សប្រជាជនកម្ពុជា |
| CRC-Cambodia | អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា |
| CSE | ការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ |
| GBV | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| HPV | មេរោគឆ្លងតាមការរួមភេទ |
| ILO | អង្គការពលកម្មអន្តរជាតិ |
| KSILA | សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ |
| LGBTIQ+ | សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា |
| LICADHO | អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) |
| LRSU | សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុន ណាហ្គាវើលដ៍ |
| LSG | ក្រុមសន្សំប្រាក់នារី |
| MoWA | ក្រសួងកិច្ចការនារី |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| PDAO | អង្គការជំនួយអភិវឌ្ឍន៍ និងសន្តិភាព |
| RHAC | អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (អង្គការ រ៉ាក់) |
| SRHR | សិទ្ធិសុខភាព ផ្លូវភេទ និងបន្តពូជ |
| STI | ជម្ងឺកាមរោគ |
| TIP | ការជួញដូរមនុស្ស |
| UNESCO | អង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ |
| UPWD | អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង |
| WELL | អង្គការលើកកម្ពស់គុណភាពជីវិត |
| WNU | បណ្តាញការងារស្ត្រីរួបរួមគ្នា |
| YRDP | អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន |

# ទិដ្ឋភាពទូទៅក្នុងឆ្នាំ២០២៤

សិទ្ធិស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ត្រូវបានកាត់បន្ថយដោយសារអំពើហិង្សា ការរើសអើង និងផ្នត់គំនិតយេនឌ័រនៅក្នុងឆ្នាំ២០២៤ ជាមួយនឹងវឌ្ឍនភាពគួរកត់ឲ្យសម្គាល់ ដើម្បីធានាថាកម្ពុជាបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនស្របតាម អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (ស៊ី-ដ)។

ទោះបីជាកម្ពុជាសម្រេចបាននូវវឌ្ឍនភាពក្នុងការអនុវត្តអនុសាសន៍មួយចំនួន របស់គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (គណៈកម្មាធិការ ស៊ី-ដ) នៅក្នុងការសង្កេតសន្និដ្ឋានឆ្នាំ ២០១៩ក៏ដោយ ក៏បញ្ហាប្រឈមកើតឡើងជាទូទៅនៅតែមានដដែល។ ដោយសារចលនាសិទ្ធិស្ត្រីប្រឈមមុខនឹងប្រតិកម្មអវិជ្ជមានយ៉ាងខ្លាំង ហើយសមភាពយេនឌ័រកំពុងរងការវាយប្រហារជាសកល ការបង្កើន និងការកំណត់គោលដៅនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់សិទ្ធិស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រីឬប្រុសនៅកម្ពុជា គឺមានសារៈសំខាន់ខ្លាំងជាងពេលណាៗទាំងអស់។

ឆ្នាំនេះមានការកត់សម្គាល់ឃើញថា ស្ត្រីនៅតែមានភាពជាតំណាងតិចតួចនៅក្នុងជួរថ្នាក់ដឹកនាំបន្ទាប់ពីការបោះឆ្នោតព្រឹទ្ធសភារបស់កម្ពុជាកាលពីខែកុម្ភៈ និងការបោះឆ្នោតអសកលនៅក្នុងខែឧសភា។ ការបង្ក្រាបជាច្រើនឆ្នាំលើសេរីភាពជាមូលដ្ឋានបានបន្តកើតឡើង ដោយសមាជិកសហជីពស្ត្រី សកម្មជនសិទ្ធិបរិស្ថាន និងដីធ្លី ប្រជាពលរដ្ឋដែលបានសម្តែងមតិជំទាស់ អ្នកសារព័ត៌មាន និងគូប្រជែងនយោបាយ ប្រឈមមុខនឹងការជាប់ពន្ធនាគារ ការផ្តន្ទាទោស អំពើហិង្សា និងការរើសអើងដោយសារតែបានបញ្ចេញមតិ។ ស្ត្រីក៏បានបន្តទទួលរងផលប៉ះពាល់ដោយមិនស្មើភាព ដោយសារតែការរំលោភយកដីធ្លីជាប្រព័ន្ធ និងការបណ្តេញចេញដោយបង្ខំនៅទូទាំងប្រទេស។

សម្ពាធផ្នែកសេដ្ឋកិច្ចកើនឡើងខ្ពស់ជាងមុន បានធ្លាក់មកលើស្ត្រីដែលជារឿយៗជាអ្នកដែលមានទំនួលខុសត្រូវចម្បងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ធ្វើការងារថែទាំដែលគ្មានប្រាក់កម្រៃ និងការធានាឱ្យមានការបំពេញតាមតម្រូវការរបស់កុមារ និងអ្នកនៅក្នុងបន្ទុកផ្សេងទៀត។ សម្ពាធទាំងនេះមានស្ថានភាពកាន់តែខ្លាំងឡើងដោយសារតែវិស័យមីក្រូហិរញ្ញវត្ថុហុតឈាម នៅកម្ពុជា ដោយរដ្ឋាភិបាល និងវិនិយោគិនអន្តរជាតិនៅមិនទាន់បានផ្តល់ការបន្ធូរបន្ថយ ឬដំណោះស្រាយដល់អ្នកខ្ចីដែលរងផលប៉ះពាល់នៅឡើយនោះទេ។

អំពើហិង្សាទាក់ទាងនឹងយេនឌ័រ (GBV) បានបន្តកើតឡើង ដោយជនរងគ្រោះទទួលបានសេវាចាំបាច់ ឬយុត្តិធម៌នៅមានកម្រិត ដោយការឆ្លើយតបជាទូទៅផ្នែកច្បាប់ និងគោលនយោបាយនៅតែត្រូវការជាបន្ទាន់ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាទាំងនេះ។ ទន្ទឹមនឹងនេះ វិបត្តិនៃការជួញដូរមនុស្សបានបន្តលាតត្រដាងជាបន្តបន្ទាប់ ខណៈទីតាំងឆបោកតាមអនឡាញបានរីករាលដាលដោយនិទណ្ឌភាព។

ការរំលោភសិទ្ធិការងារ និងស្ថានភាពការងារដែលមានការកេងប្រវ័ញ្ច ក៏កើតមានផងដែរនៅក្នុងវិស័យផ្សេងទៀត ដូចជា វិស័យការងារក្រៅប្រព័ន្ធ និងវិស័យសេវាកម្សាន្ត។ អង្គការសង្គមស៊ីវិលមួយ ដែលបានខិតខំស្វះស្វែងធ្វើការលើកកម្ពស់ការគោរពសេរីភាពក្នុងការបង្កើតសមាគម បានប្រឈមការយាយីដោយមានចេតនា និងឥតឈប់ឈរ ខណៈដែលកម្មករដែលស្វះស្វែងរៀបចំបង្កើតជាសហជីព និងបញ្ចេញមតិតវ៉ា បានប្រឈមនឹងការបណ្តេញចេញពីការងារដោយនិយោជក និងបាត់បង់ប្រាក់ចំណូល។

អ្នកប្រកបរបរផ្លូវភេទប្រឈមមុខនឹងការផ្តន្ទាទោស និងការរើសអើងជាបន្តបន្ទាប់ដោយអាជ្ញាធរ អ្នកផ្តល់សេវាថែទាំសុខភាព អង្គភាពប្រឆាំងការជួញដូរមនុស្ស និងនៅក្នុងសង្គមកាន់តែទូលំទូលាយជាងមុន ដោយវានៅតែមានសារៈសំខាន់ក្នុងការទទួលស្គាល់ថាការងារប្រករបរផ្លូវភេទក៏ជាការងារមួយប្រភេទដែរ។

ស្ត្រីដែលដើរតួជាអ្នកពពោះជំនួស ត្រូវបានផ្តន្ទាទោសប្រហាក់ប្រហែលគ្នានេះដែរ ដោយមានករណីដំបូងមួយដែលគេដឹងថាកម្ពុជាបានកាត់ទោសជនបរទេសពីបទពពោះជំនួស ដោយមិនបានគិតគូរអំពីភាពមិនស្មើភាពរវាងអ្នកមានអំណាច និងសម្ពាធដែលមាននូវក្នុងការពពោះជំនួស។

ទោះបីជាមានវឌ្ឍនភាពខ្លះក៏ដោយ ក៏ចាំបាច់ត្រូវមានវិធានការបន្ថែមទៀតដើម្បីធានាថា គ្រប់ស្ត្រី ក្មេងស្ត្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទ ស្រីឬប្រុស ទាំងអស់នៅកម្ពុជាអាចទទួលបានព័ត៌មាន និងសេវាកម្មដែលពាក់ព័ន្ធនឹងសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ព្រមទាំងសុខភាពផ្លូវចិត្តផងដែរ។

នៅឆ្នាំ២០២៤ កម្ពុជាពុំមានវឌ្ឍនភាពក្នុងការទទួលស្គាល់តាមច្បាប់លើសមភាពអាពាហ៍ពិពាហ៍នៅឡើយទេ ដោយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ប្រឈមមុខនឹងអំពើហិង្សា និងការរើសអើងនៅក្នុងជីវិតប្រចាំថ្ងៃ និងនៅក្នុងសង្គមរបស់ពួកគេ។

កិច្ចខិតខំបន្តនៅតែមានភាពចាំបាច់ ដើម្បីដោះស្រាយការកើនឡើងនៃហានិភ័យបោះបង់ការសិក្សារបស់ក្មេងស្រី និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើការអប់រំ។ ការស្រាវជ្រាវបន្ថែមទៀតបានគូសបញ្ជាក់ថា ស្ត្រី និងក្មេងស្រីដែលមិនមានសញ្ជាតិនៅកម្ពុជានៅតែគ្មានលទ្ធភាពទទួលបានឯកសារអត្តសញ្ញាណសំខាន់ៗ និងសេវាមូលដ្ឋាន។

ជាចុងក្រោយ វិបត្តិចង្អៀតខ្លាំងនៅក្នុងពន្ធនាគាររបស់កម្ពុជាក៏នៅតែបន្តកើតមានឡើងក្នុងឆ្នាំ២០២៤ ការប្រើប្រាស់ជម្រើសផ្សេងៗទៀតជំនួសឲ្យការឃុំឃាំង គឺចាំត្រូវធ្វើជាបន្ទាន់ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី ស្ត្រីមានផ្ទៃពោះ ក្មេងស្រីជាអនីតិជន និងកុមារដែលត្រូវបានឃុំខ្លួនជាមួយម្តាយរបស់ពួកគេ។

កម្ពុជាបានអនុម័ត ឬកំពុងបង្កើតគោលនយោបាយជាច្រើន ដែលផ្តោតទៅលើការលើកកម្ពស់សមភាពយេនឌ័រ ដូចជាផែនការយុទ្ធសាស្ត្រនារីរតនៈទី ៦ (ឆ្នាំ២០២៤-២០២៨) និងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៤ ឆ្នាំ២០២៤-២០៣០ (NAPVAWIV)។ ក៏ប៉ុន្តែគោលនយោបាយ និងផែនការសកម្មភាពទាំងនេះ អាចនឹងមិនបានផ្តល់ផលជះជាវិជ្ជមានអ្វីចំពោះជីវិតរស់នៅ

ជាក់ស្តែងរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ដោយសារតែផែនការទាំងនេះជារឿយៗមិនទទួលបានការគាំទ្រការវិនិយោគផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្សគ្រប់គ្រាន់នោះទេ។

គួរកត់សម្គាល់ថា ក្រសួងកិច្ចការនារី នៅតែស្ថិតក្នុងចំណោមក្រសួងមួយដែលទទួលបានមូលនិធិទាបបំផុតក្នុងឆ្នាំ២០២៤ ដោយទទួលបានថវិកាត្រឹមតែ ៥១,០៦៧លានរៀល (ប្រហែល ១២.៧៧លានដុល្លារអាមេរិក) នៃថវិកាជាតិ។[1] ទោះបីជាគណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១៩ ថាកម្ពុជាគួរបែងចែកធនធាន និងមូលនិធិឱ្យបានគ្រប់គ្រាន់សម្រាប់ផែនការគោលនយោបាយ និងសកម្មភាពយ៉ាងណាក៏ដោយ[2] ប៉ុន្តែអនុសាសន៍នេះមិនទាន់បានឆ្លើយតបនៅឡើយទេ ដែលការណ៍នេះអាចនាំឱ្យមានផលវិបាកចំពោះសិទ្ធិស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទ ស្រីឬប្រុស។ ការលុបបំបាត់ផ្នត់គំនិតយេនឌ័រ ដែលជាឫសគល់នៃការរើសអើង និងអំពើហិង្សាទាក់ទងនឹងយេនឌ័រទូទាំងប្រទេស នៅតែជាចំណុចសំខាន់ខ្លាំងជាងពេលណាៗទាំងអស់។

របាយការណ៍នេះគឺជាសេចក្តីសង្ខេបអំពីកង្វល់ និងព្រឹត្តិការណ៍សំខាន់ៗ ដែលបានកើតឡើងក្នុង ឆ្នាំ២០២៤។ **របាយការណ៍នេះមិនបានលើកឡើងគ្រប់ជ្រុងជ្រោយចំពោះគ្រប់បញ្ហាទាំងអស់ដែលស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទ ស្រីឬប្រុស នៅកម្ពុជាទាំងអស់ កំពុងប្រឈមមុខនោះទេ ប៉ុន្តែផ្តោតលើបញ្ហាដែលជាកង្វល់ថ្មី ឬសំខាន់ៗនៅឆ្នាំ២០២៤។**

---

[1] Ministry of Economy and Finance, "Budget in Brief: Fiscal Year 2024", online: <https://mef.gov.kh/documents/budget-in-brief-2024/>.
[2] CEDAW Committee, "Concluding observations on the sixth periodic report of Cambodia", CEDAW/C/KHM/CO/6, November 12, 2019, para. 15(b), online: <https://docs.un.org/en/CEDAW/C/KHM/CO/6>.

# ស្ត្រីក្នុងជួរថ្នាក់ដឹកនាំ

ស្ត្រីនៅតែមានចំនួនតិចតួចស្ទើរគ្រប់វិស័យ ក្នុងជួរថ្នាក់ដឹកនាំនយោបាយក្នុងឆ្នាំ២០២៤ ចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ។ ស្ត្រីដែលសកម្មក្នុងវិស័យនយោបាយ ជាពិសេសស្ត្រីដែលចូលរួមជាមួយគណបក្សប្រឆាំង ត្រូវបានរាយការណ៍ថាទទួលបាននូវការរំលោភបំពានសិទ្ធិ ដែលធ្វើឱ្យប៉ះពាល់ការចូលរួមនយោបាយរបស់ពួកគេ។ ស្ត្រីមួយចំនួនត្រូវបានរាយការណ៍អំពីការបៀតបៀនផ្លូវកាយ ពាក្យសម្តី និងផ្លូវភេទ ហើយការរើសអើងដែលបណ្តាលឱ្យមានការប៉ះពាល់ផ្លូវចិត្ត និងគំរាមកំហែងដល់តួនាទី ដ៏សំខាន់ ដែលស្ត្រីនៅក្នុងឆាកនយោបាយត្រូវចូលរួមក្នុងការអភិវឌ្ឍ[3]ប្រទេសកម្ពុជា។ ចំណុចទាំងនេះបានធ្វើឱ្យកម្ពុជា មិនទាន់អាចសម្រេចបាននូវអនុសាសន៍ របស់គណៈកម្មាធិការ ស៊ី-ដ ឆ្នាំ២០១៩ ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការចូលរួមរបស់ស្ត្រីក្នុងជីវភាព[4] នយោបាយ និងសាធារណៈ។

ការបោះឆ្នោតព្រឹទ្ធសភាក្នុងខែកុម្ភៈ ឆ្នាំ២០២៤ ត្រូវបានញាំញីដោយការរាយការណ៍អំពីការជ្រៀតជ្រែក។ ការបោះឆ្នោតព្រឹទ្ធសភាដោយប្រយោលរបស់កម្ពុជា មានសមាជិកព្រឹទ្ធសភាចំនួន ៥៨រូប ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិករដ្ឋសភា ហើយសមាជិកព្រឹទ្ធសភាចំនួនពីររូបត្រូវបានតែងតាំងដោយព្រះមហាក្សត្រ និងសមាជិកព្រឹទ្ធសភាពីររូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា។ គណបក្សភ្លើងទៀន ដែលជាគណបក្សប្រឆាំងនៅតែត្រូវរារាំងតាមអំពើចិត្តមិនឱ្យចូលរួមក្នុងការបោះឆ្នោតដោយសារពុំមានឯកសាររដ្ឋបាលគ្រប់គ្រាន់។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរាយការណ៍អំពីការបំភិតបំភ័យ ការគំរាមកំហែង ការសូកប៉ាន់ និងការល្បួងលួងលោមដោយខុសច្បាប់ ជាថ្នូរនឹងការឱ្យសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់គណបក្សប្រឆាំង ឈប់គាំទ្របេក្ខជនគណបក្សប្រឆាំង ដែលការណ៍នេះ បង្ហាញក្តីបារម្ភយ៉ាងខ្លាំងដែលថា ការបោះឆ្នោតនេះមិនប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌។[5] អ្នកស្រីឆាយ ចិន្តា មន្ត្រីគណបក្សភ្លើងទៀន ដែលធ្វើការជាប្រធានចលនាស្ត្រីរបស់គណបក្សស្ត្រី ក៏ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារផងដែរ នៅមុនការបោះឆ្នោតនៅខែមករា ឆ្នាំ២០២៤។[6] នៅក្នុងការបោះឆ្នោតនេះ គណបក្សប្រជាជនកម្ពុជា (CPP) ទទួលបាន ៥៥អាសនៈ និងគណបក្សឆន្ទៈខ្មែរចងសម្ព័ន្ធភាពជាមួយគណបក្សប្រឆាំងទទួលបាន ៣អាសនៈ។ មានតែសមាជិកព្រឹទ្ធសភាចំនួន ១១រូប ក្នុងចំណោមសមាជិកព្រឹទ្ធសភាទាំង ៦២រូបរបស់កម្ពុជា (១៧,៧%) ប៉ុណ្ណោះដែលជាស្ត្រី[7] ដែលតួលេខនេះ មានការកើនឡើងបន្តិចបន្តួច ១៦,១% ធៀបទៅនឹងអាណត្តិមុន។[8]

---

3 កែវ សុខា, “ស្ត្រីគួរទម្លាយភាពស្ងៀមស្ងាត់ករណីមានការបៀតបៀនក្នុងពេលប្រឡូកនយោបាយ”, WMC, December 26, 2024, online: <https://wmc.org.kh/women-should-break-their-silence-on-harassment-in-politics/>.
4 CEDAW Committee, above n 2, para. 31(b).
5 Human Rights Watch, “Cambodia: Threats, Bribes Tainted Senate Elections”, April 3, 2024, online: <https://www.hrw.org/news/2024/04/03/cambodia-threats-bribes-tainted-senate-elections>.
6 LICADHO, “Candlelight Official Arrested, Accused of Election Document Forgery”, January 16, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=367>.
7 Senate of the Kingdom of Cambodia, “**នីតិកាលទី៥ (២០២៤-២០២៩)**”, online: <https://senate.gov.kh/senate-leaders/fifth-legislature/>.
8 Senate of the Kingdom of Cambodia, “**នីតិកាលទី៤ (២០១៨-២០២៤)**”, online: <https://senate.gov.kh/senate-leaders/fourth-legislature/>.

គណបក្សប្រជាជនកម្ពុជាក៏បានឈ្នះការបោះឆ្នោតនៅតាមរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌក្នុងខែឧសភា ឆ្នាំ២០២៤។ បន្ទាប់ពីការបោះឆ្នោតទាំងនេះ ស្ត្រីប្រហែល ១៧% ត្រូវបានជាប់ឆ្នោតនៅថ្នាក់រាជធានី និងខេត្ត និង១៩% នៅថ្នាក់[9]ក្រុង ស្រុក និងខណ្ឌ។ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកវិទិត ម៉ុនតាបន (Vitit Muntarbhorn) បានលើកឡើងថា ការបោះឆ្នោតឆ្នាំ២០២៣ និងឆ្នាំ២០២៤នៅកម្ពុជា "នៅមិនទាន់ប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌" ហើយលោកវិទិត ម៉ុនតាបន បានគូសបញ្ជាក់ថា "ការចូលរួមរបស់ស្ត្រីនៅក្នុងប្រព័ន្ធថ្នាក់ដឹកនាំនយោបាយកំពូលមានចំនួនតិចតួចណាស់ ពោលគឺប្រព័ន្ធនេះ ភាគច្រើនគ្រប់គ្រងដោយបុរស"។[10] ចំនួនតំណាងជាស្ត្រីដ៏តិចតួចនេះ កើតចេញពីផ្នត់គំនិតយេនឌ័រ និងបញ្ហាប្រឈមជាបន្តបន្ទាប់ដែលកើតមាននៅក្នុងសង្គម គណបក្សនយោបាយ និងប្រព័ន្ធបោះឆ្នោត។[11]

តំណាងជាប់ឆ្នោតនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក៏បានប្រឈមមុខនឹងបញ្ហានៃការរើសអើង និងឧបសគ្គមួយចំនួនចំពោះការសម្រេចចិត្ត នៅពេលអនុវត្តតួនាទី និងទំនួលខុសត្រូវរបស់ខ្លួន។ នៅឆ្នាំ២០២៤ គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) បានវាយតម្លៃបទពិសោធន៍ និងលក្ខខណ្ឌការងាររបស់សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់របស់ស្ត្រីចំនួន៤០ ដែលជាប់ឆ្នោតក្នុងឃុំចំនួន២០ នៃខេត្តចំនួន៥។[12] ខុមហ្វ្រែលបានរកឃើញថា មេឃុំបានប្រគល់ភារកិច្ចឱ្យទៅសមាជិកក្រុមប្រឹក្សាជាស្ត្រីចំនួន៨០% ស្របតាមមុខតំណែងជាប់ឆ្នោតរបស់ពួកគេ។ សមាជិកក្រុមប្រឹក្សាស្ត្រី៨៣% បានរាយការណ៍ថា ពួកគេបានបញ្ចេញមតិយោបល់នៅក្នុងកិច្ចប្រជុំ។ ក្នុងចំណោមតំណាងឃុំទាំង២០ដែលបានចូលរួម មានឃុំចំនួន៥ បានរាយការណ៍ពី បញ្ហាតម្លាភាពថវិកាគឺនៅមានកម្រិត និងនៅក្នុងឃុំចំនួន៧ មានការពិបាកក្នុងការដកថវិកាដើម្បីអនុវត្តកិច្ចការស្ត្រី និងកុមារ ។

ស្ត្រីជនជាតិភាគតិច ដូចជាជនជាតិ ចាម ខ្មែរក្រោម ជនជាតិភាគតិចវៀតណាម និងស្ត្រីជនជាតិដើមភាគតិចផងដែរ ហាក់ដូចជាមានតំណាងតិចតួចនៅគ្រប់កម្រិតនៃការសម្រេចចិត្ត។ ការស្រាវជ្រាវដោយអង្គការនារីដើម្បីសន្តិភាពក្នុងឆ្នាំ២០២៤ បានរកឃើញថា ស្ត្រីជនជាតិភាគតិច៦០% ដែលបានចូលរួមក្នុងការសិក្សានេះ កម្រ ឬមិនដែលបានចូលរួមក្នុងការរៀបចំគំនិតផ្តួចផ្តើម ការអភិវឌ្ឍសហគមន៍នៅក្នុងសហគមន៍របស់ពួកគេនោះទេ។[13] កត្តាទាំងនេះកើតចេញពីបទដ្ឋានសង្គមទាក់ទងនឹងការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពនយោបាយ ភាពមិនស្មើគ្នានៃការទទួលខុសត្រូវ ចំពោះការងារមើលថែដែលមិនមានប្រាក់កម្រៃ អាជ្ញាធរមូលដ្ឋានបង្អាក់ ឬហាមប្រាមការចូលរួមរបស់ពួកគេ និងឧបសគ្គដែលកើតចេញពីបញ្ហាដែលស្ត្រីខ្វះទំនុកចិត្តលើខ្លួនឯងក្នុងការរាយការណ៍។

[9] Report of the Special Rapporteur on the situation of human rights in Cambodia, Vitit Muntarbhorn, A/HRC/57/82, August 5, 2024, para. 44 and 38, online: <https://cambodia.un.org/sites/default/files/2024-08/SR%20report.pdf>.
[10] Ibid., para. 33.
[11] For more information, see NGO-CEDAW, "2023 Annual CEDAW Monitoring Report for Cambodia".
[12] COMFREL, "Summary results of COMFREL's Political Gender Monitoring: Empowering Female Commune and Sangkat Councillors to Perform Tasks at the Grassroots Level, 2024, 2nd Year of the 5th Mandate".
[13] Women Peace Makers (2024) "Voice and Visibility: A participatory exploration of minority women's human rights in Cambodia", online: <https://wpmcambodia.org/project/voice-and-visibility-a-participatory-exploration-of-minority-womens-human-rights-in-cambodia/>.




# សេរីភាពជាមូលដ្ឋាន និងលំហពលរដ្ឋ

ការកាត់បន្ថយលំហពលរដ្ឋ និងសេរីភាពមូលដ្ឋាននៃការជួបប្រជុំ សេរីភាពក្នុងការបង្កើតសមាគម និងការបញ្ចេញមតិ នៅតែបន្តកើតមានឡើងក្នុងកម្រិតប្រហាក់ប្រហែលគ្នានៅក្នុងឆ្នាំ២០២៤។ សកម្មជនការងារជាស្ត្រី សកម្មជនបរិស្ថានដីធ្លី អ្នកសារព័ត៌មាន និងពលរដ្ឋដែលបញ្ចេញមតិ ត្រូវបានរាយការណ៍ថា បានជាប់ពន្ធនាគារ រងការគំរាមកំហែង ការឃ្លាំមើល និងការបៀតបៀនផ្លូវភេទ។ ចំណុចទាំងនេះក៏បានបង្ហាញអំពីការមិនបានបំពេញតាមអនុសាសន៍គណៈកម្មាធិការ ស៊ី-ដ ឆ្នាំ២០១៩ ដើម្បីធានាឱ្យបានពេញលេញនូវសិទ្ធិសកម្មជនជាស្ត្រី សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងការបង្កើតសមាគមដោយគ្មានការបៀតបៀន ការឃ្លាំមើល ឬការរឹតត្បិតមិនត្រឹមត្រូវ។[14]

នៅក្នុងឆ្នាំ២០២៤នេះ សកម្មជនត្រូវបានចោទប្រកាន់ជាញឹកញាប់ពីបទព្រហ្មទណ្ឌ។ បទចោទប្រកាន់ភាគច្រើនរួមមានដូចជា បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមនៃមាត្រា ៤៩៤ និង៤៩៥ ដែលផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមាពីរឆ្នាំ ឬអំពើរួមគំនិតក្បត់នៃមាត្រា៤៥៣ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអតិបរមា ១០ឆ្នាំ។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ មានស្ត្រីយ៉ាងតិច ១៨រូប ត្រូវបានជាប់ពន្ធនាគារដោយសារការបញ្ចេញមតិ សកម្មនិយម ឬការចូលរួមក្នុងសកម្មភាពនយោបាយ។[15]

---

14 CEDAW Committee, above n 2, para. 19.

15 LICADHO, "Cambodia's Prisoners of Interest", online: <https://www.licadho-cambodia.org/prisoners_of_interest/> [as of December 2024].

## សមាជិកសហជីព

សកម្មភាពកូដកម្មដោយសមាជិកនៃសហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិក កម្មករខ្មែរនៃក្រុមហ៊ុន ណាហ្គាវើលដ៏ (LRSU) បានបន្តនៅក្នុងឆ្នាំ២០២៤ ជាការឆ្លើយតបនឹងកាស៊ីណូណាហ្គាវើលដ៏ ដែលបានបញ្ឈប់បុគ្គលិកជាច្រើននៅឆ្នាំ២០២១ អំឡុងពេលរាតត្បាតជំងឺកូវីដ។ ការបញ្ឈប់នេះសំដៅលើសមាជិករបស់សហជីព។[16] ការបង្ក្រាបលើសមាជិកសហជីពស្ត្រីទាំងនេះក៏បានបន្តកើតឡើងស្រដៀងគ្នានេះដែរ។

ក្នុងខែមីនា កូដករឈ្មោះម៉ម សុវឌ្ឍិន បានរងរបួសដៃ និងជើងពេលដែលសន្តិសុខក្រុមហ៊ុនបានដាក់របាំងដែកមិនឱ្យ សុវឌ្ឍិន ចូលទៅកាន់ទីតាំងកូដកម្ម។[17] ក្នុងខែឧសភា តុលាការកំពូលបានតម្កល់សេចក្តីសម្រេចផ្តន្ទាទោសមនុស្សប្រាំបីរូប ជាអតីត និងបច្ចុប្បន្នជាមេដឹកនាំ និងសមាជិក[18]របស់LRSU។ ដូច្នេះមេដឹកនាំសហជីព កញ្ញាឈឹម ស៊ីថរ បានអនុវត្តទោសក្នុងពន្ធនាគាររយៈពេលពីរឆ្នាំពេញពីបទចោទញុះញង់មុនពេលដែលកញ្ញា ស៊ីថរ ត្រូវបានដោះលែងនៅខែកញ្ញា ឆ្នាំ២០២៤។ បន្ទាប់ពីការដោះលែងភ្លាម កញ្ញាស៊ីថរ បានជួបសមាជិកសហជីពដើម្បីបង្ហាញការប្តេជ្ញាចិត្តក្នុងការបន្តស្វែងរកដំណោះស្រាយចំពោះបញ្ហាវិវាទការងារ។[19]

ក្រុមសង្គមស៊ីវិល និងសហគមន៍បានអំពាវនាវឱ្យមានការដោះលែងកញ្ញាស៊ីថរដោយគ្មានលក្ខខណ្ឌ និងបញ្ចប់ធ្វើទុក្ខបុកម្នេញលើ LRSU បន្ទាប់ពីការចេញសាលដីការបស់តុលាការកំពូល។[20] ក្នុងខែតុលា ឆ្នាំ២០២៤ គណៈកម្មាធិការនៃអង្គការពលកម្មអន្តរជាតិ (ILO) បានចេញរបាយការណ៍មួយឆ្លើយតបទៅនឹងពាក្យបណ្តឹងឆ្នាំ២០២២ ទាក់ទងនឹងការរំលោភបំពានដែលប្រព្រឹត្តចំពោះមេដឹកនាំ និងសកម្មជន LRSU។[21] ក្នុងចំណោមអនុសាសន៍ផ្សេងទៀត គណៈកម្មាធិការបានសម្តែងការសោកស្តាយ ដែលកញ្ញាស៊ីថរ ត្រូវបានបង្ខំឱ្យអនុវត្តទោស ហើយគណៈកម្មាធិការបានអំពាវនាវឱ្យកញ្ញាស៊ីថរ អាចចូលរួមដោយសេរីនៅក្នុងសកម្មភាពសហជីពស្របច្បាប់។ គណៈកម្មាធិការក៏បានអំពាវនាវឱ្យទម្លាក់បទចោទប្រកាន់លើសកម្មជនផ្សេងទៀតរបស់ LRSU ផងដែរ។ ក្នុងខែមិថុនា ឆ្នាំ២០២៤ ក្រុមអង្គការសង្គមស៊ីវិល និងសហជីពចំនួន ១៧ស្ថាប័ន ក៏បានអំពាវនាវឱ្យផ្តល់ការងារវិញជូនប្រធានសហព័ន្ធសហជីពសេរីកម្មករ លោកស្រីរឿន កូលាប នៅក្នុងរោងចក្រកាត់ដេរ។ លោកស្រីកូលាប ត្រូវបានជ្រើសរើសជាប្រធានសហជីពរោងចក្រក្នុងខែមិថុនា ឆ្នាំ២០២៣។[22]

---

16 For further background, see Joint Statement, "Enough is Enough: Stop Persecuting LRSU Unionists", May 6, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=523>.

17 **គីម ចាន់ចារ, "ស្ត្រីកូដករណាហ្គាវើលដ៍ ដែលរងរបួសដៃ អះអាងថា ដំណោះស្រាយវិវាទនៅស្ងាត់ឈឹងនៅឡើយ"**, WMC, March 5, 2024, online: <https://wmc.org.kh/injured-nagaworld-striker-claims-dispute-resolution-remains-silent/>. Senate of the Kingdom of Cambodia, "**នីតិកាលទី៤ (២០១៨-២០២៤)**", online: <https://senate.gov.kh/senate-leaders/fourth-legislature/>.

18 LICADHO, "LRSU Verdicts Upheld, Sithar to Remain in Prison", May 3, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=386>.

19 **គីម ចាន់ចារ, "កញ្ញា ឈឹម ស៊ីថរ លើកពីការប្តេជ្ញាបន្តបេសកកម្ម ក្រោយចេញពីពន្ធនាគារ"**, WMC, September 16, 2024, online: <https://wmc.org.kh/chhim-sithor-expressed-her-commitment-to-continue-the-mission-after-being-released-from-prison/>.

20 Joint Statement, "Enough is Enough: Stop Persecuting LRSU Unionists", May 6, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=523>.

21 ILO, "Report in which the committee requests to be kept informed of development - Report No 408, October 2024", online: <https://normlex.ilo.org/dyn/nrmlx_en/f?p=NORMLEXPUB:50002:0::NO::P50002_COMPLAINT_TEXT_ID:4412910>.

22 Joint Statement, "Respect Union Freedom and Reinstate Elected Union Leader at Shengbo Garment Factory", June 12, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=527>.

ពីរថ្ងៃក្រោយមក លោកស្រីត្រូវបានបណ្តេញចេញពីការងារដោយរោងចក្រ សេងបូ ហ្គាមិន ខេមបូឌា (Shengbo Garment (Cambodia) Co., LTD.)។ រោងចក្រនេះមិនបានបន្តកិច្ចសន្យាការងារមានថិរវេលាកំណត់របស់ខ្លួន ដែលនេះជាវិធីសាស្រ្តទូទៅដែលគេយកមកប្រើប្រាស់ដើម្បីរារាំង និងបំផ្លាញការរៀបចំការបង្កើតសហជីព។ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍នៅឆ្នាំ២០១៩ថា កម្ពុជាគួរអនុវត្តឱ្យបានត្រឹមត្រូវនូវកិច្ចសន្យាការងារមានថិរវេលាកំណត់ ហើយថាស្ត្រីជាប់កិច្ចសន្យាទាំងនេះគួរទទួលបានសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម រួមមានការចូលរួមក្នុងសហជីពដោយមិនមានការភ័យខ្លាចអំពីការបញ្ឈប់ពីការងារ។[23]

## សកម្មជនបរិស្ថាន

ការបៀតបៀនលើសកម្មជនបរិស្ថានជាស្ត្រីបានបន្តកើតមានឡើងពេញមួយឆ្នាំ។ ក្នុងខែមករា ឆ្នាំ២០២៤ យុវជន និងសកម្មជនបរិស្ថានចំនួន ១៣រូប រួមមានទាំងស្ត្រីជាច្រើន ត្រូវបានសាកសួរជាច្រើនម៉ោង បន្ទាប់ពីការកាន់ផ្ទាំងបដា និងថតរូប ដោយអំពាវនាវឱ្យមានការអភិរក្សតំបន់កោះកុងក្រៅ។[24]

ក្នុងខែកក្កដា សកម្មជនបរិស្ថានចំនួន ១០រូប មកពីអង្គការចលនាមាតាធម្មជាតិ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី ៦ឆ្នាំ ទៅ៨ឆ្នាំពីបទរួមគំនិតក្បត់ និង/ឬប្រមាថអង្គព្រះមហាក្សត្រ។[25] សកម្មជន៥រូបនោះរួមមានសកម្មជនការពារបរិស្ថាន ឡុង គន្ធា និង ភួន កែវរស្មី ត្រូវបានចាប់ខ្លួនភ្លាមៗ ហើយបញ្ជូនទៅពន្ធនាគារផ្សេងគ្នានៅក្នុងប្រទេស ដោយធ្វើឱ្យពួកគេកាន់តែលំបាកទាក់ទងជាមួយគ្រួសារ និងមេធាវីរបស់ពួកគេ។[26] នេះជាលើកទីពីរហើយ ដែល គន្ធា អាយុ២៦ឆ្នាំ និងកែវ រស្មី អាយុ២៣ឆ្នាំនៅពេលចាប់ខ្លួន កំពុងអនុវត្តទោសជាប់ពន្ធនាគារដោយសារសកម្មភាពរបស់ពួកគេ។[27]

ក្រុមសង្គមស៊ីវិល និងសហគមន៍៥៣ស្ថាប័ន បានថ្កោលទោសការផ្តន្ទាទោសលើសកម្មជនបរិស្ថាន និងបានអំពាវនាវឱ្យមានការដោះលែងពួកគេដោយគ្មានលក្ខខណ្ឌ។[28] អ្នកជំនាញប្រាំរូបរបស់អង្គការសហប្រជាជាតិក៏បានថ្កោលទោសការកាត់ទោសនេះផងដែរ ហើយបានកត់សម្គាល់ថា “វាហាក់ក្លាយទៅជាផ្នែកមួយនៃការអនុវត្តគោលនយោបាយរបស់រដ្ឋជាបន្តបន្ទាប់ ដើម្បីបង្រួមលំហពលរដ្ឋ និងការបង្ក្រាបសំឡេងជំទាស់នៅកម្ពុជា”។[29]

---

[23] CEDAW Committee, above n 2, para. 37(a).
[24] LICADHO, “Activists Questioned over Koh Kong Island Campaign”, January 7, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=363>.
[25] LICADHO, “Mother Nature Activists Violently Arrested, Sentenced to 6-8 Years”, July 2, 2024, online: <https://www.licadho-cambodia.org/articles/20240702/195/index.html>.
[26] LICADHO, “Mother Nature Activists Imprisoned Far From Each Other and Their Families”, July 3, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=401>.
[27] LICADHO, “Mother Nature Activists Released on Bail”, November 12, 2021, online: <https://www.licadho-cambodia.org/flashnews.php?perm=302>.
[28] Joint Statement, “Conviction of Mother Nature Activists is a National Shame”, July 4, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=529>.
[29] Experts condemn conviction of environmental activists in Cambodia”, July 4, 2024, online: <https://www.ohchr.org/en/press-releases/2024/07/experts-condemn-conviction-environmental-activists-cambodia>.

## ការបញ្ចេញមតិអំពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA)

ចាប់ពីខែកក្កដា ឆ្នាំ២០២៤រលកនៃការចាប់ខ្លួនបានកើតឡើងជាការឆ្លើយតបទៅនឹងការបញ្ចេញមតិសាធារណៈអំពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មតាំងពីយូរមកហើយរវាងប្រទេសទាំងបី។ មនុស្សជាង១០០នាក់ រួមមានស្ត្រីយ៉ាងតិច១២នាក់ ត្រូវបានចាប់ខ្លួនចាប់ពីខែកក្កដា ដល់ខែកញ្ញា។ មនុស្សជាង៦០នាក់ ក្នុងចំណោមពួកគេដំបូងត្រូវបានចោទប្រកាន់ និងដាក់ពន្ធនាគារដោយសារការបញ្ចេញមតិ ឬរៀបចំផែនការប្រមូលផ្តុំបញ្ចេញមតិអំពី CLV-DTA។[30] អង្គការឃ្លាំមើលសិទ្ធិមនុស្ស និងអង្គការលើកលែងទោសអន្តរជាតិ បានចាត់ទុកការចាប់ខ្លួនថាជាការធ្វើឡើងតាមអំពើចិត្ត និងជាសកម្មភាពបំភិតបំភ័យអ្នករិះគន់។[31]

ក្នុងចំណោមអ្នកដែលជាប់ពន្ធនាគារទាំងនោះ មានសមាជិក៥នាក់ មកពីសមាគមសម្ព័ន្ធនិស្សិតបញ្ញាវ័ន្តខ្មែរ (KSILA) និងអង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) យុវជនសកម្ម រៀម ស្រីពេជ្រ រតនា សាក់ កន្និការ និងសឿន ស្រីម៉ៃ ដែលត្រូវបានចោទប្រកាន់ពីបទរួមគំនិតក្បត់។[32] អ្នកផ្សេងទៀតរួមមាន អ្នកគាំទ្រកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដូចជាកញ្ញាភឹង សោភា ដែលត្រូវបានចោទប្រកាន់ពីបទញុះញង់។[33] សកម្មជនគណបក្សប្រជាធិបតេយ្យមូលដ្ឋាន អ្នកស្រីសែម សុផល ក៏ត្រូវបានជាប់ពន្ធនាគារដូចគ្នាដែរពីបទញុះញង់ បន្ទាប់ពីអ្នកស្រីបាននិយាយការពារសិទ្ធិសេរីភាពនៃការបញ្ចេញមតិ។[34] ទោះបីសកម្មជនមួយចំនួនត្រូវបានដោះលែងឱ្យនៅក្រៅឃុំ បន្ទាប់ពីសារភាពកំហុសជាសាធារណៈ និងសុំទោសអតីតនាយករដ្ឋមន្ត្រីហ៊ុន សែន និងនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែត[35] ក៏ដោយ ក៏សកម្មជនមួយចំនួនទៀតដូចជា រតនា សោភា និងសុផល នៅតែជាប់ពន្ធនាគាររហូតដល់ចុងឆ្នាំនេះ។ កម្ពុជាបានដកខ្លួនចេញពី CLV-DTA បន្ទាប់ពីការរិះគន់ជាសាធារណៈ ប៉ុន្តែក្នុងចំណោមអ្នកដែលបានបញ្ចេញមតិជំទាស់ទាំងនោះនៅតែស្ថិតក្នុងពន្ធនាគារនៅឡើយ។




[30] LICADHO, "More Than 60 Charged, Imprisoned Over CLV-DTA", September 16, 2024, online: <https://www.licadho-cambodia.org/articles/20240916/196/index.html>.
[31] Human Rights Watch: "Cambodia: Arrests Target Critics of Regional Development Zone", August 28, 2024, online: <https://www.hrw.org/news/2024/08/28/cambodia-arrests-target-critics-regional-development-zone>.
[32] LICADHO, "Youth and Student Group Members Denied Bail on Appeal", December 5, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=426>.
[33] ជា សុខនី, "គ្រួសារសកម្មជនទីក្រុងប៉ារីសបន្តធ្វើតាមនីតិវិធីច្បាប់ដោយរំពឹងថាតុលាការផ្តល់យុត្តិធម៌ជូនពួកគេ", WMC, February 4, 2025, online: <https://wmc.org.kh/the-families-of-the-paris-activists-continue-to-follow-legal-procedures-expecting-the-courts-to-give-them-justice/>.
[34] Khuon Narim & Tep Suokeany, "Sixteen Youths Released While Several Others Continue To Be Questioned Over Planned CLV-DTA Rally", CamboJA News, August 20, 2024, online: <https://cambojanews.com/sixteen-youths-released-while-several-others-continue-to-be-questioned-over-planned-clv-dta-rally/>.
[35] Khuon Narim, "Three Youths Released on Bail, Join CPP and Confess Mistake for Involvement in Anti-CLV-DTA", CamboJA News, January 6, 2025, online: <https://cambojanews.com/three-youths-released-on-bail-join-cpp-and-confess-mistake-for-involvement-in-anti-clv-dta/>.




## ការគាបសង្កត់ឆ្លងដែន

ការបង្ក្រាបរបស់កម្ពុជាលើសកម្មភាពជំទាស់ បានបង្ខំឱ្យសកម្មជន ដែលស្ថិតក្រោមការគំរាមកំហែងឱ្យភៀសខ្លួនទៅក្រៅប្រទេស។ ជាការឆ្លើយតបការគាបសង្កត់ឆ្លងដែន សំដៅលើអ្នកជំទាស់ជាស្ត្រីនៅក្រៅប្រទេសក្នុងឆ្នាំ២០២៤។ ក្នុងខែកញ្ញា កម្មករធ្វើការងារតាមផ្ទះ ជនជាតិកម្ពុជា ឈ្មោះនួន ធឿន ត្រូវបាននិរទេសចេញពីប្រទេសម៉ាឡេស៊ី ដើម្បីប្រឈមមុខនឹងបទចោទប្រកាន់នៅកម្ពុជា។[36] ធឿន ត្រូវបានចោទប្រកាន់ពីបទញុះញង់បង្កឱ្យមានភាពវឹករវរដល់សន្តិសុខសង្គម និងញុះញង់ឱ្យមានការរើសអើងក្នុងសំណុំរឿងទីមួយ និងបទញុះញង់បង្កឱ្យមានភាពវឹករវរដល់សន្តិសុខសង្គម និងប្រមាថព្រះមហាក្សត្រក្នុងសំណុំរឿងទីពីរ បន្ទាប់ពីអ្នកនាង ធឿន បានបង្ហោះសាររិះគន់អតីតនាយករដ្ឋមន្ត្រីហ៊ុន សែន នៅលើ Facebook។ អាជ្ញាធរកម្ពុជាបានធ្វើការជាមួយអាជ្ញាធរម៉ាឡេស៊ី ដើម្បីឱ្យអ្នកនាង ធឿន និរទេស និងចាប់ខ្លួន។ អ្នកនាង ធឿន នៅតែស្ថិតក្នុងពន្ធនាគាររហូតដល់ចុងឆ្នាំ ហើយក្រោយមកត្រូវបានផ្តន្ទាទោសនៅខែមេសា ឆ្នាំ២០២៥ ក្នុងសំណុំរឿងផ្លូវច្បាប់ទាំងពីរមកលើនឹងអ្នកនាង ធឿន។[37]

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៤ ស្ត្រី៤រូប ស្ថិតក្នុងចំណោមសកម្មជនប្រឆាំង៦រូប ត្រូវបាននិរទេសចេញពីប្រទេសថៃ។[38] អ្នកទាំង៦រូបនោះ គឺមាន៥រូប មានឋានៈជាជនភៀសខ្លួន និងម្នាក់ស្វែងរកសិទ្ធិជ្រកកោន ត្រូវបានចាប់បញ្ជូនទៅដាក់ពន្ធនាគារពីបទចោទរួមគំនិតក្បត់ពេលត្រឡប់មកដល់កម្ពុជាវិញ។ ក្មេងម្នាក់ដែលត្រូវបាននិរទេសជាមួយពួកគេ ត្រូវបានដោះលែងឱ្យរស់នៅជាមួយសមាជិកគ្រួសារនៅកម្ពុជា។ អ្នកទាំង៦រូបនោះ នៅតែស្ថិតក្នុងពន្ធនាគារបីដាច់ដោយឡែកពីគ្នារហូតដល់ចុងឆ្នាំ២០២៤។ នៅដើមឆ្នាំ២០២៤ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរាយការណ៍អំពីការបង្ក្រាបជាញឹកញាប់ និងការបង្ខំឱ្យជនភៀសខ្លួននៅក្នុងប្រទេសថៃវិលត្រឡប់មកវិញដោយកត់សម្គាល់ថាប្រទេសថៃគ្មានសុវត្ថិភាពឡើយសម្រាប់ជនភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញ។[39]

## សេរីភាពសារព័ត៌មាន និងស្ត្រីក្នុងវិស័យសារព័ត៌មាន

សេរីភាពសារព័ត៌មាននៅកម្ពុជានៅតែមានការរឹតត្បិតខ្លាំងក្នុងឆ្នាំ២០២៤ ដោយមានការរឹតត្បិតសិទ្ធិទទួលបានព័ត៌មានសម្រាប់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រីឬប្រុសនៅកម្ពុជា។ ក្នុងសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ២០២៤ អង្គការអ្នកកាសែតគ្មានព្រំដែនបានដាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជាលេខ១៥១ក្នុងចំណោម ១៨ប្រទេស។

[36] Human Rights Watch, "Malaysia Deports Cambodian Worker for Critical Comments", October 4, 2024, online: <https://www.hrw.org/news/2024/10/04/malaysia-deports-cambodian-worker-critical-comments>.
[37] LICADHO, "Nuon Toeun Convicted Following Deportation from Malaysia", April 28, 2025, online: <https://www.licadho-cambodia.org/flashnews.php?perm=440>.
[38] Human Rights Watch, "Thailand: Cambodian Refugees Forcibly Returned", November 29, 2024, online: <https://www.hrw.org/news/2024/11/29/thailand-cambodian-refugees-forcibly-returned>.
[39] Human Rights Watch (2024) ""We Thought We Were Safe": Repression and Forced Return of Refugees in Thailand", online: <https://www.hrw.org/feature/2024/05/16/we-thought-we-were-safe/repression-and-forced-return-of-refugees-in-thailand>.

របាយការណ៍នោះបានកត់សម្គាល់ថា ប្រព័ន្ធផ្សព្វផ្សាយដែលកំពុងដំណើរការត្រូវតែ "ធ្វើតាមមាគ៌ារដ្ឋាភិបាល" ដូច្នេះសារព័ត៌មានទាំងនេះប្រាកដជា "មិនអាច" រាយការណ៍អំពីប្រធានបទដូចជា អំពើពុករលួយ និងការប្រឆាំងនឹងនយោបាយបានឡើយ។[40]

ជាលទ្ធផល សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មានស្ត្រីនៅតែមានការរឹតត្បិត។ តួនាទីដ៏សំខាន់ដែលស្ត្រី និងអ្នកសារព័ត៌មានផ្សេងទៀតដើរតួក្នុងការរាយការណ៍អំពីវិសមភាពយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅកម្ពុជា ក៏នៅតែមិនសូវមានប្រសិទ្ធភាពផងដែរ។

ក្នុងខែសីហា ឆ្នាំ២០២៤ កម្ពុជាបានប្រកាសឱ្យប្រើប្រាស់យ៉ាងឆាប់រហ័សនូវធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានដោយមិនបានធ្វើការពិគ្រោះយោបល់ប្រកបដោយអត្ថន័យឡើយ។ ការប្រកាសឱ្យប្រើប្រាស់ធម្មនុញ្ញនេះ បានរំលោភបំពានបន្ថែមទៀតទៅលើសេរីភាពសារព័ត៌មាន។[41] អ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានអំពាវនាវឱ្យមានការផ្អាកធម្មនុញ្ញនេះជាបណ្ដោះអាសន្ន រួចធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់ ដោយសារវិសាលភាពនៃការអនុវត្តក្នុងធម្មនុញ្ញនេះមានលក្ខណៈទូលាយពេក ដោយមិនបានបញ្ចូលផលប្រយោជន៍សាធារណៈ និងខ្វះមធ្យោបាយគន្លឹះផ្លូវច្បាប់សម្រាប់កំហុសផ្អែកលើការពិត ជាពិសេសសិទ្ធិក្នុងការកែតម្រូវ និងការឆ្លើយតប។[42]

នៅក្នុងទិដ្ឋភាពគាបសង្កត់នេះ អ្នកសារព័ត៌មានស្ត្រីបានរាយការណ៍ពីការរំលោភបំពាន ដូចជាការរើសអើងយេនឌ័រ អំពើហិង្សា ការបៀតបៀនផ្លូវភេទ និងពាក្យសំដី និងការគំរាមកំហែងពីសំណាក់មន្ត្រីរដ្ឋាភិបាល ប្រភព និងសហការីបុរស។[43] អ្នកសារព័ត៌ស្ត្រីជាច្រើននាក់ក៏បានរាយការណ៍ពីបញ្ហាប្រឈម និងគ្រោះថ្នាក់ផ្សេងទៀតដល់សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA) រួមមានការមិនលើកទឹកចិត្តពីសំណាក់គ្រួសារក្នុងការបន្តការងាររបស់ពួកគេ ការបៀតបៀនតាមអនឡាញ និងឱកាសបណ្ដុះបណ្ដាលតិចតួច។[44] អ្នកសារព័ត៌មានឯករាជ្យជាស្ត្រីមួយចំនួនបានរាយការណ៍ ពីការលំបាកក្នុងការទទួលបានបណ្ណសារព័ត៌មានដែលរឹតត្បិតការងាររបស់ពួកគេ។[45]

បញ្ហាប្រឈមទាំងនេះបានរួមចំណែក និងកើតឡើងដោយសារតែភាពជាតំណាងរបស់ស្ត្រី ក្នុងវិស័យសារព័ត៌មាននៅមានកម្រិតតិចតួច។ គួរកត់សម្គាល់ថា បណ្ណសារព័ត៌មានត្រូវបានចេញជូនស្ត្រីចំនួន ២៦៩នាក់ក្នុងឆ្នាំ២០២៣ ដែលស្មើនឹង ៨% ប៉ុណ្ណោះនៃបណ្ណសារព័ត៌មានសរុបចំនួន ៣២០១បណ្ណ ដែលចេញដោយក្រសួងព័ត៌មានក្នុងឆ្នាំដដែលនោះ។[46]

---

40 Reporters Without Borders, World Press Freedom Index, online: <https://rsf.org/en/country/cambodia>.
41 Seoung Nimol, "New Professional Journalism Charter Speedily Implemented Only Days After Input Deadline", CamboJA News, August 7, 2024, online: <https://cambojanews.com/new-professional-journalism-charter-speedily-implemented-only-days-after-input-deadline/>.
42 "Cambodia: UN experts call for suspension of professional journalism charter", September 12, 2024, online: <https://www.ohchr.org/en/press-releases/2024/09/cambodia-un-experts-call-suspension-professional-journalism-charter>.
43 For example, see: <https://www.facebook.com/share/v/18jCziMbob/?mibextid=wwXIfr>.
44 CamboJA (2025) "Cambodian Journalism Situation Report 2024", online: <https://www.camboja.net/advocacy/reports/annual-report/cambodian-journalism-situation-report-2024/>.
45 For example, see: <https://www.facebook.com/share/v/1AubzsSaPd/>.
46 Ministry of Information (2024) "Report on State of Press Freedom in Cambodia", online: <https://moi-static.sgp1.cdn.digitaloceanspaces.com/0Report-2024/Report%20on%20The%20State%20of%20Press%20Freedom%20in%20Cambodia%20FINAL.pdf>.

# ការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ

ជារឿយៗ ស្ត្រីរងផលប៉ះពាល់ច្រើនដោយមិនមានសមាមាត្រ ក្នុងករណីរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំ។ វិវាទដីធ្លីរ៉ាំរ៉ៃដែលកើតចេញពីដីសម្បទានសេដ្ឋកិច្ច និងការផ្តល់ដីថ្មីដល់អ្នកមានអំណាច បានធ្វើឱ្យមានការរំលោភបំពានសិទ្ធិដីធ្លីនៅក្នុងឆ្នាំ ២០២៤។ បញ្ហាទាំងនេះបានធ្វើឱ្យកម្ពុជាមិនទាន់មានវឌ្ឍនភាពក្នុងការបំពេញតាមអនុសាសន៍ឆ្នាំ២០១៩ របស់គណៈកម្មាធិការ ស៊ី-ដ ដើម្បីបែកចែកឡើងវិញ និងចែកដីដើម្បីឱ្យស្ត្រីមានកម្មសិទ្ធិដីធ្លីស្មើៗគ្នា។[47]

អង្គការលីកាដូបានរាយការណ៍ថា មានគ្រួសារយ៉ាងតិច ៩៨១៣គ្រួសារ ត្រូវបានរងផលប៉ះពាល់ដោយការរំលោភយកដីធ្លី និងការបណ្តេញចេញដោយបង្ខំក្នុងចំណោម ៤១ករណីក្នុងឆ្នាំ២០២៤។ សកម្មជនដីធ្លី និងសហគមន៍ ដែលជារឿយៗមានស្ត្រីជាអ្នកដឹកនាំ ពួកគេក៏បានបន្តប្រឈមមុខនឹងអំពើហិង្សា ការបៀតបៀន និងការផ្តន្ទាទោសព្រហ្មទណ្ឌដោយសារតែការការពារផ្ទះសម្បែង ដីធ្លី និងជីវភាពរបស់ពួកគេពីផលប្រយោជន៍របស់បុគ្គលមានអំណាច។ ករណីនៃការរំលោភសិទ្ធិដីធ្លី និងការបៀតបៀនខាងក្រោមគ្រាន់តែជាឧទាហរណ៍មួយចំនួនដែលបានកើតឡើងទូទាំងប្រទេសនៅក្នុងឆ្នាំ២០២៤ ប៉ុណ្ណោះ។

## ការបណ្តេញចេញពីតំបន់បេតិកភណ្ឌពិភពលោកអង្គររបស់អង្គការយូណេស្កូ

ក្នុងខែធ្នូ ឆ្នាំ២០២៤ អ្នកជំនាញរបស់អង្គការសហប្រជាជាតិបានសម្តែងក្តីកង្វល់អំពីការបណ្តេញចេញដោយបង្ខំជាបន្តបន្ទាប់តាំងពីឆ្នាំ២០២២ លើមនុស្សប្រមាណ៤០០០០នាក់ ពីតំបន់បេតិកភណ្ឌពិភពលោកអង្គរ។[48] អ្នកជំនាញបានកត់សម្គាល់ថា ការបណ្តេញចេញដោយបង្ខំនេះ ដែលរួមមានជនជាតិដើមភាគតិចផងនោះ ត្រូវបានធ្វើឡើងដោយគ្មានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ជាមួយសហគមន៍ដែលរងផលប៉ះពាល់នោះឡើយ ហើយបានបណ្តាលឱ្យមានការផ្លាស់ទីលំនៅរបស់ពួកគេទៅកាន់កន្លែងតាំងលំនៅថ្មីដែលមានស្ថានភាពរស់នៅលំបាក។ អ្នកជំនាញបានអំពាវនាវឱ្យមានការដោះស្រាយ និងផ្តល់សំណងចំពោះ “ករណីរំលោភសិទ្ធិមនុស្សដែលបានរាយការណ៍ជាច្រើនដង និងលើសលុប” សម្រាប់អ្នកដែលត្រូវបានផ្លាស់ទីលំនៅពីតំបន់ការពារដោយអង្គការយូណេស្កូ និងការបាត់បង់ផ្ទះសម្បែង ដីកសិកម្ម និងជីវភាពរស់នៅរបស់ពួកគេ។

អង្គការលើកលែងទោសអន្តរជាតិ ធ្លាប់បានកត់ត្រាពីមុនផងដែរថា ស្ត្រីប្រឈមមុខនឹងអំពើហិង្សា និងការគំរាមកំហែងពីសំណាក់អាជ្ញាធរ ដោយសារពួកគេប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ពីតំបន់បេតិកភណ្ឌពិភពលោកអង្គរ។[49] អង្គការលើកលែងទោសអន្តរជាតិក៏បានរកឃើញថា ភូមិធម្មជាតិរុនតាឯក ងាយនឹងជន់លិច និងខ្វះហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋាន រួមទាំងកង្វះលំនៅឋាន បន្ទប់ទឹក បង្គន់អនាម័យ អគ្គិសនី និងទឹក ដែលបញ្ហាខ្វះខាតនីមួយៗអាចប៉ះពាល់ដោយមិនមានសមមាត្រ ចំពោះស្ត្រី និងក្មេងស្រី គ្រួសារ និងសហគមន៍ បានរាយការណ៍ទៅកាន់អង្គការលើកលែងទោសអន្តរជាតិ ថាពួកគេបានរស់នៅបែក

[47] CEDAW Committee, above n 2, para. 21(a).
[48] "Cambodia: Experts alarmed over forced resettlement due to heritage conservation", December 13, 2024, online: <https://www.ohchr.org/en/press-releases/2024/12/cambodia-experts-alarmed-over-forced-resettlement-due-heritage-conservation>.
[49] Amnesty International (2023) "'Nobody wants to leave their home': mass forced evictions at Cambodia's UNESCO world heritage site of Angkor", online: <https://www.amnesty.org/en/documents/asa23/7374/2023/en/>.

គ្នានៅទីតាំងថ្មី ដោយសារការបែងចែកដីតាមវិធីសាស្ត្រចៃដន្យ។ ហេតុការណ៍នេះ នាំឲ្យការទទួលបានការគាំទ្រពីបណ្ដាញសហគមន៍របស់ស្ត្រី ដែលជារឿយៗដើរតួនាទីយ៉ាងសំខាន់ ក្នុងការការពារប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ និងជួយមើលថែទាំកុមារមានការលំបាកជាងមុន។

## ការបៀតបៀនចំពោះសហគមន៍សំរោងត្បូងជាប់បឹងតាមោក

បឹងតាមោកក្នុងទីក្រុងភ្នំពេញត្រូវបានកាត់ពុះជាដុំ រួចផ្តល់ជូនទៅវិស័យឯកជន ដោយមិនគោរពសហគមន៍ដែលរស់នៅក្បែរ និងអាស្រ័យផលលើបឹងនេះដើម្បីជីវភាពរបស់ពួកគាត់នោះទេ។ ក្នុងខែមករា ឆ្នាំ២០២៤ ក្រុមសង្គមស៊ីវិល និងសហគមន៍ ចំនួន៣៨ស្ថាប័ន បានថ្កោលទោសការបណ្តេញចេញ និងការប្រព្រឹត្តមិនសមរម្យដែលប្រឈមមុខដោយសហគមន៍សំរោងត្បូង ដែលបានរស់នៅក្បែរបឹងតាំងពីឆ្នាំ១៩៩៦។[50] ប្រជាសហគមន៍ទាំងនេះ ប្រឈមនឹងការគំរាមកំហែងអំពើហិង្សា និងការចោទប្រកាន់ព្រហ្មទណ្ឌនៅក្នុងឆ្នាំ២០២៤។

ក្នុងខែកុម្ភៈ សន្តិសុខចំនួន១០នាក់ បានប៉ុនប៉ងប្រើប្រាស់គ្រឿងចក្រអេស្កាវ៉ាទ័រឈូសឆាយដីកាន់កាប់ដោយសហគមន៍។ កុមារម្នាក់ និងស្ត្រី២នាក់ រួមទាំងស្ត្រីមានផ្ទៃពោះម្នាក់ បានរងរបួសនៅពេលឈ្លោះប្រកែកគ្នាជាមួយអាជ្ញាធរ នៅពេលកំពុងតែតវ៉ាប្រឆាំងការឈូសឆាយដី។[51] ក្នុងខែឧសភា អាជ្ញាធរបានរារាំង និងរុញប្រជាសហគមន៍ដែលកំពុងព្យាយាមដើរហែក្បួនឆ្ពោះទៅសាលាខណ្ឌ ដើម្បីជួបមន្ត្រីពាក់ព័ន្ធនឹងការជូនដំណឹងអំពីការបណ្តេញចេញ។[52] ក្នុងខែសីហា ប្រជាសហគមន៍៩នាក់ ត្រូវបានផ្តន្ទាទោសពីបទហិង្សាដោយចេតនា និងការរារាំងមន្ត្រីសាធារណៈមានស្ថានទម្ងន់ទោស។ ពួកគេទទួលបានការព្យួរទោសជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ។ ការផ្តន្ទាទោសនេះបានធ្វើឡើងអំឡុងពេលមានជម្លោះជាមួយអាជ្ញាធរ បន្ទាប់ពីមានការចោទប្រកាន់ថាប្រជាសហគមន៍បានរំលោភបំពានបម្រាមសាងសង់ ដោយបានបិទទ្វារផ្ទះ រារាំងមិនឱ្យអាជ្ញាធរចូល ដើម្បីការពារសុខសុវត្ថិភាព និងទ្រព្យសម្បត្តិរបស់គាត់។[53] ក្នុងខែវិច្ឆិកា ស្ត្រីបីនាក់មកពីសហគមន៍សំរោងត្បូងត្រូវបានផ្តន្ទាទោសស្រដៀងគ្នា ពីបទរារាំងមន្ត្រីសាធារណៈមានស្ថានទម្ងន់ទោស។ ការចោទប្រកាន់នេះ បានកើតឡើងបន្ទាប់ពីអាជ្ញាធរបានបញ្ជាឱ្យស្ត្រីទាំងនោះរើតូបលក់បន្លែមួយចេញពីផ្ទះរបស់ពួកគេ ហើយអាជ្ញាធរបានបំផ្លាញតូបនោះចោលនៅពេលដែលពួកគេមិនធ្វើតាម។ ស្ត្រីទាំងនោះទទួលបានការព្យួរទោស និងព្យួរការផាកពិន័យរយៈពេល ៦ខែ។[54]

## អំពើហិង្សានៅខេត្តព្រះវិហារ

ជម្លោះដីធ្លីដ៏រ៉ាំរ៉ៃរវាងក្រុមហ៊ុន Seladamex Co., Ltd. និងគ្រួសារដែលរស់នៅក្នុងតំបន់នោះបានកើនឡើងក្នុងឆ្នាំ២០២៤។ ក្រុមហ៊ុនបានទទួលសម្បទានដីសេដ្ឋកិច្ចក្នុងឆ្នាំ២០១១ ដែលនាំឱ្យមានជម្លោះជាមួយគ្រួសាររាប់រយ។

---

50 Joint Statement, "Stop Harassment and Intimidation; Provide Legal Land Tenure to Samrong Tbong Community", January 25, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=518>.

51 LICADHO, "Samrong Tbong Community Reports Violence as Government Clears Land", February 27, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=378>.

52 LICADHO, "Samrong Tbong Community Members Harassed After Eviction Notices", May 10, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=389>.

53 LICADHO, "Nine Samrong Tbong Community Members Convicted", August 16, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=411>.

54 LICADHO, "Samrong Tbong Family Convicted of Obstructing Authorities", November 19, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=422>.

ក្នុងខែមីនា កម្លាំងចម្រុះបានយកត្រាក់ទ័របើកចូលទៅតំបន់នោះ ហើយនៅពេលដែលអ្នកភូមិប្រមូលផ្តុំគ្នា អាជ្ញាធរបានដាក់ពង្រាយគ្រាប់ពិត និងគ្រាប់បែកផ្សេងៗ។[55] មនុស្ស២៩នាក់ ត្រូវបានចាប់ខ្លួនពីចោទប្រកាន់ពីបទកាប់រានដីព្រៃ និងហ៊ុមព័ទ្ធដីនេះដើម្បីទាមទារកម្មសិទ្ធិតាមច្បាប់ស្តីពីព្រៃឈើ។ មនុស្ស៤នាក់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។ មនុស្ស២៥នាក់ផ្សេងទៀត គឺស្ត្រី១២នាក់ និងបុរស១៣នាក់ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរហូតដល់ខែបន្ទាប់ ទើបដោះលែងពួកគេឱ្យនៅក្រៅឃុំវិញ។[56] អាជ្ញាធរបានបន្តដុតបំផ្លាញផ្ទះប្រជាសហគមន៍។ ផ្ទះរបស់ស្ត្រីម្នាក់ត្រូវបានគេបំផ្លាញហើយស្ត្រីនោះបានស្លាប់ដោយការធ្វើអត្តឃាតនៅប៉ុន្មានថ្ងៃបន្ទាប់។ ក្រោយមករដ្ឋបាលខេត្តព្រះវិហារ បានចេញសេចក្តីថ្លែងការណ៍ដោយបដិសេធថាការស្លាប់របស់ស្ត្រីរូបនោះមិនជាប់ពាក់ព័ន្ធនឹងសកម្មភាពរបស់អាជ្ញាធរនោះទេ ហើយឆ្លើយថារឿងនេះជាប់ពាក់ព័ន្ធនឹងជម្លោះគ្រួសារ ហើយព្រមផ្តល់ប្រាក់ដល់គ្រួសាររបស់ស្ត្រីនោះ។[57]

## ការរំលោភយកដីធ្លីនៅខេត្តក្រចេះ

ក្នុងខែមិថុនា ឆ្នាំ២០២៤ ក្រុមហ៊ុនក្នុងស្រុក Kasekam Youveakchun Svay Rieng Co. Ltd. បានបំផ្លាញដី ដំណាំ និងផ្ទះរបស់អ្នកភូមិនៅក្នុងសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តក្រចេះ ដែលត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុនសិង្ហបុរីក្នុងឆ្នាំ២០០៩។ ក្នុងខែមិថុនា និងវិច្ឆិកា អាជ្ញាធរបានរារាំងសមាជិកសហគមន៍មិនឱ្យមកកាន់រាជធានីភ្នំពេញដើម្បីធ្វើការតវ៉ា និងបានដាក់ចេញការរឹតត្បិតផ្សេងទៀត ខណៈដែលពួកគេព្យាយាមដាក់ញត្តិដើម្បីអំពាវនាវឱ្យរដ្ឋាភិបាលដោះស្រាយជម្លោះនេះ។[58]

## សកម្មជនដីធ្លីខេត្តកោះកុងដែលបានជាប់ទោស

នៅក្នុងជម្លោះដ៏រ៉ាំរ៉ៃដែលកើតចេញពីសម្បទានដីសេដ្ឋកិច្ច តាំងពីឆ្នាំ២០០៦ ក្រុមហ៊ុនដែលមានទំនាក់ទំនងជាមួយសមាជិកព្រឹទ្ធសភា និងឧកញ៉ាដែលមានខ្នងក្រាស់ បានបង្កើតចម្ការអំពៅនៅលើដីសហគមន៍នៅខេត្តកោះកុង។ សកម្មជនមកពីសហគមន៍ដែលរងផលប៉ះពាល់ប្រឈមមុខនឹងការចាប់ខ្លួន និងការផ្តន្ទាទោសក្នុងសំណុំរឿងផ្លូវច្បាប់ ៤ករណី ក្នុងឆ្នាំ២០២៣[59] ដោយការឃាយឃីតាមប្រព័ន្ធតុលាការនៅតែបន្តរហូតដល់ឆ្នាំ២០២៤។ ក្នុងខែមិថុនា សកម្មជនខេត្តកោះកុង១២នាក់ ត្រូវបានផ្តន្ទាទោសពីបទញុះញង់បន្ទាប់ពីប៉ុនប៉ងដាក់ញត្តិទៅអាជ្ញាធរ។ សកម្មជនទាំងនោះរួមមានស្ត្រី៨នាក់ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ តែទោសនេះត្រូវបានព្យួរ។[60]

---

55 LICADHO, "Armed Forces Fire Weapons, Arrest Villagers Amid Longstanding Preah Vihear Land Conflict", March 6, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=379>.

56 LICADHO, "25 People Imprisoned in Preah Vihear Land Dispute", March 12, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=383>; CCHR, "Fact Sheet: Forced Evictions in Cambodia", October, 2024, online: <https://www.sithi.org/medias/files/projects/sithi/publication/fact-sheet-on-forced-evictions-eng-final-20241007-083125.pdf>.

57 Som Sotheary, "Woman's suicide not related to land dispute, say authorities", Khmer Times, March 19, 2024, online: <https://www.khmertimeskh.com/501457974/womans-suicide-not-related-to-land-dispute-say-authorities/>.

58 LICADHO, "Kratie Land Community Petitions Government to Stop Land Clearing", June 19, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=395>; LICADHO, "Kratie Community Camps at Land Ministry to Call for Dispute Resolution", November 7, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=421>.

59 For more information, see NGO-CEDAW, "2023 Annual CEDAW Monitoring Report for Cambodia".

60 LICADHO, "Koh Kong Land Activists Convicted Over Petition Attempt", June 27, 2024, online: <https://www.licadho-cambodia.org/flashnews.php?perm=400>.

## គម្រោងទូទាត់កាបូនរេដបូក និងការរំលោភសិទ្ធិជនជាតិដើមភាគតិច

ក្នុងខែកុម្ភៈ ឆ្នាំ២០២៤ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានបោះពុម្ពផ្សាយរបាយការណ៍មួយ ដែលរាយការណ៍ថា គម្រោងទូទាត់កាបូនដ៏ធំបំផុតរបស់កម្ពុជា គឺគម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង ដែលអនុវត្តរួមគ្នាដោយក្រសួងបរិស្ថាន និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃ។ គម្រោងនេះត្រូវបានទទួលស្គាល់ដោយអង្គការ Verra។ គម្រោងនេះក៏បានរំលោភសិទ្ធិជនជាតិដើមភាគតិចផង ដែលបានរស់នៅក្នុងតំបន់នេះអស់ជាច្រើនសតវត្សមកហើយ។[61] គម្រោងនេះបានចេញឥណទានកាបូនច្រើនជាង ២៧.៦លាន គិតត្រឹមខែមិថុនា ឆ្នាំ២០២៣។ ឥណទានកាបូនត្រូវបានទិញដោយក្រុមហ៊ុន និងបុគ្គលឯកជនដើម្បី "ទូទាត់" ការបញ្ចេញឧស្ម័ន។ គម្រោងនេះរកបានប្រាក់ចំណូលជាង ១៨លានដុល្លារ ក្នុងការលក់ឥណទាននៅត្រឹមឆ្នាំ២០២១ ដោយមិនមានតម្លាភាពគ្រប់គ្រាន់ជុំវិញការបង្កើតប្រាក់ចំណូលបន្ថែមទៀត។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា គម្រោងរេដបូក បានរំលោភសិទ្ធិជនជាតិដើមភាគតិចរួមទាំងស្ត្រី ដោយសារកង្វះការពិគ្រោះយោបល់ កង្វះការយល់ព្រមដោយស្ម័គ្រចិត្ត កង្វះការយល់ព្រមជាមុន និងកង្វះការយល់ព្រមបន្ទាប់ពីជ្រាបព័ត៌មានសព្វគ្រប់ ព្រមទាំងកង្វះការព្រមព្រៀងចែករំលែកផលប្រយោជន៍។ គម្រោងនេះក៏បានបណ្តាលឱ្យមានការរំលោភសិទ្ធិ ជនជាតិដើមភាគតិចផង ដែលប្រឈមមុខនឹងផលប៉ះពាល់អវិជ្ជមានមកលើជីវភាពរស់នៅ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ការបណ្តេញចេញដោយបង្ខំ ការចាប់ខ្លួន និងការឃុំឃាំងព្រោះតែការអនុវត្តវិធីសាស្ត្រធ្វើកសិកម្មបែបប្រពៃណី និងការប្រមូលអនុផលព្រៃឈើប្រកបដោយចីរភាព អំពើហិង្សា និងការយាយីផ្សេងៗទៀតដោយសារគម្រោងនេះ។

អង្គការឃ្លាំមើលសិទ្ធិមនុស្សបានគូសបញ្ជាក់ថា នេះគឺជារឿងដែលមិនអាចទទួលយកបានឡើយ និងជាសកម្មភាពដែលផ្ទុយពីការចង់បាន ខណៈដែលមានការរុញច្រាន និងការធ្វើបាបជនជាតិដើមភាគតិចនៅពេលពួកគេខិតខំប្រឹងប្រែងអភិរក្ស។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានអំពាវនាវឱ្យមានដំណោះស្រាយចំពោះការរំលោភបំពាន និងការពិនិត្យមើលគម្រោងឡើងវិញ ដើម្បីធានាឱ្យមានការចូលរួមពិតប្រាកដចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងការព្រមព្រៀងចែករំលែកផលប្រយោជន៍។ ទោះបីគម្រោងនេះត្រូវបានផ្អាករហូតដល់ខែកញ្ញា ឆ្នាំ២០២៤ ក៏ពិតមែន ប៉ុន្តែប្រជាសហគមន៍បានរាយការណ៍ថា ការរំលោភសិទ្ធិជនជាតិដើមភាគតិចនៅតែបន្តកើតមានដដែល។[62]

[61] Human Rights Watch (2024) "Carbon Offsetting's Casualties: Violations of Chong Indigenous People's Rights in Cambodia's Southern Cardamom REDD+ Project", online: <https://www.hrw.org/report/2024/02/29/carbon-offsettings-casualties/violations-chong-indigenous-peoples-rights>.
[62] Flynn, G. "Indigenous community calls out Cambodian REDD+ project as tensions simmer in the Cardamoms", Mongabay, March 10, 2025, online: <https://news.mongabay.com/2025/03/indigenous-community-calls-out-cambodian-redd-project-as-tensions-simmer-in-the-cardamoms/>.

# បំណុលមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុជញ្ជក់ឈាមនៅកម្ពុជា បានបន្តធ្វើឱ្យប៉ះពាល់សិទ្ធិស្ត្រីនៅទូទាំងប្រទេសកម្ពុជាក្នុងឆ្នាំ២០២៤ ដោយមិនមានវិធានការប្រកបដោយអត្ថន័យពីតួអង្គណាមួយដើម្បីដោះស្រាយ ឬរកមធ្យោបាយដោះស្រាយវិបត្តិបំណុលវ័ណ្ឌកនៅកម្ពុជានោះទេ។ គេសង្កេតមិនឃើញមានវឌ្ឍនភាពក្នុងការគ្រប់គ្រងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយប្រសិទ្ធភាព និងការបង្កើតយន្តការត្រួតពិនិត្យ ដើម្បីទប់ស្កាត់ការផ្តល់ប្រាក់កម្ចីដោយកេងប្រវ័ញ្ច ដូចជាការផ្តល់អនុសាសន៍ ពីគណៈកម្មាធិការ ស៊ី-ដ ក្នុង ឆ្នាំ២០១៩[63]ទេ។

នៅមានស្ត្រីប្រហែល ២ភាគ៣ នៃអ្នកខ្ចីមីក្រូឥណទាន ពីរលាននាក់នៅកម្ពុជាក្នុងឆ្នាំ២០២៤ ដែលមានប្រាក់កម្ចីជាង ១៨ពាន់លានដុល្លារអាមេរិក។ ចំនួនប្រាក់កម្ចីជាមធ្យមបានបន្តលើសឆ្ងាយពីប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យម ហើយអ្នកខ្ចីភាគច្រើននៅតែត្រូវដាក់បញ្ចាំបណ្ណកម្មសិទ្ធិដីធ្លីដើម្បីបានប្រាក់កម្ចី។

ស្ថានភាពបានដុនដាបបន្ថែមទៀតសម្រាប់អ្នកខ្ចីក្នុងឆ្នាំ២០២៤ ដោយសារ ៦,២៤% នៃប្រាក់កម្ចីគ្រួសារ និងអតិថិជន ត្រូវបានទូទាត់សងយឺតយ៉ាវលើសពី៣០ថ្ងៃត្រឹមបំណាច់ឆ្នាំ។[64] ឥណទានមិនដំណើរការបានកើនឡើងនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើន។[65] កត្តានេះបង្ហាញថា អ្នកខ្ចីកាន់តែច្រើនកំពុងមានបញ្ហាក្នុងការសងប្រាក់ឱ្យបានទាន់ពេលវេលា។ ជាលទ្ធផល អង្គការមិនមែនរដ្ឋាភិបាលបានកត់ត្រា និងរាយការណ៍អំពីករណីយាយី និងសម្ពាធបន្ថែមទៀតក្នុងការសងប្រាក់កម្ចី។ ស្ត្រីបានឆ្លើយតបជារឿយៗនឹងសម្ពាធនេះ ដោយប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាក និងការបង្ខិតបង្ខំឱ្យជ្រើសរើសរវាងផលប៉ះពាល់អវិជ្ជមានដែលបង្កដោយសារវិស័យនេះ ដូចជាត្រូវខ្ចីប្រាក់បន្ថែម លក់ដី ធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព កាត់បន្ថយអាហារបរិភោគ ឬឈប់ឱ្យកូនទៅរៀន ដើម្បីសន្សំប្រាក់ទុកសងបំណុល។

បំណុលវ័ណ្ឌកនៅកម្ពុជានឹងបន្តប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះស្ត្រី ជាពិសេសស្ត្រីជនជាតិដើមភាគតិច និងស្ត្រីដែលរស់នៅក្នុងភាពក្រីក្រ រហូតដល់រដ្ឋាភិបាល និងវិនិយោគិនអន្តរជាតិដែលបានទទួលផលចំណេញពីវិបត្តិនេះ ផ្តល់ជំនួយសង្គ្រោះទាន់ពេលវេលា និងឧបាស្រ័យប្រកបដោយអត្ថន័យដល់អ្នកខ្ចីដែលរងផលប៉ះពាល់។



[63] CEDAW Committee, above n 2, para. 41.
[64] Credit Bureau of Cambodia, "Retail Credit Index 2024 Q4", online: <https://www.creditbureau.com.kh/data-for-good-consumer-credit-index>.
[65] International Monetary Fund (2025) "Cambodia 2024 Article IV Consultation", online: <https://www.imf.org/-/media/Files/Publications/CR/2025/English/1khmea2025001-print-pdf.ashx>.



# អំពើហិង្សាទាក់ទងនឹងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងផ្លូវភេទ ការបៀតបៀនផ្លូវភេទ ការជួញដូរមនុស្ស និងអាពាហ៍ពិពាហ៍កុមារបានបន្តនៅម្ពុជាក្នុងឆ្នាំ២០២៤។ ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ជាច្រើនបានរងគ្រោះផ្លូវកាយ ផ្លូវចិត្ត និងផ្នែកហិរញ្ញវត្ថុ ពីព្រោះពួកគេមានលទ្ធភាពតិចតួចក្នុងការទទួលបានសេវាមូលដ្ឋាន និងយុត្តិធម៌ទោះបីជាមានអនុសាសន៍ផ្សេងៗពីគណៈកម្មាធិការ ស៊ី-ដ ក្នុងឆ្នាំ២០១៩ ដើម្បីធ្វើឱ្យលទ្ធភាពទទួលបានរបស់ស្ត្រីទាំងនេះកាន់តែប្រសើរជាងមុន។[66] ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស មួយចំនួន រួមទាំងជនជាតិដើមភាគតិចផងដែរ នៅតែត្រូវបានរាំងពីការរាយការណ៍អំពីការរំលោភបំពាន ដោយសារការភ័យខ្លាច ការរើសអើង ការស្តីបន្ទោស ការមាក់ងាយក្នុងសង្គម និងប្រភេទដំណើរការនីតិវិធីច្បាប់ដែលមានតម្លៃថ្លៃ និងចំណាយពេលវេលាច្រើន។

66 CEDAW Committee, above n 2, para. 11 and 25.

## ប្រេវ៉ាឡង់ និងទស្សនៈយល់ឃើញ

ក្នុងខែមករា ឆ្នាំ២០២៤ រដ្ឋាភិបាលកម្ពុជាបានប្រើទិន្នន័យពីការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២ ដើម្បីចេញផ្សាយការវិភាគបន្ថែមស្តីពីអំពើហិង្សាក្នុងគ្រួសារ។[67] ការវិភាគបានបញ្ជាក់ថា ជាង២១% នៃស្ត្រីកម្ពុជាដែលមានអាយុពី ១៥-៤៩ឆ្នាំ ដែលធ្លាប់មានដៃគូ បានឆ្លងកាត់អំពើហិង្សាលើផ្លូវកាយ ផ្លូវចិត្ត ឬអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាលគិតត្រឹមឆ្នាំ២០២១ ដែលជាការថយចុះពី ២៩% ក្នុងឆ្នាំ២០១៤។ ទោះបីជាមាននិន្នាការវិជ្ជមានពីឆ្នាំ២០១៤ ដល់ឆ្នាំ២០២១ នៅតាមសូចនាករមួយចំនួនក៏ដោយ ក៏ក្តីកង្វល់នៅតែមាន។

គួរកត់សម្គាល់ថាការវិភាគនេះបានរកឃើញថា មនុស្សជាច្រើនបានឆ្លងកាត់អំពើហិង្សាលើផ្លូវកាយ ផ្លូវចិត្ត ឬអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ដោយស្ត្រីដែលរងផលប៉ះពាល់ភាគច្រើនបានឆ្លងកាត់អំពើហិង្សាទាំងពីរប្រភេទនេះ។ ស្ត្រី៩០ភាគរយ ដែលបានឆ្លងកាត់អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ក៏បានរាយការណ៍ថា ដៃគូរបស់ពួកគេបានបង្ហាញអាកប្បកិរិយាគ្រប់គ្រងច្រើន។ ស្ត្រីស្ទើរតែ៧៦% ដែលបានឆ្លងកាត់អំពើហិង្សាបង្កឡើងដោយដៃគូជិតស្និទ្ធ បានរាយការណ៍អំពីភាពភ័យខ្លាចដៃគូរបស់ពួកគេជាញឹកញាប់។ ទោះបីជាមានការភ័យខ្លាចក៏ដោយ ក៏ស្ត្រី និងក្មេងស្រី ជាងពាក់កណ្តាល (៥៣%) ដែលបានឆ្លងកាត់អំពើហិង្សាផ្លូវកាយ ឬផ្លូវភេទ មិនដែលស្វែងរកជំនួយ ឬប្រាប់នរណាម្នាក់អំពីអំពើហិង្សានេះ។

ក្នុងឆ្នាំ២០២៤ អង្គការបន្ទាយស្រី ក៏បានធ្វើការស្រាវជ្រាវដើម្បីវាយតម្លៃចំណេះដឹង ឥរិយាបថ និងទស្សនៈយល់ឃើញអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទក្នុងចំណោមប្រជាសហគមន៍ក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង។[68] ក្នុងចំណោមអ្នកចូលរួម ២៤០នាក់ (ស្ត្រី៤៨% បុរស៤៦% សហគមន៍LGBTIQ+៦%) ជាងមួយភាគបី (៣៤%) បានរាយការណ៍ថា ពួកគេបានរងគ្រោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងអំពើហិង្សាពាក្យសំដី អារម្មណ៍/ផ្លូវចិត្ត ផ្លូវកាយ ហិរញ្ញវត្ថុ ឬអំពើហិង្សាផ្លូវភេទ ឬការអាពាហ៍ពិពាហ៍ដោយបង្ខំ ដោយអត្រាខ្ពស់ជាងមុនដែលត្រូវបានរាយការណ៍ក្នុងចំណោមស្ត្រីប្តូរភេទ អ្នកស្រឡាញ់ភេទដូចគ្នា និងជនមានពិការភាព។

សមាជិកគ្រួសារ គឺជាអ្នកប្រព្រឹត្តអំពើហិង្សានេះបន្ទាប់មក គឺអ្នកជិតខាង សហការី និងអ្នកដទៃ។ អ្នកឆ្លើយតប ៧៤ភាគរយ មិនបានរាយការណ៍អំពីអំពើហិង្សានេះទៅអ្នកដែលពួកគេស្គាល់ ឬដាក់ពាក្យបណ្តឹងនោះទេ។ បន្ថែមពីនេះអ្នកចូលរួម៧១% បានឃើញអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុង សហគមន៍របស់ពួកគេ។ ជារួមអ្នកឆ្លើយតប២៧% បានរាយការណ៍អំពីបញ្ហាប្រឈមក្នុងការទទួលបានការគាំទ្រ រួមទាំងការយល់ដឹងមានកម្រិតអំពីកន្លែងដែលត្រូវទទួលបានការគាំទ្រ ឬកង្វះសេវាទាំងអស់។ ការសិក្សាបានរកឃើញនិន្នាការស្រដៀងគ្នាទាក់ទងនឹងការបៀតបៀនផ្លូវភេទ។ អ្នកចូលរួម១៣% បានរាយការណ៍អំពីបទពិសោធន៍ផ្ទាល់ខ្លួននៃការបៀតបៀនផ្លូវភេទ ដែលភាគច្រើនជាស្ត្រី ឬ LGBTIQ+ ដែលមិនបានដាក់ពាក្យបណ្តឹង។

---

[67] Royal Government of Cambodia (2024) "Further Data Analysis Report from the Cambodia Demographic and Health Survey 2021-2022: Domestic Violence", online:

[68] Havas Barefoot Company Limited and Banteay Srei (2024) "Gender Based Violence and Sexual Harassment in the Community: Knowledge, Attitude and Perception/Practice Study", online: <https://banteaysrei.info/app/uploads/2025/02/Report-KAP-SHGBV-Community-Final-1.pdf>.

អ្នកចូលរួមបានរាយការណ៍ថា អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទត្រូវបានប្រព្រឹត្តជាញឹកញាប់នៅផ្ទះ កន្លែងធ្វើការ និងទីសាធារណៈ។ អ្នកចូលរួមភាគច្រើនបានរាយការណ៍ថា អំពើហិង្សា និងការបៀតបៀនមានផលប៉ះពាល់អវិជ្ជមានលើសុខភាពផ្លូវចិត្ត និងផ្លូវកាយ ព្រមទាំងលទ្ធផលសិក្សា និងការងារ។ អ្នកចូលរួមជាទូទៅបានសម្តែងការមិនពេញចិត្តចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទ និងបង្ហាញឆន្ទៈដើម្បីទប់ស្កាត់អំពើហិង្សាទាំងនេះ ទោះបីជាមនុស្សមួយចំនួន ប្រកាន់អាកប្បកិរិយាស្តីបន្ទោសជនរងគ្រោះក៏ដោយ។

ការរើសអើងក៏កើតមាននៅទូទាំងសហគមន៍ ដែលចូលរួមក្នុងការស្រាវជ្រាវនេះផងដែរ។ ជាងពាក់កណ្តាល (៥៥%) នៃអ្នកចូលរួមបានរាយការណ៍អំពីបទពិសោធន៍នៃអារម្មណ៍រើសអើងនៅក្នុងសហគមន៍របស់ពួកគេ ដោយស្រីស្រឡាញ់ស្រី ប្រុសស្រឡាញ់ប្រុស និងជនមានពិការភាពរាយការណ៍អំពីអត្រាខ្ពស់ជាងមុននៃការរើសអើង។

អង្គការបន្ទាយស្រី បានរកឃើញថាទោះបីសហគមន៍មានចំណេះដឹងមូលដ្ឋាន អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការបៀតបៀនផ្លូវភេទក៏ដោយ ក៏ចំណេះដឹង និងការយល់ដឹងដ៏ទូលំទូលាយនៅតែមានកម្រិត។ ការបង្កើនចំណេះដឹងតាមរយៈការអប់រំ និងគំនិតផ្តួចផ្តើមការលើកកម្ពស់ការយល់ដឹងអាចពង្រឹងកិច្ចខិតខំដើម្បីដោះស្រាយ និងទប់ស្កាត់ការរំលោភបំពានបែបនេះ។ ការបង្កើតកន្លែងសុវត្ថិភាព និងប្រព័ន្ធគាំទ្រដ៏រឹងមាំ ដែលមនុស្សមានអារម្មណ៍ថា ពួកគេអាចរាយការណ៍អំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយឥតប្រកាន់អត្តសញ្ញាណរបស់ជនល្មើស ក៏នៅតែមានសារៈសំខាន់ផងដែរ។

ការស្រាវជ្រាវផ្សេងទៀតធ្វើដោយអង្គការនារីដើម្បីសន្តិភាព បានរកឃើញថា សហគមន៍ចាម ខ្មែរក្រោម ជនជាតិដើមភាគតិច និងសហគមន៍ជនជាតិភាគតិចវៀតណាម ម្នាក់ៗសុទ្ធតែដឹងថាអំពើហិង្សាក្នុងគ្រួសារថាជាបញ្ហាមួយ។[69] អ្នកចូលរួមភាគច្រើនបានឆ្លើយតបថា អំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហានៅក្នុងសហគមន៍របស់ពួកគេ រួមទាំងអ្នកចូលរួមចាម៩៤% ខ្មែរក្រោម៨៧% អ្នកចូលរួមជនជាតិដើមភាគតិច៨៥% និងអ្នកចូលរួមជនជាតិភាគតិចវៀតណាម៧៧%។ មនុស្សជាច្រើនបានរាយការណ៍អំពីបទពិសោធន៍ផ្ទាល់ខ្លួននៃអំពើហិង្សា ឬបទពិសោធន៍ក្នុងគ្រួសាររបស់ពួកគេ រួមទាំងអ្នកចូលរួមជនជាតិដើមភាគតិច៦៤% អ្នកចូលរួមខ្មែរក្រោម៥៦% អ្នកចូលរួមជនជាតិភាគតិចវៀតណាម៤២% និងអ្នកចូលរួមចាម៤២%។

បន្ថែមលើការស្រាវជ្រាវនេះ អង្គការលីកាដូ បានរាយការណ៍អំពីករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងឆ្នាំ២០២៤។ ទោះបីនេះមិនមែនបង្ហាញអត្រាប្រេវ៉ាឡង់ អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅកម្ពុជាក៏ដោយ ក៏អង្គការបានរាយការណ៍ និងផ្តល់សេវាក្នុង៧៦ករណី នៃរំលោភបំពានសិទ្ធិស្ត្រី និង១៤៥ករណី នៃរំលោភបំពានសិទ្ធិក្មេងស្រី ដែលករណីភាគច្រើនពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ និង/ឬផ្លូវភេទ។[70]

លីកាដូ ក៏បានរកឃើញថាករណីហិង្សាថ្មីជាច្រើនដែលអង្គការបានរាយការណ៍ គឺពាក់ព័ន្ធនឹងអំពើហិង្សាតាមអនឡាញ។ អ្នកប្រព្រឹត្តអំពើហិង្សាផ្លូវភេទមួយចំនួនបានទាក់ទងជាមួយក្មេងស្រី តាមអនឡាញមុនពេល

[69] Women Peace Makers, above n 13.
[70] Information provided by LICADHO.

បញ្ចុះបញ្ចូលក្មេងស្រីឱ្យជួបដោយផ្ទាល់។ ក្នុង៥ករណី អ្នកប្រព្រឹត្តអំពើហិង្សាបានថតវីដេអូអំពើហិង្សាផ្លូវភេទ ឬខ្លឹមសារផ្សេងទៀតដែលពាក់ព័ន្ធនឹងកុមារដើម្បីចែកចាយវាតាមអនឡាញ ឬប្រើប្រាស់វាដើម្បីគំរាមកំហែងបន្ថែមទៀតចំពោះក្មេងស្រី។ ទោះបីប្រទេសកម្ពុជាមិនទាន់បានអនុម័តច្បាប់ជាក់លាក់ដែលដាក់ទោសទណ្ឌលើការចែកចាយរូបភាពស្និទ្ធស្នាលដោយគ្មានការព្រមព្រៀងក៏ដោយ ក៏ច្បាប់ដែលមានស្រាប់អាចអនុវត្តបានក្នុងករណីមួយចំនួន។

## អំពើហិង្សាផ្លូវភេទ និងការព្រមព្រៀង

វប្បធម៌គិតពីព្រហ្មចារីយ៍ និងបទដ្ឋានយេនឌ័រប្រពៃណីបានបន្តមានឥទ្ធិពលលើឥរិយាបថឆ្ពោះទៅរកការយល់ព្រមនៅក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ២០២៤ ដែលជារឿយៗបានបំបិទសំឡេង និងហាមការពិភាក្សាអំពីផ្លូវភេទ និងការព្រមព្រៀង។ ទោះបីការរួមភេទមិនមានការព្រមព្រៀងគ្នា គឺជាចាប់ការរំលោភក៏ដោយ ក៏និយមន័យផ្លូវច្បាប់របស់កម្ពុជាអំពីការចាប់រំលោភ មិនបញ្ជាក់ឱ្យបានច្បាស់លាស់នូវការព្រមព្រៀង។ អង្គការក្លាហាន បានធ្វើការស្រាវជ្រាវនៅឆ្នាំ២០២៤ ស្តីពីការយល់ឃើញអំពីព្រមព្រៀងផ្លូវភេទនៅកម្ពុជា។[71] ការសិក្សានេះមានបទសម្ភាសន៍ចំនួន ៦០បែបគុណវិស័យ នៅក្នុងខេត្តបី និងការអង្កេតលើមនុស្ស ៥០០នាក់តាមអនឡាន។ ការសិក្សានេះបានបញ្ជាក់ថា ការរួមភេទមិនមានការព្រមព្រៀងគ្នា គឺជាការចាប់រំលោភដែលនាំឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ឱកាសផ្សេងៗក្នុងការរស់នៅកាន់តែរួមតូច រងការមាក់ងាយក្នុងសង្គម ហានិភ័យនៃការជួបប្រទះអំពើហិង្សាកាន់តែកើនបន្ថែមទៀត បញ្ហាប្រឈមសុខភាពផ្លូវចិត្ត និងធ្វើឲ្យកាន់តែតានតឹងនៅក្នុងទំនាក់ទំនង។ គ្រោះថ្នាក់ទាំងនេះកាន់តែធ្ងន់ធ្ងរដោយសារការខ្វះខាតការគាំទ្រ និងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់អ្នកដែលបានឆ្លងកាត់អំពើហិង្សាផ្លូវភេទ។ ទោះបីអ្នកចូលរួមអង្កេត ៩៧% បានយល់ស្របថា ការព្រមព្រៀងមានសារៈសំខាន់ក៏ដោយ ក៏អ្នកចូលរួមជាងពាក់កណ្តាល (៥៣%) បានរាយការណ៍ថា មិនមានការយល់ដឹងច្បាស់លាស់អំពីគោលគំនិតនៅកម្ពុជា។ គួរកត់សម្គាល់ថា ស្ទើរតែមួយភាគបីនៃអ្នកចូលរួម (៣២%) បានយល់ស្រប ឬយល់ស្របខ្លះថា “ភាពស្ងៀមស្ងាត់ ឬមិនបដិសេធ មានន័យថា “ការព្រមព្រៀង” ដែលបញ្ជាក់ពីតម្រូវការសម្រាប់ការយល់ដឹងកាន់តែច្រើន អំពីសារៈសំខាន់នៃការព្រមព្រៀងច្បាស់លាស់វិជ្ជមាន។ អ្នកចូលរួមបានរាយការណ៍ស្រដៀងគ្នាអំពីទស្សនៈយល់ឃើញខុសគ្នាអំពីប្រភេទនៃទង្វើដែលត្រូវការការព្រមព្រៀង។ ឧទាហរណ៍៖ មានអ្នកចូលរួមតែ ២១%ប៉ុណ្ណោះជឿថា ការព្រមព្រៀងគឺចាំបាច់មុនពេលចែករំលែករូបភាពអាក្រាតកាយ ហើយអ្នកចូលរួមតែ ១៥%ប៉ុណ្ណោះជឿថា ជាការចាំបាច់ត្រូវមានការព្រមព្រៀម ក្នុងការមិនប្រើស្រោមអនាម័យអំឡុងពេលរួមភេទ ជារួមសកម្មភាពទាំងពីរខាងនេះចាត់ជាចូលជា អំពើហិង្សាផ្លូវភេទ បើមិនមានការព្រមព្រៀង។

ការស្រាវជ្រាវដោយអង្គការក្លាហានបានរកឃើញថា ការចាប់រំលោភក្នុងអាពាហ៍ពិពាហ៍ត្រូវបានគាំទ្រដោយជំនឿសង្គមថា អាពាហ៍ពិពាហ៍បញ្ជាក់នូវការព្រមព្រៀងជានិច្ច ហើយថា ខ្លួនប្រាណរបស់ស្ត្រីជាកម្មសិទ្ធិរបស់ប្តី។ ទស្សនៈយល់ឃើញទាំងនេះធ្វើឱ្យបុរសយល់ខុស និងបណ្តុះគំនិតពួកគេថាវាជាភារកិច្ច និងកាតព្វកិច្ចរបស់ស្ត្រីក្នុងការបំពេញចំណង់ផ្លូវភេទ ដែលការណ៍នេះបានបំផ្លាញទៅដល់លទ្ធភាពរបស់ស្ត្រី នូវក្នុងការផ្តល់ការព្រមព្រៀងដោយស្ម័គ្រចិត្តនៅក្នុងចំណងអាពាហ៍ពិពាហ៍។

71 Klahaan (2024) “Breaking the Silence: Navigating sexual consent in Cambodia”, online: <https://www.klahaan.org/_files/ugd/091c7d_cf7c46a658af404e8c39f80b5a2ec5ef.pdf>.

គួរកត់សម្គាល់ថា អ្នកចូលរួម៧% បានរាយការណ៍ថា ការព្រមព្រៀងចាំបាច់ត្រូវផ្ដល់តែម្ដងគត់នៅពេលចាប់ផ្ដើមទំនាក់ទំនង ហើយអ្នកចូលរួម២៧% បន្ថែមថាការព្រមព្រៀងជាថ្មីគឺមិនចាំបាច់នៅក្នុងចំណងអាពាហ៍ពិពាហ៍ ឬទំនាក់ទំនងទុកចិត្តគ្នាទៅវិញទៅមកឡើយ។

ការសិក្សាបានរាយការណ៍ថា ស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិចមួយចំនួន មិនមានសិទ្ធិសេរីភាពក្នុងផ្ដល់ការព្រមព្រៀងដោយស្ម័គ្រចិត្តនោះឡើយ ដោយសារតែអាពាហ៍ពិពាហ៍វ័យក្មេង ការទទួលបានព័ត៌មានស្ដីពីសុខភាពផ្លូវភេទ និងការព្រមព្រៀង នៅមានកម្រិត ហើយបូកផ្សំជាមួយបទដ្ឋានយេនឌ័រតឹងរ៉ឹងផងនោះ។ អង្គការក្លាហាន បានរកឃើញថា ជនមានពិការភាពមួយចំនួនក៏ប្រឈមមុខនឹងឧបសគ្គដោយមិនស្មើភាពក្នុងការទទួលបានព័ត៌មាន និងយុត្តិធម៌ ហើយថាជំនឿរើសអើងក្នុងសង្គមអាចបង្កើនអត្រាប្រេវ៉ាឡង់នៃបទពិសោធន៍អំពើហិង្សា។ ទោះបីអង្គការក្លាហាន បានរកឃើញថា សហគមន៍LGBTIQ+ ជាញឹកញាប់ពេញចិត្តក្នុងការពិភាក្សាដោយបើកចំហជាងមុនអំពីការព្រមព្រៀងក៏ដោយ ក៏ពេលខ្លះការព្រមព្រៀងមិនធ្វើទៅបានឡើយ ដោយសារការរៀបការដោយបង្ខំ និងយល់ខុសថា "ការរំលោភនរណាម្នាក់នឹងអាចផ្លាស់ប្ដូរ ឬកែប្រែទំនោរផ្លូវភេទរបស់គេ (corrective rape)"។

ទស្សនៈយល់ឃើញអំពីការព្រមព្រៀងអាចល្អប្រសើរ ដោយការបញ្ចូលការអប់រំគ្រប់ជ្រុងជ្រោយស្ដីពី សុខភាពផ្លូវភេទនៅតាមសាលារៀន ការជំនះនឹងបទដ្ឋានប្រពៃណីវប្បធម៌ និងការយល់ខុសតាមរយៈយុទ្ធនាការអប់រំសាធារណៈ ការធ្វើឱ្យប្រសើរនូវលទ្ធភាពទទួលបានសេវា និងយុត្តិធម៌និងកំណែទម្រង់ច្បាប់ និងគោលនយោបាយដើម្បីដោះស្រាយគម្លាតទាក់ទងនឹងការព្រមព្រៀង។

## លទ្ធភាពទទួលបានសេវា និងយុត្តិធម៌

លទ្ធភាពទទួលបានសេវាសំខាន់ចាំបាច់សម្រាប់អ្នកដែលបានឆ្លងកាត់ អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅតែមានកម្រិត និងមិនគ្រប់គ្រាន់នៅក្នុងឆ្នាំ២០២៤។ កម្ពុជាមិនទាន់មានវឌ្ឍនភាពគួរកត់ឲ្យសម្គាល់ទូទៅក្នុងការអនុវត្តតាមអនុសាសន៍ឆ្នាំ២០១៩ របស់គណៈកម្មាធិការ ស៊ីដ ដើម្បីបង្កើនលទ្ធភាពទទួលបានសេវាសំខាន់ចាំបាច់ប្រកបដោយគុណភាព សម្រាប់អ្នកដែលបានទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងសេវាផ្លូវច្បាប់ ថែទាំសុខភាព និងផ្លូវចិត្ត ។[72]

ទោះបីយ៉ាងនេះក្ដី ក៏ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលបានអនុវត្តជំហានវិជ្ជមានក្នុងខែធ្នូ ឆ្នាំ២០២៤ ដោយដាក់ឱ្យដំណើរការជាផ្លូវការនូវគោលការណ៍ណែនាំ ស្ដីពីការបង្កើតអង្គភាពច្រកចេញចូលតែមួយសម្រាប់ជនរងគ្រោះ[73] ដូចអនុសាសន៍ណែនាំដោយគណៈកម្មាធិការ ស៊ីដ។[74]

អង្គភាពទាំងនេះមានបំណងផ្ដល់សេវាសុខភាពវេជ្ជសាស្ត្រ ច្បាប់ ចិត្តសាស្ត្រ និងសុវត្ថិភាពរួមនៅក្នុងមន្ទីរពេទ្យបង្អែកខេត្ត ដោយធ្វើឱ្យល្អប្រសើរលទ្ធភាពទទួលបានការថែទាំដែលផ្ដោតលើជនធ្លាប់រងគ្រោះ និងការថែទាំការប៉ះទង្គិចផ្លូវចិត្ត។ កិច្ចខិតខំរួមគ្នាបន្ថែមទៀតរបស់រដ្ឋាភិបាលឥឡូវនេះជាតម្រូវការចាំបាច់ដើម្បីអនុវត្តគោលការណ៍ណែនាំទាំងនេះ និងពង្រីកការបង្កើតអង្គភាពសេវាច្រកចេញចូលតែមួយ។

---

[72] CEDAW Committee, above n 2, para. 25(c).
[73] UNFPA, "Cambodia Officially Launches the Guidelines on setting up the One-Stop Service Units for Survivors of Gender-Based Violence", December 23, 2024, online: <https://cambodia.unfpa.org/en/news/cambodia-officially-launches-guidelines-setting-one-stop-service-units-survivors-gender-based>.
[74] CEDAW Committee, above n 2, para. 25(c).

ទោះបីជាយ៉ាងនេះក្តី ក៏លទ្ធភាពទទួលបានសេវាជារួមនៅតែមិនគ្រប់គ្រាន់ក្នុងឆ្នាំ២០២៤។ ឧទាហរណ៍៖ ការស្រាវជ្រាវដោយអង្គការនារីដើម្បីសន្តិភាពបានរកឃើញថា ការទទួលបានជម្រកសុវត្ថិភាពសម្រាប់ស្ត្រីជនជាតិភាគតិច ស្ទើរតែមិនមាន៖ ១០០% នៃអ្នកចូលរួមជាជនជាតិភាគតិចវៀតណាម ៩៨% អ្នកចូលរួមចាម ៩៦% អ្នកចូលរួមជនជាតិដើមភាគតិច និង ៨៧ % ជាអ្នកចូលរួមខ្មែរក្រោម បានរាយការណ៍ថាស្ត្រីនៅក្នុងសហគមន៍របស់ពួកគេមិនទទួលបានជម្រកសុវត្ថិភាពឡើយ។[75] តាមការរាយការណ៍ឱ្យដឹងថា ស្ត្រីភាគច្រើនពឹងពាក់លើផ្ទះអ្នកជិតខាង សាច់ញាតិ ឬអាជ្ញាធរមូលដ្ឋាន ដើម្បីរក្សាសុវត្ថិភាពពីអំពើហិង្សាក្នុងគ្រួសារក្នុងរយៈពេលខ្លី។

ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទ ស្រីឬប្រុស ជាច្រើននៅតែមិនទទួលបានយុត្តិធម៌ នៅក្នុងករណី អំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ទោះបីរដ្ឋាភិបាលកម្ពុជាបានបង្ហាញពីចេតនាក្នុងការធ្វើវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (ច្បាប់អំពើហិង្សាក្នុងគ្រួសារ) ក៏ដោយ ក៏នៅមិនមានវឌ្ឍនភាពក្នុងឆ្នាំ២០២៤នេះដែរ។ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍នៅឆ្នាំ២០១៩ថា កម្ពុជាគួរធ្វើវិសោធនកម្មច្បាប់នេះដើម្បីកំណត់ហាមឃាត់ និងដាក់ទោសទណ្ឌចំពោះ អំពើហិង្សាទាក់ទងនឹងយេនឌ័រ គ្រប់ទម្រង់ និងធានាលទ្ធភាពទទួលបានដំណោះស្រាយដោយប្រសិទ្ធភាព។[76] ការធ្វើវិសោធនកម្មច្បាប់នៅតែជាជំហានចាំបាច់ ក្នុងការឆ្ពោះទៅបញ្ចប់ ការប្រើប្រាស់ការផ្សះផ្សា និងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផ្សេងទៀតដែលមិនត្រឹមត្រូវ ដើម្បីពង្រឹងលទ្ធភាពទទួលបានដំណោះស្រាយគ្រប់ជ្រុងជ្រោយ។

ការស្រាវជ្រាវដោយអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា (CRC-Cambodia) ក្នុងឆ្នាំ២០២៤ ក៏បានកត់សម្គាល់ផងដែរថា ប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជា បច្ចុប្បន្នមិនទាន់បង្កភាពងាយស្រួលសម្រាប់កុមារ និងគិតគូរដោយផ្តោតលើសិទ្ធិ តម្រូវការ និងសុខមាលភាព របស់ជនរងគ្រោះជាចំបង ឬអ្នកដែលរងផលប៉ះពាល់ដោយសារការប៉ះទង្គិចផ្លូវចិត្ត។ កាកបាទក្រហមកម្ពុជា បានធ្វើកិច្ចពិគ្រោះយោបល់ជាមួយក្មេងស្រី ១២នាក់ និងក្មេងប្រុស ១៥នាក់ អំពីលទ្ធភាពទទួលបានយុត្តិធម៌ និងដំណោះស្រាយគ្រប់ជ្រុងជ្រោយ។[77] កុមារបានរាយការណ៍ថាការទទួលបានព័ត៌មាននៅមានកម្រិត ហើយមិនដឹងពីរបៀបដាក់ពាក្យបណ្តឹងទេ។ ពួកគេក៏បានរាយការណ៍ថា ពួកគេមិនចង់ដាក់ពាក្យបណ្តឹងទេ ដោយសារមានទស្សនៈយល់ឃើញថា មិនទុកចិត្តលើប្រព័ន្ធច្បាប់ មានតម្លៃថ្លៃ និងមានភាពស្មុគស្មាញ ហើយមិនងាយស្រួលទៅទទួលយកសេវាបាន ជាពិសេសសម្រាប់អ្នករស់នៅជនបទ ឬជនមានពិការភាព។ ក្មេងស្រីបានរាយការណ៍ថា ពួកគេមិនចង់ដាក់ពាក្យបណ្តឹទេ ដោយសារតែមន្ត្រីប៉ូលីស មេធាវី និងព្រះរាជអាជ្ញាភាគច្រើនជាបុរស។

កាកបាទក្រហមកម្ពុជាបានរកឃើញថា កុមារត្រូវបានតម្រូវជាញឹកញាប់ឱ្យធ្វើសក្ខីកម្មឡើងវិញច្រើនដង។ ការសម្ងាត់ និងកន្លែងឯកជនសម្រាប់ការផ្តល់សក្ខីកម្មក៏ខ្វះខាតផងដែរ ដែលនាំឱ្យមានការភ័យខ្លាចចំពោះការមាក់ងាយ និងការរើសអើងក្នុងសង្គម។ អាជ្ញាធរពេលខ្លះមិនយកចិត្តទុកដាក់របាយការណ៍របស់កុមារ។ អាជ្ញាធរប្រើពាក្យសម្តីគំរោះគំរើយ គំរាមកំហែង ឬពាក្យសម្តីធ្ងន់ៗ ហើយមិនបានពន្យល់ពីនីតិវិធីឱ្យកុមារដឹង

75 Women Peace Makers, above n 13.
76 CEDAW Committee, above n 2, para. 25(b).
77 CEDAW Committee, above n 2, para. 25(c).

ដែលធ្វើឱ្យពួកគេភាន់ច្រឡំ និងព្រួយបារម្ភ។ លទ្ធផលតុលាការ ជាញឹកញាប់ត្រូវបានគេដឹងថា មិនយុត្តិធម៌ ឬគ្មានប្រសិទ្ធភាព ដោយទុកឲ្យកុមារបិតនៅក្នុងហានិភ័យបន្ថែមទៀត។

គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១៩ថា កម្ពុជាគួរដោះស្រាយបញ្ហាប្រឈមបែបនេះ ដោយបង្កើតគម្រោងជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយ ផ្សព្វផ្សាយព័ត៌មានអំពីនីតិវិធីសម្រាប់ការស្វែងរកដំណោះស្រាយគ្រប់ជ្រុងជ្រោយ ការពង្រឹងការឆ្លើយតបយេនឌ័រនៃប្រព័ន្ធយុត្តិធម៌ និងការធានាឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ។[78] វិធានការបន្ថែមទៀតដើម្បីអនុវត្តតាមអនុសាសន៍ទាំងនេះនៅតែចាំបាច់។

## ការជួញដូរមនុស្ស និងកន្លែងឆបោកតាមអនឡាញ

ការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជានៅតែបន្តធ្ងន់ធ្ងរ នៅក្នុងឆ្នាំ២០២៤។ នៅខែសីហា ឆ្នាំ២០២៣ របាយការណ៍អង្គការសហប្រជាជាតិបានលើកឡើងថា ក្រុមឧក្រិដ្ឋជនមានអង្គការចាត់តាំងកំពុងជួញដូរ ឃុំខ្លួន និងបង្ខំមនុស្សរាប់សែននាក់នៅទូទាំងអាស៊ីអាគ្នេយ៍ ក្នុងនោះមនុស្សប្រមាណ ១០ម៉ឺននាក់ត្រូវបានឃុំខ្លួននៅកម្ពុជា ដើម្បីធ្វើការឆបោកតាមអនឡាញដែលបង្កើតប្រាក់ចំណូលបានរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំ។[79] តាមការរាយការណ៍បានឱ្យដឹងថា បុរស និងស្ត្រីត្រូវបានជ្រើសរើសតាមរយៈការបោកបញ្ឆោតពីប្រមាណ ៤០ប្រទេស គិតត្រឹមឆ្នាំ២០២៣ ដែលរួមបញ្ចូលទាំងប្រទេសនានានៅអាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង អាហ្វ្រិក និងតំបន់ផ្សេងៗទៀតផងដែរ។[80]

អង្គការសហប្រជាជាតិបានលើកឡើងថា អ្នកដែលត្រូវបានជួញដូរទាំងនេះ បានទទួលរងគ្រោះនូវ “ការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងអំពើហិង្សាក្នុងទម្រង់ផ្សេងៗ ដែលរួមបញ្ចូលមានការគំរាមកំហែងដល់សុវត្ថិភាព និងសន្តិសុខរបស់ពួកគេផងដែរ” ហើយថា “ភាគច្រើននៃពួកគេ ទទួលរងនូវទារុណកម្មដ៏សាហាវឃោរឃៅ និងអមនុស្សធម៌ ការឃុំខ្លួនខុសច្បាប់ អំពើហិង្សាផ្លូវភេទ ពលកម្មដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សផ្សេងៗទៀត”។[81]

ទោះបីជារបាយការណ៍មួយចំនួនបានបង្ហាញថា មនុស្សភាគច្រើនដែលត្រូវបានជួញដូរទៅក្នុងអគារទាំងនេះគឺជាបុរសក្តី[82] ស្ត្រី និងក្មេងស្រីក៏ត្រូវបានជួញដូរផងដែរ។ តាមការរាយការណ៍បានឱ្យដឹងថា ស្ត្រីបានជួបប្រទះនឹងការរំលោភ និងអំពើហិង្សាផ្លូវភេទជាច្រើនទម្រង់នៅក្នុងអគារឆបោកទាំងនេះ ឬត្រូវបានលក់ទៅក្នុងការកេងប្រវ័ញ្ចផ្លូវភេទ ដោយសារពួកគេបំពេញការងារឆបោកតាមអនឡាញមិនបានជោគជ័យ។[83]

---

78 CEDAW Committee, above n 2, para. 11.
79 OHCHR, "Hundreds of thousands trafficked to work as online scammers in SE Asia, says UN report", August 29, 2023, online: <https://www.ohchr.org/en/press-releases/2023/08/hundreds-thousands-trafficked-work-online-scammers-se-asia-says-un-report>.
80 UNODC (2023) "Casinos, cyber fraud, and trafficking in persons for forced criminality in Southeast Asia", online: <https://www.unodc.org/roseap/uploads/documents/Publications/2023/TiP_for_FC_Policy_Report.pdf>.
81 OHCHR, above n 79.
82 UNODC, above n 80; OHCHR, above n 79.
83 UNODC, above n 80.

ទោះបីជាអង្គការសហប្រជាជាតិបានសង្កត់ធ្ងន់ថា មនុស្សដែលត្រូវបានឃុំខ្លួនក្នុងអគារឆបោកទាំងនេះ គឺជាជនរងគ្រោះក៏ដោយ ក៏កម្ពុជានៅតែបន្តចាត់ទុកពួកគេជាជនអន្តោប្រវេសន៍ខុសច្បាប់ដដែរ។ ការចុះបង្ក្រាបអគារទាំងនេះចាប់តាំងពីឆ្នាំ២០២២មក បានបញ្ឈប់អគារឆបោកមួយចំនួន ប៉ុន្តែអគារភាគច្រើននឹងបន្តប្រតិបត្តិការឡើងវិញបន្ទាប់ពីអំឡុងពេលណាមួយ។

របាយការណ៍របស់សហរដ្ឋអាមេរិកក្នុងឆ្នាំ២០២៤ ស្តីពីស្ថានភាពការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា បានលើកឡើងថា "អំពើពុករលួយ និងការរួមគំនិតគ្នារបស់មន្ត្រី រួមមានទាំងមន្ត្រីជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល នៅក្នុងឧក្រិដ្ឋកម្មជួញដូរនេះនៅតែកើតឡើងច្រើន"។[84] របាយការណ៍នេះបានគូសបញ្ជាក់ថា អចលនទ្រព្យមួយចំនួនដែលអ្នកឆបោកតាមអនឡាញយកទៅប្រើប្រាស់ តាមរយៈទំនាក់ទំនងអាជីវកម្មដោយផ្ទាល់ ឬដោយប្រយោលនេះ គឺជាអចលនទ្រព្យរបស់មន្ត្រីជាន់ខ្ពស់ និងទីប្រឹក្សានៅក្នុងរដ្ឋាភិបាលកម្ពុជា ដែលនាំឱ្យប្រទេសកម្ពុជាក្លាយជាប្រទេស "អនុវត្តច្បាប់ផ្អែកលើឆន្ទៈនយោបាយ" ការអនុវត្តច្បាប់ដែលមានភាពលម្អៀង ហើយមិនយកចិត្តទុកដាក់ដោះស្រាយ ឬចាត់ទុកថាបញ្ហានេះមិនបានកើតឡើង។ របាយការណ៍ស្តីពីការជួញដូរមនុស្សនេះបានកំណត់ប្រទេសកម្ពុជាជាប្រទេសនៅកម្រិតទី៣ ក្នុងឆ្នាំ២០២២ ២០២៣ និង២០២៤ ដែលជាកម្រិតទាបបំផុត។

ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងកាណាដាបានប្រកាសការដាក់ទណ្ឌកម្មក្នុងខែធ្នូ ឆ្នាំ២០២៣ ដែលប៉ះពាល់ដល់បុគ្គល៩រូប និង៥អង្គភាព ដោយសារពួកគេពាក់ព័ន្ធក្នុងការជួញដូរមនុស្សនៅក្នុងអគារឆបោកតាមអនឡាញនៅប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។[85] សហរដ្ឋអាមេរិកបានដាក់ទណ្ឌកម្មលើឧកញ៉ា លី យ៉ុងផាត់ ដែលជាសមាជិកព្រឹទ្ធសភាកម្ពុជាម្នាក់ និងដាក់ទណ្ឌកម្មលើអាជីវកម្មជាច្រើនរបស់គាត់ក្នុងខែកញ្ញា ឆ្នាំ២០២៤ "ដោយសារអាជីវកម្មទាំងនោះមានពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនឹងការបង្ខំបុគ្គលិកឱ្យធ្វើការក្នុងប្រតិបត្តិការឆបោកតាមអនឡាញ"។[86] គួរកត់សម្គាល់ផងដែរនោះ របាយការណ៍មួយចំនួនបង្ហាញថា វិស័យឆបោកតាមអនឡាញនៅកម្ពុជានៅតែបន្តរីករាលដាលនៅក្នុងឆ្នាំ២០២៤ ដោយមានភស្តុតាងបង្ហាញថាមានអគារយ៉ាងតិច ១១កន្លែង ត្រូវបានបង្កើតឡើងចាប់ពីខែធ្នូ ឆ្នាំ២០២៣ ដល់ខែតុលា ឆ្នាំ២០២៤។[87] វិបត្តិជួញដូរមនុស្សនេះ បានទាញប្រទេសកម្ពុជាទៅកាន់តែឆ្ងាយពីការបំពេញតាមអនុសាសន៍របស់គណៈកម្មាធិការ ស៊ី-ដ ឆ្នាំ២០១៩ ក្នុងការធានាថាអ្នកជួញដូរមនុស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀតត្រូវបានកាត់ទោស និងផ្តន្ទាទោស។[88]

---

84 US Department of State, "2024 Trafficking in Persons Report: Cambodia", online: <https://www.state.gov/reports/2024-trafficking-in-persons-report/cambodia/>.
85 "UK and allies sanction human rights abusers", December 8, 2023, online:
86 US Department of State, "Imposing Sanctions on Human Traffickers and Online Investment Scam Operations in Cambodia", September 12, 2024, online: <https://2021-2025.state.gov/imposing-sanctions-on-human-traffickers-and-online-investment-scam-operations-in-cambodia/>.
87 Cyber Scam Monitor, "Cambodia's Online Compounds Continue to Expand", October 29, 2024, online: <https://cyberscammonitor.substack.com/p/cambodias-online-compounds-continue>.
88 CEDAW Committee, above n 2, para. 27(e).



# សិទ្ធិការងារ និងសិទ្ធិពលកម្ម

ការរំលោភបំពានសិទ្ធិពលកម្ម និងលក្ខខណ្ឌការងារដែលមានលក្ខណៈកេងប្រវ័ញ្ច ជាពិសេសនៅក្នុងវិស័យការងារក្រៅប្រព័ន្ធ និងវិស័យកំសាន្ត នៅតែបន្តកើតឡើងនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០២៤។

## លក្ខខណ្ឌការងារសម្រាប់អ្នកបើកបរដឹកជញ្ជូនអាហារ

ការស្រាវជ្រាវរបស់សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF) ក្នុងឆ្នាំ២០២៤ បានបង្ហាញថាស្ត្រីនៅរាជធានីភ្នំពេញ ខេត្តសៀមរាប និងព្រះសីហនុ កំពុងធ្វើការកាន់តែច្រើននៅក្នុង "ប្រព័ន្ធសេដ្ឋកិច្ចការងារឯករាជ្យ" ក្នុងនាមជាអ្នកដឹកជញ្ជូនអាហារ ជាពិសេសបន្ទាប់ពីការថយចុះនៃឱកាសការងារក្នុងឧស្សាហកម្មកាត់ដេរ។[89] គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១៩ ថាប្រទេសកម្ពុជាគួរការពារសិទ្ធិស្ត្រីឱ្យមានប្រសិទ្ធភាពក្នុងវិស័យការងារក្រៅប្រព័ន្ធ និងធានាឱ្យបានថា ពួកគេអាចទទួលបានអត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម។[90]

89 CFSWF (2025) "Social Protection for Women App Worker in Food Delivery".
90 CEDAW Committee, above n 2, para. 37(b).

លទ្ធផលស្រាវជ្រាវបឋមបង្ហាញថា ស្ត្រីនៅក្នុងវិស័យក្រៅប្រព័ន្ធនេះប្រឈមមុខនឹងបញ្ហាប្រឈមផ្សេងៗ ទាក់ទងនឹងសុវត្ថិភាព ការបៀតបៀន ការរើសអើង និងអំពើហិង្សា មិនទទួលបានអត្ថប្រយោជន៍គាំពារសង្គម និងការការពារផ្សេងទៀតតាមច្បាប់ការងារប្រទេសកម្ពុជា ក៏ដូចជាការប្រឈមនឹងស្ថានភាពផ្លូវដែលមានគ្រោះថ្នាក់ និងអាកាសធាតុអាក្រក់ផងដែរ។ ការព្រួយបារម្ភអំពីសុវត្ថិភាពជាពិសេសនៅពេលយប់ក៏បានកម្រិតម៉ោងធ្វើការរបស់ស្ត្រីផងដែរ ដែលជាហេតុនាំឱ្យស្ត្រីទទួលបានប្រាក់ចំណូលទាបជាងបុរស។

ស្ត្រីមួយចំនួនដែលធ្វើការលើកម្មវិធីដឹកជញ្ជូនទាំងនេះ ក៏បានរាយការណ៍អំពីបញ្ហាប្រឈមផ្សេងៗ ពាក់ព័ន្ធនឹងគោលនយោបាយ និងការអនុវត្តរបស់កម្មវិធីដឹកជញ្ជូនអាហារផងដែរ។ ទោះបីជាកម្មវិធីដឹកជញ្ជូនទាំងអស់មានការអនុវត្តផ្សេងពីគ្នាក៏ដោយ ក៏កម្មវិធីដឹកជញ្ជូនភាគច្រើនមិនមានផ្តល់ជូនការធានារ៉ាប់រង ឧបករណ៍សុវត្ថិភាព ឬជំនួយក្នុងករណីមានឧប្បត្តិហេតុទាក់ទងនឹងការងារជូនដល់បុគ្គលិកនោះឡើយ។ កម្មវិធីដឹកជញ្ជូនភាគច្រើនក៏មិនមានផ្តល់កម្រៃសម្រាប់ការធ្វើការក្នុងថ្ងៃចុងសប្តាហ៍ ការឈប់សម្រាកបុណ្យជាតិ ឬប្រចាំឆ្នាំ ការឈប់សម្រាកពេលឈឺ ឬការឈប់សម្រាកសម្រាលកូនដែរ។ ផ្ទុយទៅវិញតាមការរាយការណ៍ បានឱ្យដឹងថា កម្មករត្រូវបានបង្ខំឱ្យធ្វើការឱ្យគ្រប់ចំនួនម៉ោងដែលបានកំណត់ ឬធ្វើការដឹកជញ្ជូនអាហារឱ្យគ្រប់តាមចំនួនកំណត់ក្នុងមួយថ្ងៃ។ កម្មវិធីដឹកជញ្ជូនមួយចំនួនមានការដាក់ពិន័យ តាមរយៈការបិទដំណើរការរាល់គណនី ដែលអសកម្មរយៈពេលបីថ្ងៃ ឬផ្តល់អត្រាថ្លៃឈ្នួលទាបក្នុងការដឹកជញ្ជូនមួយជើង ប្រសិនបើកម្មករឈប់សម្រាក។ ឧទាហរណ៍៖ កម្មវិធីដឹកជញ្ជូនមួយត្រូវបានគេរាយការណ៍ថា បានកាត់ប្រាក់ចំណូលរបស់បុគ្គលិកពី ០.៥០ដុល្លា ទៅ០.១៧ដុល្លាអាមេរិកក្នុងការដឹកជញ្ជូនមួយជើង រយៈពេលមួយសប្តាហ៍បន្ទាប់ពីបុគ្គលិកបានធ្វើការឈប់សម្រាកពីការងារ មិនថាជាការឈប់សម្រាកពេលឈឺ ឬឈប់សម្រាកដោយហេតុផលណាមួយឡើយ។ ជាទូទៅ អត្រាថ្លៃឈ្នួលទាបបានបង្ខំបុគ្គលិកជាច្រើនឱ្យធ្វើការលើសម៉ោង ដោយមានបុគ្គលិកមួយចំនួនធ្វើការរហូតដល់ ១៧ម៉ោងក្នុងមួយថ្ងៃ។

ស្ត្រីមួយចំនួនក៏បានរាយការណ៍ពីការរើសអើងយេនឌ័រ និងការរើសអើងក្នុងដំណើរការជ្រើសរើសបុគ្គលិករបស់កម្មវិធីដឹកជញ្ជូនផងដែរ។ ឧទាហរណ៍៖ ស្ត្រីម្នាក់បាននិយាយថាកម្មវិធីដឹកជញ្ជូនបានលើកឡើងថាពួកគេមិនចង់បានអ្នកដឹកជញ្ជូនស្ត្រីថ្មីទេ ដោយសារស្ត្រីបើកបរយឺតជាងបុរស ហើយធ្វើឱ្យអតិថិជនមិនសូវពេញចិត្ត។ បុគ្គលិកដែលបានតវ៉ានឹងគោលនយោបាយកម្មវិធីដឹកជញ្ជូន ឬតស៊ូមតិដើម្បីស្នើសុំលក្ខខណ្ឌការងារប្រសើរជាងមុនបានរាយការណ៍ថា ពួកគេលែងទទួលបានការបញ្ជាទិញពីអតិថិជន ដែលជាលទ្ធផលនាំឱ្យពួកគេបានបាត់បង់មុខរបរ។

ការរកឃើញនេះ បានរំលេចនូវសារៈសំខាន់សម្រាប់បុគ្គលិក ដែលធ្វើការលើកម្មវិធីដឹកជញ្ជូនទាំងនេះអាចបង្កើត និងចូលរួមក្នុងសហជីព និងសមាគមដោយសេរី ដើម្បីបញ្ចប់គោលនយោបាយ និងការអនុវត្តដែលមានលក្ខខណៈកេងប្រវ័ញ្ច ដោយធ្វើការបញ្ចូលយ៉ាងពេញលេញនូវបុគ្គលិកធ្វើការលើកម្មវិធីដឹកជញ្ជូន និងបុគ្គលិកក្នុងវិស័យការងារក្រៅប្រព័ន្ធផ្សេងទៀតនៅក្រោមច្បាប់ការងារនៃប្រទេសកម្ពុជា ដើម្បីធានាថាពួកគេមិនត្រូវបានផាត់ចេញពីការទទួលបានសិទ្ធិជាមូលដ្ឋាន និងការការពារ ដែលគួរទទួលដូចបុគ្គលិកដទៃទៀត។

## ការតាមដានលើអនុលោមភាពនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងសេរីភាពក្នុងការបង្កើតសមាគម

ក្នុងខែមិថុនា ឆ្នាំ២០២៤ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) សហព័ន្ធសហជីពកម្ពុជា (CATU) និងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) បានបោះពុម្ពឯកសារស្រាវជ្រាវអំពីកម្រិតនៃការការពារសេរីភាពក្នុងការបង្កើតសមាគមក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ស្បែកជើង និងផលិតផលធ្វើដំណើរ ថាតើគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) បានធ្វើការវាយតម្លៃសមស្របលើឧបសគ្គចំពោះសេរីភាពក្នុងការបង្កើតសមាគម ដែរឬយ៉ាងណា។[91] ការស្រាវជ្រាវរួមគ្នាមានក្រុមផ្តោតសំខាន់ចំនួនបីជាមួយតំណាងសហជីពចំនួន៧៨ នៅរោងចក្រចំនួន២២ និងការសម្ភាសន៍ជាមួយសមាជិកសហជីពមកពី ១៤រោងចក្រ។ ការស្រាវជ្រាវបែបនេះមានសារៈសំខាន់ក្នុងការគាំទ្រសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម សម្រាប់កម្មករកាត់ដេរទាំងអស់នៅប្រទេសកម្ពុជា ដែលកម្មករភាគច្រើនជាស្ត្រី។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) ដែលជាកម្មវិធីសហការអនុវត្តដោយ ILO និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ មានគោលបំណងពិនិត្យតាមដាន និងជូនដំណឹងដល់ក្រុមហ៊ុនម៉ាកយីហោ និងអ្នកទិញអំពីការអនុលោមតាមស្តង់ដារការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរនាំចេញ។ ការសិក្សាបានរកឃើញថារបាយការណ៍អនុលោមភាព និងព័ត៌មានផ្សេងទៀតរបស់ BFC មិនត្រឹមតែពិបាកទទួលបាន និងពិបាកយល់សម្រាប់សមាជិកសហជីពប៉ុណ្ណោះទេ ប៉ុន្តែលទ្ធផលដែលបានរកឃើញទាំងនោះខ្វះព័ត៌មានលម្អិតគ្រប់គ្រាន់ ហើយភាគច្រើនមិនសមស្របជាមួយនឹងបទពិសោធន៍ផ្ទាល់របស់សមាជិកសហជីពឡើយ។ គួរកត់សម្គាល់ថា BFC បានផ្តល់ពិន្ទុល្អតតខ្ទោះដល់រោងចក្រទាំង១៤នោះ ទាក់ទងនឹងសេរីភាពក្នុងការបង្កើតសមាគម ប៉ុន្តែសមាជិកសហជីពមកពី១០រោងចក្រ ក្នុងចំណោមរោងចក្រទាំងនោះ បានរាយការណ៍អំពីការបំភិតបំភ័យ ការគំរាមកំហែង ការយាយី និងការចុះឈ្មោះក្នុងបញ្ជីខ្មៅដែលធ្វើឱ្យប៉ះពាល់សិទ្ធិសេរីភាពក្នុងការបង្កើតសមាគមរបស់ពួកគេ។ ជាលទ្ធផល សមាជិកសហជីព បានរាយការណ៍ថារបាយការណ៍របស់ BFC ភាគច្រើនមិនអាចជួយពួកគេក្នុងកិច្ចខិតខំតស៊ូមតិ និងចរចាដើម្បីការគោរពសេរីភាពក្នុងការបង្កើតសមាគមបានឡើយ។

បន្ទាប់ពីការបោះពុម្ពរបាយការណ៍នេះ សង់ត្រាល់ បានប្រឈមមុខនឹងប្រតិកម្មខ្លាំងពីសហជីពដែលចងសម្ព័ន្ធជាមួយរដ្ឋាភិបាល ហើយប្រឈមមុខនឹងវិធានការរបស់រដ្ឋាភិបាល។ ក្នុងខែមិថុនា ឆ្នាំ២០២៤ ក្រុម និងសហគមន៍ សង្គមស៊ីវិល ចំនួន៤៤ក្រុម បានថ្កោលទោសការសម្រេចរបស់ក្រសួងមហាផ្ទៃ ក្នុងការស៊ើបអង្កេតអង្គការមិនមែនរដ្ឋាភិបាល។[92] អង្គការឃ្លាំមើលសិទ្ធិមនុស្សបានកត់សម្គាល់ថា ការដាក់វិធានការចំពោះសង់ត្រាល់បានគំរាមកំហែង “មិនត្រឹមតែសិទ្ធិការងារប៉ុណ្ណោះទេ ថែមទាំងគំរាមកំហែងដល់ការរាយការណ៍រិះគន់ទាំងអស់ដោយសង្គមស៊ីវិលនៅកម្ពុជាផងដែរ”។[93]

---

[91] CENTRAL, CATU and C.CAWDU (2024) “Barries to Representation: Freedom of Association in Cambodia”, online: <https://central-cambodia.org/wp-content/uploads/2024/06/Barriers-to-Representation_-Freedom-of-Association-in-Cambodia.pdf>.

[92] Joint Statement, “Stop Reprisals Against CENTRAL Over Better Factories Report”, June 27, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=528>.

[93] Human Rights Watch, “Cambodia: Smear Campaign against Labor Group”, July 2, 2024, online: <https://www.hrw.org/news/2024/07/02/cambodia-smear-campaign-against-labor-group>.

## កង្វះសំណង/ដំណោះស្រាយពីក្រុមហ៊ុន Evergreen Apparel (Cambodia)

នៅក្នុងឆ្នាំ២០២៤ ស្ត្រីចំនួន៩នាក់ បានបន្តតស៊ូទាមទារដំណោះស្រាយ និងសំណងសមរម្យពីក្រុមហ៊ុន Evergreen Apparel (Cambodia)។ ក្រុមហ៊ុន Evergreen Apparel បានបិទប្រតិបត្តិការក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ដែលធ្វើឱ្យកម្មករប្រហែល១៧០០នាក់ មិនទទួលបានដំណោះស្រាយ ឬសំណងសមរម្យដែលពួកគេមានសិទ្ធិគួរទទួលបានយោងតាមច្បាប់ការងារនៃប្រទេសកម្ពុជា។ បន្ទាប់ពីបានចរចាជាច្រើនឆ្នាំកន្លងមក កម្មករទាំងអស់បានទទួលយកសំណងដែលផ្ដល់ដោយក្រុមហ៊ុន លើកលែងតែកម្មករ៩នាក់ ដែលមិនព្រមទទួលយកការទូទាត់នេះ។[94] កម្មករទាំង៩នាក់នោះ បានបន្តទាមទារឱ្យមានការគោរពពេញលេញចំពោះសិទ្ធិរបស់ពួកគេ រួមទាំងប្រាក់ឈ្នួលចុងក្រោយរបស់ពួកគេ និងសំណងផ្សេងទៀតដែលពួកគួរទទួលបានទៅតាមផ្លូវច្បាប់។

ទោះបីជាកម្មករទាំងនោះខិតខំតស៊ូស្វែងរកកិច្ចអន្តរាគមន៍ពីអាជ្ញាធរ ក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតក៏ដោយ ក៏ក្រុមហ៊ុន Evergreen Apparel នៅតែគេចវេសពីការទទួលខុសត្រូវ និងបន្តពន្យារពេលក្នុងការផ្តល់ដំណោះស្រាយដែលសមស្របដែរ។ កម្មកររាយការណ៍ថា កង្វះដំណោះស្រាយសមស្រប និងស្ថានភាពការងារមិនស្ថិតស្ថិររបស់ពួកគេ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងហិរញ្ញវត្ថុរបស់ពួកគេ។ ស្ត្រីក្នុងចំណោមកម្មករ ៩នាក់បានរាយការណ៍អំពីផលប៉ះពាល់អវិជ្ជមានដែលរួមមានការរើសអើង ការផាត់ចេញពីសង្គម និងការបាក់ទឹកចិត្ត។ ពួកគេមិនមានលទ្ធភាពក្នុងការបង់ថ្លៃឈ្នួលបន្ទប់ ថ្លៃទឹកភ្លើង ឬអាហារគ្រប់គ្រាន់ឡើយ ហើយដោយសារតែស្ថានភាពហិរញ្ញវត្ថុបែបនេះ ពួកគេក៏មិនអាចទទួលបានការថែទាំសុខភាពគ្រប់គ្រាន់នៅកំឡុងពេល និងក្រោយពេលមាតុភាព គាំទ្រការអប់រំរបស់កូនៗ ឬបំពេញតម្រូវការរបស់ឪពុកម្តាយចាស់ និងសមាជិកគ្រួសាររបស់ពួកគេផងដែរ។ កម្មករក៏បានរាយការណ៍អំពីបញ្ហាប្រឈមក្នុងការសងបំណុល ហើយត្រូវជំពាក់បំណុលបន្ថែម ខណៈដែលរង់ចាំការឆ្លើយតបពីក្រុមហ៊ុន Evergreen Apparel និងអាជ្ញាធរពាក់ព័ន្ធ។

កម្មករទាំងប្រាំបួននាក់ បានបន្តខិតខំការពារសិទ្ធិរបស់ពួកគេនៅក្នុងឆ្នាំ២០២៤ ដោយអំពាវនាវស្នើសុំដំណោះស្រាយពីអាជ្ញាធរពាក់ព័ន្ធ យន្តការក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ និងក្រុមហ៊ុនEvergreen Apparel។ រហូតមកដល់ពេលនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ Evergreen Apparel និងក្រុមហ៊ុនម៉ាកយីហោផ្សេងៗ មិនទាន់បានផ្តល់ជូនដំណោះស្រាយសមស្របដល់កម្មករទាំង៩នាក់នោះនៅឡើយទេ។



[94] See, Sorn Sarath, "Three years on, former workers of closed garment factory still struggle for compensation", CamboJA News, April 4, 2022, online: <https://cambojanews.com/three-years-on-former-workers-of-closed-garment-factory-still-struggle-for-compensation/>.

## សិទ្ធិការងារក្នុងវិស័យកំសាន្ត

កន្លែងកំសាន្តជាច្រើនដូចជា ភោជនីយដ្ឋាន បា ក្លឹបរាត្រី ហាងម៉ាស្សា និងខារ៉ាអូខេ មិនបានគោរពសិទ្ធិការងារ និងអនុវត្តគោលនយោបាយកេងប្រវ័ញ្ចដោយគ្មានការទទួលខុសត្រូវនៅក្នុងឆ្នាំ២០២៤។ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) បានរាយការណ៍ថា បុគ្គលិកក្នុងវិស័យកំសាន្តមិនមានប្រាក់ឈ្នួលអប្បបរមាដែលការពារដោយច្បាប់នោះទេ។ ជាញឹកញាប់ ពួកគេមិនមានកិច្ចសន្យាការងារ និងការការពារផ្លូវច្បាប់ដែលពាក់ព័ន្ធឡើយ។ ពេលខ្លះពួកគេធ្វើការដោយគ្មានប្រាក់ឈ្នួល ហើយពួកគេទទួលបានតែប្រាក់ទឹកតែប៉ុណ្ណោះ។ ជាញឹកញាប់ ពួកគេធ្វើការថែមម៉ោងដោយគ្មានសំណង និងបាត់បង់ការងារ ដោយគ្មានលទ្ធភាពទទួលបានអត្ថប្រយោជន៍ផ្លូវច្បាប់។ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នាក៏បានរកឃើញដូចគ្នាដែរថា បុគ្គលិកតិចតួចណាស់នៅក្នុងវិស័យកំសាន្ត មានលទ្ធភាពទទួលបានកិច្ចគាំពារសង្គម។ ឧទាហរណ៍៖ បុគ្គលិកក្នុងវិស័យកំសាន្ត ៨នាក់ ក្នុងចំណោម ១៦០នាក់ ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវបានរាយការណ៍ថា ពួកគេមានលទ្ធភាពទទួលបានបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)។[95]

អង្គការបណ្តាញការងារស្ត្រីរួបរួម បានរកឃើញថាការប្រើប្រាស់គោលនយោបាយកេងប្រវ័ញ្ចទូទៅក្នុងវិស័យកំសាន្តបានធ្វើឱ្យទម្លាប់អនុវត្តនេះទៅជាធម្មតា។ គោលនយោបាយនេះបានរារាំងកម្មករមិនឱ្យរៀបចំលក្ខខណ្ឌការងារល្អប្រសើរ និងបានធ្វើឱ្យបុគ្គលិកផ្លាស់ទៅធ្វើការ ក្នុងបរិយាកាសមិនសូវមានសុខសុវត្ថិភាព។ បរិយាកាសសេដ្ឋកិច្ចដែលទូលំទូលាយក៏បានរួមចំណែកឱ្យមានការបិទ និងការផ្អាកវិស័យកំសាន្ត និងទេសចរណ៍ ដោយគ្មានការការពារសម្រាប់បុគ្គលិក។ ជាមួយនឹងលក្ខខណ្ឌទាំងនេះ បានបណ្តាលឱ្យមានប្រាក់ចំណូលទាប បំណុលកើនឡើង និងកម្រិតជីវភាពកាន់តែអាក្រក់ក្នុងចំណោមបុគ្គលិកក្នុងវិស័យកំសាន្ត។

បុគ្គលិកក្នុងវិស័យកំសាន្ត រួមទាំងអ្នកប្រកបរបរផ្លូវភេទ ត្រូវតែមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងមានលទ្ធភាពទទួលបានសិទ្ធិ និងការការពារជាមូលដ្ឋានដែលមានចែងក្នុងច្បាប់ការងារប្រទេសកម្ពុជា និងប្រកាសពាក់ព័ន្ធស្តីពីលក្ខខណ្ឌការងារ។



95 Information provided by WNU.



# ការរើសអើងអ្នកប្រកបរបរផ្លូវភេទ

ការរើសអើង និងការទទួលស្គាល់ការងារប្រកបរបរផ្លូវភេទថា ជាការងារនៅតែមានសារៈសំខាន់នៅក្នុងឆ្នាំ២០២៤។ គណៈកម្មាធិការ ស៊ី-ដ នៅឆ្នាំ២០១៩ បានផ្តល់អនុសាសនថា កម្ពុជាគួរកែសម្រួលច្បាប់ជាតិរបស់ខ្លួន ដើម្បីកុំឱ្យដាក់ទោសព្រហ្មទណ្ឌលើអ្នកប្រកបរបរផ្លូវភេទ និងដើម្បីដោះស្រាយកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងវិសមភាព[96]យេនឌ័រតាមរចនាសម្ព័ន្ធ។ ទោះបីយ៉ាងនេះក្តី ការដាក់ទោសព្រហ្មទណ្ឌជាបន្តបន្ទាប់ធ្វើឱ្យប៉ះពាល់សមត្ថភាពរបស់អ្នកប្រកបរបរផ្លូវភេទ ក្នុងការចរចាលក្ខខណ្ឌការងារឱ្យល្អប្រសើរ និងរារាំងពួកគេមិនឱ្យស្វែងរកយុត្តិធម៌ដោយសារការរំលោភបំពានសិទ្ធិតាមរយៈប្រព័ន្ធច្បាប់។ កិច្ចអន្តរាគមន៍ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សក៏នៅតែបន្តអនុវត្តខុស ហើយធ្វើមានការការភាន់ច្រឡំថា ការងារប្រកបរបរផ្លូវភេទ និងការជួញដូរគឺដូចគ្នាទៅនឹងការដែលធ្វើឲ្យមានការរំលោភបំពានលើសិទ្ធិអ្នកប្រកបរបរផ្លូវភេទ។

អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នាបានចងក្រង ការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទចំនួន ១១៦នាក់ ក្នុងឆ្នាំ២០២៤។[97] ដំបូងឡើយ អ្នកប្រកបរបរផ្លូវភេទជាច្រើនត្រូវបានបញ្ជូនទៅសាលាសង្កាត់ មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (ព្រៃស្ពឺ) ឬមជ្ឈមណ្ឌលស្តារនីតិសម្បទាគ្រឿងញៀន ដែលត្រូវបានគេរាយការណ៍ថា មនុស្សត្រូវបានឃុំខ្លួនតាមអំពើចិត្ត។ អង្គការបណ្តាញការងារស្ត្រីរួបរួមគ្នា បានរាយការណ៍បន្ថែមថា យ៉ាងតិច ១០ករណីនៃអំពើហិង្សា និងការកេងប្រវ័ញ្ចត្រូវបានប្រព្រឹត្តចំពោះអ្នកប្រកបរបរផ្លូវភេទក្នុងឆ្នាំ២០២៤ ដោយសន្តិសុខ អតិថិជន ដៃគូស្និទ្ធស្នាល និងបុគ្គលិកមជ្ឈមណ្ឌលឃុំឃាំងតែម្តង។ អ្នកប្រកបរបរផ្លូវភេទមួយចំនួនក៏បានរាយការណ៍អំពីការប្រឈមនឹងការរើសអើងទ្វេរដង និងមិនទទួលបានការយកចិត្តទុកដាក់ដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។ គួរកត់សម្គាល់ថា អ្នកប្រកបរបរផ្លូវភេទដែលប្តូរភេទបានរាយការណ៍ អំពីការកើនឡើងការរំលោភបំពាន ការប្រមាថ និងការបៀតបៀនជាសាធារណៈនៅឆ្នាំ២០២៤ ដោយគ្មានអន្តរាគមន៍ ឬការគាំទ្រពីអាជ្ញាធរ។

---

[96] CEDAW Committee, above n 2, para. 29.
[97] Information provided by WNU.

អ្នកប្រកបរបរផ្លូវភេទក៏បានរាយការណ៍អំពីហានិភ័យឆ្លងមេរោគអេដស៍ និងជំងឺកាមរោគដោយសារការទទួលបានស្រោមអនាម័យនៅមានកម្រិតដោយឧបសគ្គផ្នែកហិរញ្ញវត្ថុ ព័ត៌មានអំពីកន្លែងដែលត្រូវទទួលស្រោមអនាម័យនៅមានកម្រិត និងការរើសអើងនៅតាមមណ្ឌលសុខភាព។ កត្តាស្រដៀងគ្នានេះបានធ្វើឱ្យស្ត្រីអ្នកប្រកបរបរផ្លូវភេទដែលមានផ្ទៃពោះដោយមិនបានគ្រោងទុក ឈានទៅរកការរំលូតកូននៅផ្ទះដោយមិនមានសុវត្ថិភាព និងមានតម្លៃថ្លៃដែលជាកត្តានាំឱ្យអត្រាមរណភាពមាតាកើនឡើងកាន់តែខ្ពស់។ ការដោះស្រាយ និងបំបាត់ការរើសអើងក្នុងការថែទាំសុខភាព សេវាផ្លូវច្បាប់ និងក្នុងចំណោមសាធារណជននៅតែជាសកម្មភាពដ៏សំខាន់ដដែល។

# ការពពោះជំនួស

កម្ពុជាបានបន្តដាក់ទោសព្រហ្មទណ្ឌ លើស្ត្រីដែលពពោះជំនួសនៅឆ្នាំ២០២៤។ ក្នុងឆ្នាំ២០១៩ គណៈកម្មាធិការស៊ី-ដ បានអំពាវនាវឱ្យកម្ពុជាបញ្ឈប់ការឃុំខ្លួនស្ត្រីដែលពពោះជំនួស និងបញ្ចប់ការតម្រូវឱ្យស្ត្រីដែលពពោះជំនួសព្រមទទួលចិញ្ចឹមកូនជាកូនផ្ទាល់របស់ខ្លួន ដើម្បីទទួលបានការដោះលែងពីការឃុំឃាំង និងចោទប្រកាន់តាមផ្លូវច្បាប់ផ្សេងៗ។[98]

កម្ពុជាបានចេញប្រកាសកាលពីឆ្នាំ២០១៦ ដោយហាមការពពោះជំនួសគ្រប់ទម្រង់។ ក្រោយមករដ្ឋាភិបាលបានចាប់ផ្តើមបង្កើតសេចក្តីព្រាងច្បាប់ ដែលមានបំណងគ្រប់គ្រងឱ្យបានគ្រប់ជ្រុងជ្រោយនូវការអនុវត្តនេះ។ សេចក្តីព្រាងច្បាប់ត្រូវបានផ្សព្វផ្សាយនៅឆ្នាំបន្តបន្ទាប់ ប៉ុន្តែសេចក្តីព្រាងច្បាប់នេះបានធ្វើឱ្យមានក្តីកង្វល់[99] បន្ថែមទៀត ហើយមិនទាន់ត្រូវបានបញ្ចប់ ឬអនុម័តនៅឡើយទេគិតត្រឹមឆ្នាំ២០២៤។ កម្ពុជាបែរជាបានបន្តដាក់ទោសព្រហ្មទណ្ឌលើស្ត្រីដែលពពោះជំនួសក្រោមបញ្ញត្តិ ដែលមានស្រាប់នៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ការឆ្លើយតបរបស់កម្ពុជាចំពោះការពពោះជំនួសផ្តោតជាចម្បងលើការហាមលក់កុមារ។ ទោះបីនេះជាការពិចារណាដ៏សំខាន់ ក្នុងការឆ្លើយតបទៅនឹងការពពោះជំនួសក៏ដោយ ក៏អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីការលក់ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារបានកត់សម្គាល់ពី “ផលវិបាកធ្ងន់ធ្ងរ” នៃ “ការបកស្រាយមានកម្រិត” របស់កម្ពុជាអំពីគោលគំនិតនេះ ដែលអាចមិនបានគិតពីឧត្តមប្រយោជន៍របស់កុមារ និងសិទ្ធិស្ត្រីដែលពពោះជំនួស និងឪពុកម្តាយដែលមានបំណងក្លាយជាឪពុកម្តាយស្របច្បាប់តាមរយៈការពពោះជំនួស។[100]

នៅក្នុងខែកញ្ញា ឆ្នាំ២០២៤ស្ត្រី២៥នាក់ គឺមានស្ត្រីហ្វីលីពីន២០នាក់ ស្ត្រីវៀតណាម៤នាក់ និងស្ត្រីខ្មែរម្នាក់ត្រូវបានឃុំខ្លួននៅកម្ពុជា។ ស្ត្រី១១នាក់ត្រូវបានដោះលែងនៅពេលរកឃើញថាស្ត្រី១១នាក់នោះមិនមានផ្ទៃពោះ។

98 CEDAW Committee, above n 2, para. 47(a).
99 See, NGO-CEDAW, "2022 CEDAW Monitoring Reports for Cambodia", online: <https://www.klahaan.org/_files/ugd/091c7d_a50ffd17d4994b14a2ee649f579a8273.pdf>
100 Report of the Special Rapporteur on the sale and sexual exploitation of children, including child prostitution, child pornography and other child sexual abuse material, A/74/162, 15 July 2019, para. 77, online: <https://docs.un.org/A/74/162>.

ទោះបីយ៉ាងនេះក្តីស្ត្រីហ្វីលីពីនចំនួន១៣នាក់ ដែលពពោះជំនួសស្ថិតក្នុងដំណាក់កាលមានផ្ទៃពោះខុសគ្នា ត្រូវបានឃុំខ្លួននៅក្នុងមន្ទីរពេទ្យក្នុងតំបន់អស់រយៈពេលច្រើនខែ។ ស្ត្រីខ្មែរដែលបម្រើការងារធ្វើម្ហូប និងសម្អាតឱ្យស្ត្រីមានផ្ទៃពោះ ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ននៅមណ្ឌលកែប្រែទី២[101] រាជធានីភ្នំពេញ។

ជាលើកទីមួយ ដែលកម្ពុជាបានផ្តន្ទាទោសជនជាតិបរទេសពីបទពពោះជំនួស គឺស្ត្រីហ្វីលីពីន១៣នាក់ ត្រូវបានផ្តន្ទាទោសក្នុងខែធ្នូ ឆ្នាំ២០២៤ ពីបទចោទប្រកាន់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ ពួកគេត្រូវផ្តន្ទាទោសដាក់ពន្ធនាគារបួនឆ្នាំដោយព្យួរទោស[102]រយៈពេលពីរឆ្នាំ។ ស្ត្រីទាំង១៣នាក់ នោះត្រូវបានគេផ្តល់ការលើកលែងទោសពីព្រះមហាក្សត្រនៅចុងខែធ្នូ ហើយពួកគេត្រូវបានធ្វើមាតុភូមិនិវត្តទៅកាន់ប្រទេសហ្វីលីពីន រួមជាមួយទារកបីនាក់ដែលបានកើតអំឡុងពេលឃុំខ្លួនពួកគេផងដែរ។[103] ព័ត៌មានអំពីឪពុកម្តាយ ដែលត្រូវទទួលកូននោះពីការពពោះជំនួស និងអ្នកដែលត្រូវទទួលខុសត្រូវក្នុងការចិញ្ចឹមកូន នៅតែមានភាពមិនច្បាស់លាស់។ ស្ត្រីខ្មែរម្នាក់ត្រូវបានផ្តន្ទាទោសដោយសារគាត់មិនបានរាយការណ៍អំពីបទឧក្រិដ្ឋ និងផ្សំគំនិតក្នុងដំណើរការនោះ។ ស្ត្រីខ្មែរម្នាក់នោះបានជាប់ពន្ធនាគារពីរខែរួចមកហើយ ហើយទោសដែលនៅសល់ប្រាំមួយខែរបស់គាត់នោះត្រូវបានព្យួរ។

ជារួមកម្ពុជាមិនទាន់មានវឌ្ឍនភាពនៅក្នុងការអនុវត្តអនុសាសន៍ របស់គណៈកម្មាធិការ ស៊ីដ ឆ្នាំ២០១៩ ទាក់ទងនឹងការពពោះជំនួសនៅឡើយទេ ហើយបែរជាបានបន្តដាក់ទោសទណ្ឌ លើអ្នកដែលងាយរងគ្រោះទៅវិញ។



[101] Sovann Sreypich and Tang Porgech, "Cambodian and Thai Authorities Investigate Surrogacy Case As Filipino Surrogate Mothers Are Detained Until Delivery", CamboJA News, October 22, 2024, online: <https://cambojanews.com/cambodian-and-thai-authorities-investigate-surrogacy-case-as-filipino-surrogate-mothers-are-detained-until-delivery/>.

[102] the Philippines, Phnom Penh, Cambodia, "Philippine Embassy Statement on the Case of 13 Filipino Surrogates Charged for Violation of Cambodian Laws", December 2, 2024, online: <https://phnompenhpe.dfa.gov.ph/embassy-news/1317-philippine-embassy-statement-on-the-case-of-13-filipino-surrogates-charged-for-violation-of-cambodian-laws>.

[103] Embassy of the Philippines, Phnom Penh, Cambodia, "Statement on the Repatriation of the 13 Filipino Surrogates from Cambodia", December 30, 2024, online: <https://phnompenhpe.dfa.gov.ph/embassy-news/1329-dfa-statement-on-the-repatriation-of-the-13-filipino-surrogates-from-cambodia>; Embassy of the Philippines, Phnom Penh, Cambodia, "Philippine Ambassador Conveys Appreciation to Philippine Airlines for the Safe Repatriation from Cambodia of the 13 Filipino Surrogates", January 8, 2025, online: <https://phnompenhpe.dfa.gov.ph/embassy-news/1331-philippine-ambassador-conveys-appreciation-to-philippine-airlines-for-the-safe-repatriation-from-cambodia-of-the-13-filipino-surrogates>.

# ការថែទាំសុខភាព

## សិទ្ធិ សុខភាពផ្លូវភេទ និងបន្តពូជ

កម្ពុជាសម្រេចបានលទ្ធផលមួយចំនួនទាក់ទងនឹងការបង្កើនការទទួលបាន សិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ (SRHR) នៅក្នុងឆ្នាំ២០២៤។ ទោះបីយ៉ាងនេះក្តី ចាំបាច់ត្រូវមានវិធានការបន្ថែមទៀតដើម្បីអនុវត្តឱ្យបានពេញលេញនូវអនុសាសន៍ទាក់ទងនឹងសុខភាពដែលធ្វើឡើងដោយគណៈកម្មាធិការ ស៊ី-ដ ក្នុងឆ្នាំ២០១៩។[104] គួរកត់សម្គាល់ថា សកម្មភាពបន្ថែមទៀតគឺចាំបាច់ដើម្បីធានាថា គ្រប់យុវជនទាំងអស់មានលទ្ធភាពទទួលបានការអប់រំផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) និងមានសេវាសម្រាប់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស គ្រប់រូប។

គិតត្រឹមឆ្នាំ២០២៤ គ្រូបង្រៀនចំនួន១៦២៤៥នាក់ ត្រូវបានគេរាយការណ៍ថា បានទទួលការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់សៀវភៅអប់រំសុខភាពរបស់កម្ពុជា ដែលស្មើនឹងប្រមាណ២០% នៃគ្រូបង្រៀន ៨០០០០នាក់ ដែលប្រទេសកម្ពុជាបានប្តេជ្ញាថានឹងបណ្តុះបណ្តាល។[105] អត្រាបណ្តុះបណ្តាលយឺតបានបណ្តាលឱ្យមានការខ្វះខាតជាបន្តបន្ទាប់នូវមនុស្ស ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីបង្រៀន CSE។ ការសិក្សាដោយអង្គការថែទាំសុខភាពគ្រួសារកម្ពុជា (RHAC) បានរកឃើញបន្ថែមទៀតថា កង្វះសម្ភារៈដែលបោះពុម្ព និងសៀវភៅសិក្សាបានបន្តបង្កឱ្យមានបញ្ហាប្រឈមដ៏សំខាន់ ក្នុងលទ្ធភាពទទួលបាន CSE ប្រកបដោយគុណភាព។[106] អង្គការ RHAC បានរកឃើញថា បទដ្ឋានវប្បធម៌ ការមាក់ងាយ និងព័ត៌មានភាន់ច្រឡំជុំវិញ SRHR បានធ្វើឱ្យប៉ះពាល់លទ្ធភាពទទួលបានការអប់រំ និងសេវាកម្មចាំបាច់។

អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC) ក៏បានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន គ្រូបង្រៀន និងបុគ្គលិកមណ្ឌលសុខភាពក្នុងខេត្តចំនួនបួននៅក្នុងឆ្នាំ២០២៤ ដើម្បីផ្តល់ការអប់រំឱ្យសហគមន៍ និងយុវជនលើ SRHR ការប្រឹក្សាសុខភាពតាមអនឡាញ និងការណែនាំពួកគេទៅកាន់សេវាមានវិជ្ជាជីវៈ។ តាមរយៈការងាររបស់ពួកគេ CHEC បានរកឃើញថា យុវជនប្រឈមមុខនឹងបញ្ហាក្នុងការទទួលបានសេវាថែទាំសុខភាពដោយសារចម្ងាយ និងកង្វះមធ្យោបាយធ្វើដំណើរទៅកន្លែងទទួលសេវា។ ក្តីកង្វល់អំពីការសម្ងាត់ដោយសារមណ្ឌលសុខភាពមួយចំនួន ខ្វះបន្ទប់ពិគ្រោះដាច់ដោយឡែក ការស្ទាក់ស្ទើរក្នុងចំណោមមនុស្សមួយចំនួនក្នុងការបង្ហាញពីបញ្ហាសុខភាព ដោយសារតែការភ័យខ្លាចការរើសអើង និងអត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភដោយសារការទទួលបានអាហារមិនគ្រប់គ្រាន់។

អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) ក៏បានរៀបចំកិច្ចប្រជុំជាមួយសហគមន៍ និងក្រុមតូចដែលមានមនុស្ស ៨២០នាក់ (ស្ត្រី៨២%) នៅទូទាំង៣១សហគមន៍ក្នុងឆ្នាំ២០២៤។ UPWD បានរកឃើញបញ្ហាប្រឈមជាច្រើន ដូចជាឧបសគ្គផ្នែកហិរញ្ញវត្ថុដែលរារាំងស្ត្រីមិនឱ្យទទួលបានការថែទាំសុខភាព ការលំបាកក្នុងការទទួលបានការធ្វើតេស្តជំងឺកាមរោគ ជាពិសេសក្នុងចំណោមស្ត្រីដែលមានអាយុជាង៦០ឆ្នាំ និងការផ្សព្វផ្សាយមានកម្រិតអំពីព័ត៌មានគោលនយោបាយ ស្តីពីសុខភាពក្នុងចំណោមសាធារណជន។

104 CEDAW Committee, above n 2, para. 39(a)-(b).
105 Information provided to RHAC.
106 RHAC (2024) "Fact Sheet - An Assessment of CSE Intervention on Sexual Behaviors among Cambodian Adolescents: A Mixed Method Study", online: <https://rhac.org.kh/storage/publication/CSE%20Intervention%20Factsheet-Eng.pdf>.

ការដោះស្រាយបញ្ហាប្រឈមនីមួយៗទាំងនេះ ចាំបាច់ត្រូវធានាថា គ្រប់ស្ត្រីកម្ពុជា ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ទាំងអស់ មានលទ្ធភាពទទួលបានសេវា និងព័ត៌មានសំខាន់ៗ។

កម្ពុជាក៏មានវឌ្ឍនភាពមួយចំនួនក្នុងការអនុវត្ត អនុសាសន៍ឆ្នាំ២០១៩ របស់គណៈកម្មាធិការ ស៊ី-ដ ដើម្បីធានាលទ្ធភាពទទួលបានការប្រឹក្សា ការធ្វើតេស្ត និងការព្យាបាលមេរោគអេដស៍[107] ដោយស្ម័គ្រចិត្ត និងដោយសម្ងាត់។ កម្ពុជាមានគោលបំណងសម្រេចបានគោលដៅ “៩៥-៩៥-៩៥” ជាសកល ដើម្បីកាត់បន្ថយការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍នៅឆ្នាំ២០៣០។ នៅក្នុងគោលដៅនេះ ៩៥%នៃអ្នករស់នៅជាមួយមេរោគអេដស៍ដឹងពីស្ថានភាពរបស់ពួកគេ ៩៥%នៃអ្នកផ្ទុកមេរោគអេដស៍ បានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ និង៩៥%នៃអ្នកទទួលការព្យាបាលបែបនេះសម្រេចបានការទប់ស្កាត់ការផ្ទុកមេរោគ (viral load suppression)។ ផ្អែកលើរបាយការណ៍សមិទ្ធផលដែលបានផ្សព្វផ្សាយដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) កម្ពុជាបានសម្រេចគោលដៅចំនួនពីរក្នុងចំណោមគោលដៅទាំងនេះគិតត្រឹមខែកញ្ញា ឆ្នាំ២០២៤៖ ៨៩% នៃអ្នកផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពរបស់ពួកគេ។ ជាង៩៨% កំពុងទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ហើយជាង៩៨% បានសម្រេចការទប់ស្កាត់ការផ្ទុកមេរោគ។[108] NCHADS បានរាយការណ៍បន្ថែមថា មនុស្សជាង២៧០០០នាក់ កំពុងប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ ក្នុងការបង្ការកុំឱ្យឆ្លងមេរោគអេដស៍ (pre-exposure prophylaxis) ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគអេដស៍។

នៅទីបំផុត កម្ពុជាបានចាត់វិធានការមួយចំនួនដើម្បីទប់ស្កាត់ជំងឺមហារីកស្បូន ដូចដែលបានផ្តល់អនុសាសន៍ដោយគណៈកម្មាធិការ ស៊ី-ដ ក្នុងឆ្នាំ២០១៩។[109] មហារីកស្បូនអាចបង្ការបានច្រើនតាមរយៈការចាក់វ៉ាក់សាំងប្រឆាំងនឹងមេរោគឆ្លងតាមការប៉ះពាល់ និងការរួមភេទ Human Papillomavirus (HPV)។ ចាប់ពីខែតុលា ឆ្នាំ២០២៣ ក្រសួងសុខាភិបាល សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋបាលមូលដ្ឋាន បានចាប់ផ្តើមផ្តល់វ៉ាក់សាំងដោយឥតគិតថ្លៃប្រឆាំង HPV ឱ្យក្មេងស្រីអាយុប្រាំបួនឆ្នាំទូទាំងប្រទេសតាមរយៈវគ្គផ្សព្វផ្សាយវ៉ាក់សាំងជាប្រចាំនៅតាមសាលារៀន និងសហគមន៍ ព្រមទាំងសេវាពេញមួយឆ្នាំនៅមណ្ឌលសុខភាព។[110] ការធានាឱ្យបានថាស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុសកម្ពុជាគ្រប់វ័យអាចទទួលបានវ៉ាក់សាំងទាំងនេះរួមជាមួយការទទួលបានព័ត៌មានគ្រប់គ្រាន់ និងការពិនិត្យ HPV ទៀងទាត់នឹងបង្ហាញពីវឌ្ឍនភាពដ៏សំខាន់នៅក្នុងការបង្កា និងដោះស្រាយជំងឺមហារីកស្បូននៅកម្ពុជា។

107 CEDAW Committee, above n 2, para. 39(a).
108 NCHADS (2024) “Achievements of the implementation of the AIDS and STD prevention, care, and treatment program from January to September 2024” [Print only].
109 CEDAW Committee, above n 2, para. 39(d).
110 UNICEF, “Life-saving HPV vaccine introduced nationwide into routine immunization schedule to prevent cervical cancer in Cambodia”, October 5, 2023, online: <https://www.unicef.org/cambodia/press-releases/life-saving-hpv-vaccine-introduced-nationwide-routine-immunization-schedule-prevent>.

## ការថែទាំសុខភាពផ្លូវចិត្ត

ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស រួមបញ្ចូលទាំងអ្នកដែលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បានប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការទទួលសេវាថែទាំសុខភាពផ្លូវចិត្តនៅក្នុងឆ្នាំ២០២៤។ សេវាសុខភាពផ្លូវចិត្តមានភាពខ្វះខាតនៅក្នុងតំបន់ជាច្រើនក្នុងប្រទេស ជាពិសេសនៅតាមតំបន់ជនបទ ដោយមូលដ្ឋានថែទាំសុខភាពភាគច្រើនខ្វះអ្នកមានវិជ្ជាជីវៈសុខភាពផ្លូវចិត្ត ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ។ វប្បធម៌មើលស្រាលជុំវិញបញ្ហាសុខភាពផ្លូវចិត្ត ការភ័យខ្លាចអំពីការមាក់ងាយ ឧបសគ្គ និងសម្ពាធហិរញ្ញវត្ថុក្នុងការផ្តល់អាទិភាពលើតម្រូវការមូលដ្ឋានផ្សេងទៀតជាជាងសុខភាពផ្លូវចិត្ត ក៏បានរារាំងស្ត្រី និងក្មេងស្រីជាច្រើននាក់មិនឱ្យទទួលបានការថែទាំ។ ការណ៍នេះបានរួមចំណែកធ្វើឱ្យក្លាយទៅជាវដ្តនៃតម្រូវការសុខភាពផ្លូវចិត្តមិនត្រូវបានដោះស្រាយ ហើយធ្វើឱ្យធ្ងន់ធ្ងរបន្ថែមទៀតចំពោះបញ្ហាប្រឈមផ្សេងទៀត ដែលស្ត្រី និងក្មេងស្រីជួបប្រទះពេញមួយជីវិតរបស់ពួកគេ។

ក្នុងឆ្នាំ២០២៤ អង្គការលើកកម្ពស់គុណភាពជីវិត (WELL-Wellbeing Advancement) បានធ្វើការស្រាវជ្រាវផ្ទៃក្នុង ស្តីពីសុខុមាលភាពយុវជន។[111] ការសិក្សារួមទាំងនិស្សិតសាកលវិទ្យាល័យ១៥០នាក់ មកពីខេត្តផ្សេងៗដែលកំពុងសិក្សានៅទីក្រុងភ្នំពេញ។ ការសិក្សានេះបានរកឃើញថា អ្នកចូលរួម៥៧% បានរាយការណ៍អំពីបញ្ហាសុខភាពរាងកាយ។ អ្នកចូលរួម៤៩% បានរាយការណ៍អំពីភាពតានតឹងផ្លូវចិត្ត ការថប់បារម្ភ និងជំងឺធ្លាក់ទឹកចិត្ត និងអ្នកចូលរួម៥១% បានរាយការណ៍អំពីការខ្វល់ខ្វាយអំពីហិរញ្ញវត្ថុ។ យុវជនម្នាក់ក្នុងចំណោមប្រាំនាក់ បានរាយការណ៍អំពីការជួបប្រទះបញ្ហាប្រឈមនឹងបញ្ហាសុខុមាលភាពលើសពីមួយ។ ការសិក្សានេះបានរំលេចពីភាពខុសគ្នានៃសក្តានុពលរវាងយេនឌ័រ ដែលមានបទពិសោធន៍សុខភាពផ្លូវចិត្តៈ ៥៦%នៃស្ត្រី និងក្មេងស្រីបានរាយការណ៍អំពីការថប់បារម្ភដោយប្រៀបធៀបនឹង៤៥%នៃបុរស និងក្មេងប្រុស។

អង្គការ WELL ក៏បានទទួលរបាយការណ៍ពីក្រុមសន្សំប្រាក់នារី (Lady Saving Group) ជាបណ្តាញស្ត្រីចម្រុះដែលបង្ហាញពីការកើនឡើងបញ្ហាប្រឈមសុខភាពផ្លូវចិត្ត ក្នុងចំណោមស្ត្រីម្ចាស់សហគ្រាសមីក្រូខ្នាតតូច និងមធ្យម។ ទាំងសហគ្រិនវ័យក្មេង និងស្ត្រីបានលើកឡើងពីលទ្ធភាពមានកម្រិតទទួលបានសេវាសុខភាពផ្លូវចិត្តដែលមានតម្លៃសមរម្យ និងការមើលស្រាលជុំវិញសុខភាពផ្លូវចិត្ត ដែលជាឧបសគ្គសំខាន់ក្នុងការស្វែងរកការគាំទ្រ។

ការដោះស្រាយតម្រូវការសុខភាពផ្លូវចិត្តរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស នៅកម្ពុជា រួមបញ្ចូលទាំងអ្នកដែលទទួលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺមានសារៈសំខាន់ណាស់។ ការធ្វើដូច្នេះ ត្រូវការមិនត្រឹមតែការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសេវាសុខភាពផ្លូវចិត្ត និងការគាំទ្រផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែត្រូវធ្វើការកាន់តែខ្លាំងក្លា ដើម្បីដោះស្រាយការវាយតម្លៃបែបអវិជ្ជមានផងដែរ។ ការស្រាវជ្រាវបន្ថែមស្តីពីចំណុចប្រសព្វនៃសុខភាពផ្លូវចិត្ត យេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា ក៏ចាំបាច់ផងដែរសម្រាប់ការបង្កើតអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដែលបង្កើតភាពខុសគ្នាប្រកបដោយអត្ថន័យនៅក្នុងជីវិតរបស់ស្ត្រី និងក្មេងស្រី។

---

111 WELL (2024) "Internal Research on Wellbeing of Youth and SME Women Owners".



# ការរើសអើងផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ

អំពើហិង្សា និងការរើសអើងដោយផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័របានបន្តនៅកម្ពុជា ក្នុងឆ្នាំ២០២៤។ ក្នុងខែមករា ឆ្នាំ២០២៤ តំណាងរដ្ឋាភិបាលបានទទួលស្គាល់ថា ការរើសអើងបង្ហាញកាន់តែច្បាស់នៅកម្ពុជា។ តំណាងរូបនេះបានលើកឡើងថាការរើសអើង ជាមូលដ្ឋានក្នុងការពន្យាពេលការធ្វើឱ្យស្របច្បាប់នូវអាពាហ៍ពិពាហ៍ភេទដូចគ្នា ដោយកត់សម្គាល់ពីសក្តានុពលនៃសមភាពអាពាហ៍ពិពាហ៍ក្នុងការបង្កឱ្យមាន "ការមិនឯកភាពនៅក្នុងសង្គមយើង"។[112] ការខកខានរបស់កម្ពុជាក្នុងការធ្វើឱ្យស្របច្បាប់នូវសមភាពអាពាហ៍ពិពាហ៍ មានការចាក់ឫសជាជាងដោះស្រាយទស្សនៈរើសអើងក្នុងសង្គម។ ការស្រាវជ្រាវក្នុងឆ្នាំ២០២៣ បង្ហាញថាប្រជាជនកម្ពុជាជាងពាក់កណ្តាល (៥៧%) គាំទ្រសមភាពអាពាហ៍ពិពាហ៍។[113]

CHEC បានស្រាវជ្រាវពីបញ្ហាប្រឈមដែល LGBTIQ+ បានជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ និងជីវិតក្នុងសង្គមរបស់ពួកគេក្នុងឆ្នាំ២០២៤។[114] ការស្រាវជ្រាវរួមទាំងកម្រងសំណួរពាក់កណ្តាលរចនាសម្ព័ន្ធ (Semi-structured questionnaire) ការពិភាក្សាតាមក្រុម (FGD) និងការសម្ភាសន៍ផ្ទាល់ម្នាក់ៗ (KII) ជាមួយយុវជន LGBTIQ+ ចំនួន២០៨នាក់ ឪពុកម្តាយ១២៧នាក់ អាជ្ញាធរមូលដ្ឋានចំនួន៤២នាក់ និងបុគ្គលិកសុខាភិបាលចំនួន៣៦នាក់ នៅក្នុងខេត្តចំនួន៤។

112 Seoung Nimol, "Gov't Studies Same-Sex Marriage Law Amid Prejudices, Risk of Breaking Tradition", CamboJA News, January 1, 2024, online: <https://cambojanews.com/govt-studies-same-sex-marriage-law-amid-prejudices-risk-of-breaking-tradition/>.

113 Pew Research Center, "Across Asia, views of same-sex marriage vary widely", November 27, 2023, online: <https://www.pewresearch.org/short-reads/2023/11/27/across-asia-views-of-same-sex-marriage-vary-widely/>.

114 CHEC Cambodia (2024) "LGBTIQ Challenges and Problems in their Daily Living and Social Communication".

ការសិក្សានេះបានរកឃើញថា ប្រហែលមួយភាគបួននៃយុវជន LGBTIQ+ (២៨%) បានរាយការណ៍ថា ពួកគេមិនមានផាសុកភាពនៅក្នុងសហគមន៍របស់ពួកគេទេ និង(២៤%)មិនមានផាកសុខភាពជាមួយគ្រួសារ។ អ្នកចូលរួម LGBTIQ+ បានរាយការណ៍អំពីការរំលោភបំពានដោយពាក្យសំដីអារម្មណ៍មើលងាយ ការមាក់ងាយ និងការផាត់ចេញក្នុងសហគមន៍របស់ពួកគេ។ ពួកគេក៏បានរាយការណ៍អំពីការរំលោភបំពានដោយពាក្យសំដី និងអំពើហិង្សាលើរាងកាយក្នុងគ្រួសារ រួមទាំងការវាយដំ ការបណ្តេញចេញពីផ្ទះដោយបង្ខំ និងការរៀបការដោយបង្ខំ។ តិចជាងពាក់កណ្តាលនៃឪពុកម្តាយ (៤៦%) ដែលបានចូលរួមរាយការណ៍ថា ពួកគេពេញចិត្តក្នុងការទទួលយកកូន LGBTIQ+ របស់ពួកគេ។

ជាងពាក់កណ្តាលនៃសិស្សានុសិស្ស LGBTIQ+ ក៏បានរាយការណ៍អំពីការមាក់ងាយនៅក្នុងសាលារៀន (៥៣%) និងការបៀតបៀនផ្លូវភេទនៅស្ថាប័នអប់រំ ឬកន្លែងធ្វើការ (៥៧%) ដូចជាការបៀតបៀនដោយពាក្យសំដី ការលេងសើចបែបអាសអាភាស និងការប៉ះដែលមិនចង់បាន។ ស្ទើរតែមួយភាគបួននៃអ្នកចូលរួម LGBTIQ+ (២៤%) បានរាយការណ៍អំពីការរើសអើងក្នុងកន្លែងការងារ។ អាជ្ញាធរមូលដ្ឋានភាគច្រើនបានកំណត់សម្គាល់ការរើសអើងក្នុងកន្លែងការងារ (៦៩%) ការរើសអើងក្នុងស្ថាប័ន (៦២%) និងអំពើហិង្សា (៥២%) ជាបញ្ហាប្រឈមចំពោះក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+)។ ទោះបីយ៉ាងនេះក្តី យុវជន LGBTIQ+ នៅក្នុងក្រុម FGD បានរាយការណ៍ថា ពេលខ្លះអាជ្ញាធរមូលដ្ឋានមិនយកចិត្តទុកដាក់ចំពោះបញ្ហារបស់ពួកគេដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

បើនិយាយពីភាពវិជ្ជមានវិញ អ្នកចូលរួម LGBTIQ+ ភាគច្រើន (៨៤%) បានយល់ស្របថាពួកគេមានលទ្ធភាពទទួលបានសេវាចាំបាច់ដូចជា ការថែទាំសុខភាព ការអប់រំ និងសន្តិសុខសង្គម។ ក្នុងចំណោមអ្នកដែលបានទទួលសេវាបែបនេះ ភាគច្រើន (៥៧%) បានរាយការណ៍ថា មិនមានចន្លោះប្រហោងជាដុំកំភួននៅក្នុងសេវាកម្មទាំងនេះទេ ទោះបីជាអ្នកផ្សេងទៀតបានរាយការណ៍អំពីបញ្ហាប្រឈម ដែលកើតមកពីគុណភាពសេវាទាប ការផ្តល់សេវាយឺតយ៉ាវ ការខ្វះការយកចិត្តទុកដាក់ និងការថែទាំមិនគ្រប់គ្រាន់ក៏ដោយ។ អ្នកចូលរួមក៏បានរាយការណ៍ថា បុគ្គលិកមណ្ឌលសុខភាពមួយចំនួនបានបំពានដោយពាក្យសំដី ឬមិនសូវចាប់អារម្មណ៍ក្នុងការស្តាប់ក្តីកង្វល់របស់ពួកគេ។ (៣៣%) នៃបុគ្គលិកសុខាភិបាលបានកំណត់សម្គាល់ថា សហគមន៍ LGBTIQ+ មិនមកទទួលយកសេវាសុខភាពដែលផ្តល់ឲ្យនេះទេ និង(២៥%) ផ្សេងទៀតមកទទួលសេវាមិនទៀងទាត់ ដែលជាបញ្ហាប្រឈមចំពោះក្រុមសហគមន៍ LGBTIQ+។

ការស្រាវជ្រាវដោយ CHEC បានរកឃើញអនុសាសន៍ជាគន្លឹះ ដើម្បីដោះស្រាយការរើសអើងនេះ រួមទាំងការកសាងការយល់ដឹង និងការអប់រំសាធារណៈអំពីសិទ្ធិរបស់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ការលើកកម្ពស់ និងការជួយរាយការណ៍អំពីការរើសអើង និងការឃាំពីបង្កើនការយកចិត្តទុកដាក់ និងភាពតំណាង ហើយធ្វើឱ្យល្អប្រសើរនូវច្បាប់ និងគោលនយោបាយដើម្បីការពារពួកគេពីការរើសអើង។

# ការអប់រំ

## ការបោះបង់ការសិក្សា

ទោះបីកម្ពុជាមានវឌ្ឍនភាពក្នុងការសម្រេចបានសមភាពយេនឌ័រក្នុងវិស័យអប់រំក៏ដោយ ក៏ការខិតខំបន្តបន្ទាប់ត្រូវការចាំបាច់ដើម្បីរក្សាវឌ្ឍនភាព និងកាត់បន្ថយការបោះបង់ការសិក្សា។ គណៈកម្មាធិការ ស៊ីដ-ដ បានផ្តល់អនុសាសន៍ក្នុងឆ្នាំ២០១៩ ថាកម្ពុជាគួរបំបាត់ឧបសគ្គ ឬកាត់បន្ថយបញ្ហាដែលរារាំងក្មេងស្រីមិនឱ្យនៅបន្តការសិក្សាថ្នាក់វិទ្យាល័យ និងមហាវិទ្យាល័យ។[115]

គិតត្រឹមឆ្នាំ២០២២-២០២៣ អត្រាបញ្ចប់ការសិក្សាថ្នាក់បឋម គឺ៨៩%សម្រាប់ក្មេងស្រី និង៨៥%សម្រាប់ក្មេងប្រុស។ ទោះជាយ៉ាងណាក៏ដោយ អត្រាបោះបង់ការសិក្សាថ្នាក់បឋមអំឡុងពេលដូចគ្នា គឺ៩.៥% សម្រាប់ក្មេងស្រី លើសពីអត្រាបោះបង់ការសិក្សាសូម្បីតែអំឡុងពេលជំងឺកូវីដ១៩ បើប្រៀបធៀបនឹង៥.៥% សម្រាប់ក្មេងប្រុស។ អត្រាបោះបង់ការសិក្សាកម្រិតមធ្យម សិក្សាបឋមភូមិ គឺ១៧%សម្រាប់ក្មេងស្រី និង១៩%សម្រាប់ក្មេងប្រុស។ អត្រាចុះឈ្មោះចូលរៀនសរុបថ្នាក់ឧត្តមសិក្សា គឺ១៩%សម្រាប់ស្ត្រី ដែលមានអាយុពី១៨ដល់២២ឆ្នាំ និង១៦.៥%សម្រាប់បុរស។[116]

ពេញមួយឆ្នាំ២០២៤ អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍ (CCDO) ជាមួយអង្គការរចនា (Rachana) និងអង្គការជំនួយអភិវឌ្ឍន៍ និងសន្តិភាព (PDAO) បានស្រាវជ្រាវអំពីការបោះបង់ការសិក្សានៅខេត្តតាកែវ។[117] ការស្រាវជ្រាវនេះមានគោលបំណងបញ្ចូលអ្នកចូលរួមដែលជាគ្រូបង្រៀនចំនួន៩២នាក់ (ស្ត្រី៤០%) កុមារ និងយុវជនចំនួន៩២នាក់ (ក្មេងស្រី៥០%) និងឪពុកម្តាយ ឬអាណាព្យាបាលចំនួន៩២នាក់ (៦០%នៃឪពុកម្តាយ ឬអាណាព្យាបាលមានកូនដែលបានបោះបង់ការសិក្សា)។ របាយការណ៍បឋមបានលើកឡើងពីកត្តាដែលរួមចំណែកដល់ការបោះបង់ការសិក្សា។ កត្តាដែលរួមចំណែកមានដូចជាភាពក្រីក្រ បំណុលមីក្រូហិរញ្ញវត្ថុ និងបំណុលឯកជន តម្រូវការឱ្យកូនជួយរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ ការធ្វើចំណាកស្រុក ជម្លោះក្នុងគ្រួសារ ជំងឺឬមរណភាពរបស់សមាជិកគ្រួសារ និងលទ្ធផលសិក្សាអន់ដោយសារកង្វះសម្ភារៈសិក្សា និងមូលនិធិសម្រាប់ថ្លៃសិក្សាឯកជន។ ការសិក្សាស្រាវជ្រាវនេះក៏បានរកឃើញកុមារ៤នាក់ ក្នុងនោះមានក្មេងស្រី៣នាក់ បានបោះបង់ការសិក្សាពីព្រោះការដាក់ទណ្ឌកម្មដោយគ្រូ ឬត្រូវបានរើសអើងដោយសារស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ខ្លួន។

---

[115] CEDAW Committee, above n 2, para. 35(a).
[116] Ministry of Education, Youth and Sport (2024) "Education Strategic Plan 2024-2028", online:
[117] CCDO, "Assessment on Children Dropout School: Child Rights for Education".

ការស្រាវជ្រាវដោយអង្គការនារីដើម្បីសន្តិភាពក៏បានរកឃើញថា ស្ត្រី និងក្មេងស្រីជនជាតិភាគតិច ដូចជាចាមខ្មែរក្រោម ជនជាតិភាគតិចវៀតណាម និងស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច បានប្រឈមមុខនឹងឧបសគ្គចំពោះការអប់រំដោយផ្អែកលើការរើសអើងជាច្រើនទម្រង់។[118] គួរកត់សម្គាល់ថាអ្នកចូលរួម២៤% មិនទាន់បានបញ្ចប់ការអប់រំណាមួយទេ ហើយអ្នកឆ្លើយតប៣៧% បានត្រឹមតែបញ្ចប់ការអប់រំថ្នាក់បឋមប៉ុណ្ណោះ។ មានតែអ្នកឆ្លើយតប១០%ប៉ុណ្ណោះ ដែលបានបញ្ចប់ថ្នាក់សាកលវិទ្យាល័យ។

ក្នុងពេលប្រឈមមុខនឹងសម្ពាធហិរញ្ញវត្ថុក្នុងគ្រួសារ ការស្រាវជ្រាវបានរកឃើញថាការអប់រំរបស់ក្មេងប្រុសត្រូវបានចាត់ទុកថាសំខាន់ជាងការអប់រំរបស់ក្មេងស្រី។ អ្នកចូលរួមស្ទើរតែពាក់កណ្តាលបានប្រឈមមុខនឹងការយាយី និងការរើសអើងបន្ថែមទៀតនៅសាលារៀនដោយផ្អែកលើសាសនា ការស្លៀកពាក់ ឬដោយសារការយល់ឃើញថាពួកគេជាជនគ្មានរដ្ឋ ឬឋានៈជាពលរដ្ឋរបស់ពួកគេ។ អ្នកចូលរួមមួយចំនួនក៏បានរាយការណ៍អំពីឧបសគ្គក្នុងទទួលបានការអប់រំដោយផ្អែកលើការរើសអើង ដែលផ្សាភ្ជាប់ទៅនឹងការប្រើប្រាស់ភាសខុសគ្នា។

## ការប្រែប្រួលអាកាសធាតុ និងការអប់រំក្មេងស្រី

លទ្ធភាពទទួលបានការអប់រំរបស់ក្មេងស្រីកម្ពុជា ត្រូវបានគំរាមកំហែងដោយការប្រែប្រួលអាកាសធាតុ។ នៅឆ្នាំ២០១៩ គណៈកម្មាធិការ ស៊ី-ដ បានផ្តល់អនុសាសន៍ថា កម្ពុជាគួរធានាឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ស្ត្រី ក្នុងការអភិវឌ្ឍគោលនយោបាយ និងផែនការសកម្មភាពនៃការប្រែប្រួលអាកាសធាតុ ហើយដាក់បញ្ចូលយ៉ាងច្បាស់នូវទស្សនៈយេនឌ័រ នៅក្នុងការឆ្លើយតបទាំងនេះ។[119] គណៈកម្មាធិការសិទ្ធិកុមារបានទទួលស្គាល់បន្ថែមទៀតនៅឆ្នាំ២០២៣ថា ការអប់រំគឺជាឧបករណ៍សំខាន់ក្នុងការការពារសិទ្ធិកុមារ និងបរិស្ថាន។ សិទ្ធិទទួលបានការអប់រំត្រូវបានគំរាមកំហែងដោយការខូចខាតបរិស្ថាន និងការរិចរិលបរិស្ថានមានផលប៉ះពាល់ដាក់លាក់លើយេនឌ័រ ដូចជាការកើនឡើងនៃបន្ទុកក្នុងគ្រួសារ និងហិរញ្ញវត្ថុដែលរួមចំណែកដល់ការបោះបង់ការសិក្សា។[120]

នៅឆ្នាំ២០២៤ អង្គការបួនស្ថាប័ន បានបោះពុម្ពរបាយការណ៍រួមមួយស្តីពីរបៀបដែលការប្រែប្រួលអាកាសធាតុប៉ះពាល់ដល់លទ្ធភាពទទួលបានសិទ្ធិស្មើគ្នា នៃសិទ្ធិក្មេងស្រីក្នុងការអប់រំនៅកម្ពុជា។ របាយការណ៍នេះបានសិក្សាយ៉ាងប្រុងប្រយ័ត្ននូវ ព្រឹត្តិការណ៍វិវត្តន៍ថ្មីៗ អក្សរសាស្ត្រ និងទស្សនៈរបស់ក្មេងស្រីកម្ពុជាចំនួន១៥នាក់ ដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ជាពិសេសដោយការប្រែប្រួលអាកាសធាតុ។[121]

118 Women Peace Makers, above n 13.
119 CEDAW Committee, above n 2, para. 43(a)-(b).
120 Committee on the Rights of the Child, "General comment No. 26 (2023) on children's rights and the environment, with a special focus on climate change", CRC/C/GC/26, August 22, 2023, online: <https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CRC%2FC%2FGC%2F26&Lang=en>.
121 CRC-Cambodia, Child and Youth-Led Networks (CYLNs), ActionAid International Cambodia (AAC) and Live & Learn Cambodia (2024) "Civil Society Input from Cambodia", online: <https://www.ohchr.org/sites/default/files/documents/issues/education/cfis/res-54-19/subm-how-climate-change-cso-civil-society-input-from-cambodia.docx>.

របាយការណ៍នេះបានរកឃើញថា ការប្រែប្រួលអាកាសធាតុបានបង្កើនចំនួនការងារក្នុងគ្រួសារដែលធ្វើដោយក្មេងស្រី ជាពិសេសកូនស្រីច្បង។ ទឹកជំនន់ រលកកំដៅ និងគ្រោះរាំងស្ងួតញឹកញាប់ក៏អាចរួមចំណែកដល់ការបោះបង់ការសិក្សារបស់ក្មេងស្រី ដោយការរំខានដល់ការអប់រំផងដែរ ការធ្លាក់ចុះនៃលំនឹងជីវភាពគ្រួសារ ការប៉ះពាល់អវិជ្ជមានដល់សុខភាពផ្លូវចិត្តក្នុងរយៈពេលខ្លី និងរយៈពេលវែង ប៉ះពាល់ទឹកប្រើប្រាស់ អនាម័យ និងបរិក្ខារអនាម័យនៅក្នុងសាលារៀន និងគុណភាពផ្លូវថ្នល់ និងការដឹកជញ្ជូនទៅកាន់សាលារៀន។

ទោះបីជាមានផលប៉ះពាល់ទូទៅទាំងនេះក៏ដោយ ក៏ការខ្វះខាតគុណភាពនៃការអប់រំនៅកម្ពុជា បានធ្វើឱ្យក្មេងស្រីមានការយល់ដឹងតិចតួចអំពីសិទ្ធិ បញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ រួមផ្សំជាមួយនឹងបទដ្ឋានយេនឌ័រ និងកត្តាផ្សេងទៀត ស្ថានភាពនេះបានធ្វើឱ្យក្មេងស្រីត្រូវបានផាត់ចេញពីដំណើរការធ្វើការសម្រេចចិត្តទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅគ្រប់កម្រិតទាំងអស់។ ទោះបីកម្ពុជាបានបង្កើតគោលនយោបាយ និងគោលការណ៍ណែនាំច្រើនដើម្បីធ្វើឱ្យល្អប្រសើរការបង្រៀនអំពីបរិស្ថាននៅក្នុងសាលារៀន និងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ការមានទូរធនធានគ្រប់គ្រាន់ គឺចាំបាច់សម្រាប់ការអនុវត្តប្រកបដោយអត្ថន័យ។

អង្គការទាំងបួនស្ថាប័ននេះ បានស្នើឱ្យដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយធានាឱ្យមានមូលនិធិគ្រប់គ្រាន់ពីថវិកាជាតិ ដែលធានាថាការប្រមូលទិន្នន័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុគឺត្រូវគិតគូរអំពីស្ថានភាពរបស់ក្មេងស្រី និងបែងចែកលម្អិតនៅក្នុងក្រុមកុមារ ការទទួលស្គាល់ផ្លូវច្បាប់ថា កុមារមានសិទ្ធិទទួលបានបរិស្ថានស្អាតមានសុខភាពល្អ និងប្រកបដោយចីរភាព រួមទាំងសិទ្ធិរបស់កុមារក្នុងការទទួលបានព័ត៌មាន និងចូលរួមក្នុងការសម្រេចចិត្ត ការកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀនប្រកបដោយសុវត្ថិភាព សុខភាព ភាពធន់ ហើយឆ្លើយតបនឹងយេនឌ័រ ព្រមទាំងធ្វើឱ្យកម្មវិធីសិក្សាសម្រាប់ការអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុស្របជាមួយឧត្តមានុវត្តន៍អន្តរជាតិ។

# ភាពមិនមានរដ្ឋ

ភាពមិនមានរដ្ឋ បានបន្តប៉ះពាល់ដល់សិទ្ធិស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស នៅកម្ពុជានៅក្នុងឆ្នាំ២០២៤។ ក្នុងឆ្នាំ២០១៩ គណៈកម្មាធិការ ស៊ី-ដ បានអំពាវនាវឱ្យកម្ពុជាធានាលទ្ធភាពទទួលបានសញ្ជាតិសម្រាប់គ្រប់ស្ត្រីដែលមានសិទ្ធិនឹងទទួល ជាពិសេសស្ត្រីដើមកំណើតវៀតណាម និងស្ត្រីខ្មែរក្រោម និងធានាលទ្ធភាពទទួលបានឯកសារអត្តសញ្ញាណ ការចុះបញ្ជីកំណើត ការអប់រំ ការងារ ការថែទាំសុខភាព និងលំនៅដ្ឋាន។[122]

[122] CEDAW Committee, above n 2, para. 33(a)-(b).

ក្នុងឆ្នាំ២០២៤ អង្គការនារីដើម្បីសន្តិភាព និងសញ្ជាតិសម្រាប់គ្រប់គ្នា បានបោះពុម្ពផ្សាយការសិក្សាមួយដោយពិនិត្យមើលវិសាលភាព និងលក្ខខណ្ឌនៃចំនួនប្រជាជនដែលមិនមានរដ្ឋជាក់លាក់ និងអ្នកដែលប្រឈមនឹងហានិភ័យដោយសារភាពមិនមានរដ្ឋនៅកម្ពុជា។ ការសិក្សាបានកំណត់អ្នកបានមកតាំងលំនៅក្នុងរយៈពេលយូរ ដែលមានដើមកំណើតវៀតណាម ខ្មែរក្រោមមួយចំនួន និងជនភៀសខ្លួនថាជាអ្នកដែលប្រឈមនឹងហានិភ័យច្រើនបំផុត។[123] ការសិក្សានេះបានរកឃើញថា កម្ពុជាមិនទទួលស្គាល់ជាផ្លូវការថាមានប្រជាជនដែលមិនមានរដ្ឋនៅក្នុងប្រទេសទេ។ ជាលទ្ធផល កម្ពុជាមិនបានប្រមូលទិន្នន័យពាក់ព័ន្ធណាមួយឡើយ ដែលនាំឲ្យភាពមិនមានរដ្ឋ គឺមិនច្បាស់លាស់។ ការសិក្សានេះបានរកឃើញថា អ្នកដែលបានមកតាំងលំនៅក្នុងរយៈពេលយូរ ដែលមានដើមកំណើតវៀតណាម ជាញឹកញាប់មិនមានភស្តុតាងបញ្ជាក់សញ្ជាតិខ្មែរ ឬវៀតណាម ទោះបីជាមានការទាមទារសញ្ជាតិខ្មែរក៏ដោយ ហើយជាញឹកញាប់ត្រូវបានចាត់ទុកដោយអាជ្ញាធរថាជា “ជនជាតិវៀតណាម”។ ការសិក្សានេះបានរកឃើញបន្ថែមទៀតថាប្រជាពលរដ្ឋខ្មែរក្រោមមួយចំនួនខ្វះភស្តុតាងបញ្ជាក់សញ្ជាតិខ្មែរ ដោយសារតម្រូវការរដ្ឋបាល បើទោះបីជាពួកគេទាមទារសិទ្ធិជាពលរដ្ឋក៏ដោយ។

ការសិក្សានេះបានរកឃើញថា ភាពមិនមានរដ្ឋប៉ះពាល់ដល់លទ្ធភាពទទួលបានសិទ្ធិ សេវាកម្ម និងការការពារជាមូលដ្ឋាន ដូចជាការចុះបញ្ជីសំបុត្រកំណើត និងអាពាហ៍ពិពាហ៍ ការអប់រំនៅសាលារដ្ឋ ការថែទាំសុខភាព និងការងារ សេរីភាពក្នុងការដើរហើរ កម្មសិទ្ធិដីធ្លី និងសន្តិសុខដីធ្លី ការចូលរួមនយោបាយ លទ្ធភាពទទួលបានយុត្តិធម៌ និងសេវាសង្គម ដូចជាកម្មវិធីផ្តល់បណ្ណសមធម៌។ ការសិក្សានេះបានរកឃើញថា ឧបសគ្គចំពោះការចុះបញ្ជីកំណើត និងគោលនយោបាយចូលសញ្ជាតិដែលមិនមានប្រសិទ្ធភាព ដែលនាំឲ្យភាពមិនមានរដ្ឋនៅតែបន្តពីមួយជំនាន់ទៅមួយជំនាន់។

ការសិក្សានេះផ្តល់អនុសាសន៍ថា កម្ពុជាគួរមានចំណាត់ការកាត់បន្ថយ និងបង្ការភាពមិនមានរដ្ឋដោយទទួលស្គាល់ជាផ្លូវការនូវវត្តមានរបស់ពួកគេ គួរប្រមូលទិន្នន័យសាធារណៈអំពីប្រជាជនដែលរងផលប៉ះពាល់ ដោយដោះស្រាយការរើសអើងក្នុងចំណោមតួអង្គសាធារណៈ និងតួអង្គពាក់ព័ន្ធទាំងអស់ ធានាថាមិនមានការរើសអើងក្នុងការទទួលបានការចុះបញ្ជីកំណើត និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ផ្តល់ការអប់រំជាសកល ដោយឥតប្រកាន់ពីឯកសារអត្តសញ្ញាណ។ កម្ពុជាគួរអនុវត្តឱ្យកាន់តែប្រសើរនូវគោលនយោបាយដែលមានស្រាប់ ដូចជាគោលនយោបាយទាក់ទងនឹងបណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងអនុវត្តមាគ៌ាមិនរើសអើងក្នុងនាមកម្ពុជាជាប្រទេសប្រកាន់អព្យាក្រឹត និងការផ្តល់សញ្ជាតិ។

123 Women Peace Makers and Nationality for All (2024) “Mapping Statelessness in Cambodia: A Review of the Current Context and Conditions”, online: <https://wpmcambodia.org/wp-content/uploads/2025/02/2024_Mapping_Statelessness_in_Cambodia.pdf>.

# សេរីភាពខាងជំនឿសាសនា

ក្នុងឆ្នាំ២០២៤ អង្គការនារីដើម្បីសន្តិភាព បានធ្វើការវិភាគអំពីស្ថានភាពនៃសេរីភាពខាងជំនឿសាសនានៅកម្ពុជា។[124] ការវិភាគនេះបានរកឃើញថា សេរីភាពខាងសាសនា ជាពិសេសសម្រាប់ជនជាតិភាគតិចខាងសាសនា ត្រូវបានគំរាមកំហែងជាញឹកញាប់ ទោះបីជាមានការការពារដោយរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងទៀតក៏ដោយ។ ជាពិសេស អ្នកចូលរួមជាគ្រីស្តសាសនិក និងមូស្លីម បានរាយការណ៍អំពីការរើសអើង ការយាយីនិងការរឹតត្បិតលើសកម្មភាពសាសនារបស់ពួកគេ។ សហគមន៍ជនជាតិដើមភាគតិចក៏ប្រឈមនឹងការរឹតត្បិតក្នុងការប្រតិបត្តជំនឿរបស់ពួកគេផងដែរ ដោយសារការបំផ្លាញទីតាំង និងទីសក្ការៈ។ ស្ត្រីមកពីក្រុមសាសនាជនជាតិភាគតិចក៏អាចប្រឈមមុខនឹងការរើសអើងច្រើនទម្រង់ក្នុងសង្គម ដែលប៉ះពាល់ដល់លទ្ធភាពទទួលបានការអប់រំ និងការងារ។ បញ្ហាប្រឈមកើតចេញមួយផ្នែកពីរដ្ឋាភិបាលនិយមពុទ្ធសាសនាហីនយាន ដែលត្រូវបានប្រតិបត្តិដោយប្រជាជនប្រមាណ៩៥%។

ការវិភាគនេះបានរកឃើញបន្ថែមទៀតថា ជំនឿលើសាសនាផ្សេងៗគឺបានជំរុញឲ្យមានវិសមភាពយេនឌ័រដោយស្ត្រីត្រូវបានរារាំងពីតួនាទីដឹកនាំសាសនាមួយចំនួន និងក្លាយជាកម្មវត្ថុនៃរើសអើង។ ផលប៉ះពាល់នៃការបដិបត្តិសាសនាមួយចំនួនក៏អាចប៉ះពាល់ការទទួលស្គាល់ និងបន្តការរើសអើងដែលប្រឈមមុខដោយក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ផងដែរ។

របាយការណ៍នេះផ្តល់អនុសាសន៍អំពីការការពារផ្នែកច្បាប់ និងលើកកម្ពស់ការយល់ដឹងសម្រាប់ការប្រព្រឹត្តលើក្រុមសាសនាទាំងអស់ដោយស្មើភាពគ្នា ដោះស្រាយបញ្ហាយេនឌ័រ និងការរើសអើងទម្រង់ផ្សេងទៀតនៅក្នុងបរិបទសាសនា កិច្ចសន្ទនាអន្តរជំនឿសាសនាកាន់តែល្អប្រសើរ ការការពារតំបន់ជនជាតិដើមភាគតិច និងការគាំទ្រស្ត្រី និងក្រុមអ្នកដែលគេមិនបានយកចិត្តទុកដាក់ ដើម្បីចូលរួមក្នុងជីវិតសាសនា និងសាធារណៈ។



[124] Women Peace Makers (2024) "Diving Deep Into Cambodia's Freedom of Religion and Belief", online: <https://wpmcambodia.org/project/diving-deep-into-cambodias-freedom-of-religion-and-belief/>.

# ស្ត្រី និងក្មេងស្រីដែលជាប់ឃុំឃាំង

ប្រព័ន្ធពន្ធនាគាររបស់កម្ពុជា នៅតែបានបន្តប្រឈមមុខនឹងភាពចង្អៀតណែនខ្លាំង នៅក្នុងឆ្នាំ២០២៤។ ទោះបីយ៉ាងនេះក្តី កម្ពុជានៅតែមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តអនុសាសន៍ឆ្នាំ២០១៩ របស់គណៈកម្មាធិការ ស៊ី-ដ ដើម្បីកាត់បន្ថយចំនួនស្ត្រីជាប់នៅក្នុងការឃុំឃាំង ដោះស្រាយភាពចង្អៀតណែន និងឫសគល់នៃបទល្មើស និងធ្វើឱ្យល្អប្រសើរនូវស្ថានភាព និងសេវាកម្មនៅក្នុងមន្ទីរឃុំឃាំង។[125]

អង្គការលីកាដូឃ្លាំមើលពន្ធនាគារចំនួន១៩ ក្នុងចំណោមពន្ធនាគារចំនួន២៩ និងមណ្ឌលអប់រំកែប្រែរបស់កម្ពុជា។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៤ ស្ត្រី និងក្មេងស្រីចំនួន២៨៣៧នាក់ ក្នុងចំណោមមនុស្សសរុបប្រហែល ៤៥០០០នាក់ ត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ។ ចំនួនអ្នកជាប់ពន្ធធនាគារនៅក្នុងប្រទេសកម្ពុជានៅតែបន្តកើនឡើង ដោយចំនួនអ្នកជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែត្រូវបានឃ្លាំមើលដោយអង្គការលីកាដូបានកើនឡើង២៣% បើធៀបនឹងឆ្នាំ២០២៣។[126]

ពន្ធនាគារក្នុងពិភពលោក (World Prison Brief) បានចាត់ចំណាត់ថ្នាក់កម្ពុជាជាប្រទេសដែលមានអត្រាអ្នកជាប់ឃុំនៅក្នុងពន្ធនាគារខ្ពស់បំផុតទីពីរនៅលើពិភពលោក ដោយផ្អែកលើទិន្នន័យឆ្នាំ២០២៣។[127] ក្នុងចំណោមពន្ធនាគារទាំង១៩ ដែលអង្គការលីកាដូបានឃ្លាំមើល មានពន្ធនាគារ១៨ ដាក់អ្នកជាប់ឃុំលើសពីចំណុះពន្ធនាគារគិតត្រឹមខែធ្នូ ឆ្នាំ២០២៤ ដោយមានចំណុះភាគច្រើនពី២០០% ទៅ៦៥០%។ ស្ថានភាពចង្អៀតណែនទាំងនេះ បានបង្កើនហានិភ័យនៃជំងឺឆ្លងតាមខ្យល់ដង្ហើមនឹងបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរព្រោះស្ថានភាពចង្អៀត និងគ្មានអនាម័យ។

ក្រុមអ្នកងាយប្រឈមនឹងហានិភ័យ មានដូចជាស្ត្រីមានផ្ទៃពោះ ក្មេងស្រីអនីតិជន និងកុមារដែលរស់នៅជាមួយម្តាយរបស់ពួកគេនៅក្នុងពន្ធនាគារ ហើយជារឿយៗ ពួកគេងាយប្រឈមនឹងការឆ្លងធ្ងន់ធ្ងរជាងគេ។[128] ប្រទេសកម្ពុជាអនុញ្ញាតឱ្យកុមារអាយុក្រោម៣ឆ្នាំរស់នៅជាមួយម្តាយក្នុងពន្ធនាគារ។ ក្នុងឆ្នាំ២០២៤ កុមារ ១០១នាក់ (ក្មេងស្រី៥៧នាក់ និងក្មេងប្រុស ៤៤នាក់) កំពុងរស់នៅជាមួយម្តាយក្នុងពន្ធនាគារ ដែលអង្គការលីកាដូឃ្លាំមើល ហើយស្ត្រី៣២នាក់បន្ថែមទៀតមានផ្ទៃពោះ។ ក្មេងស្រីអនីតិជនសរុបចំនួន៩៧នាក់ដែលមានអាយុចាប់ពី ១៤ទៅ២៨ឆ្នាំ ប៉ុន្តែមានអាយុក្រោម ១៨ឆ្នាំ នៅពេលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស ត្រូវបានជាប់ពន្ធនាគារនៅចុងឆ្នាំ២០២៤។

ស្ថានភាពរស់នៅសម្រាប់ក្រុមទីមួយៗទាំងនេះ អាចមានភាពល្អប្រសើរឡើងភ្លាមៗ ដោយការដោះស្រាយភាពចង្អៀតណែន ដែលត្រូវបានជំរុញដោយការប្រើប្រាស់ជម្រើសជំនួសមានកម្រិតសម្រាប់ការឃុំខ្លួន និងការពឹងផ្អែកជាប្រព័ន្ធលើការឃុំខ្លួនបណ្តោះអាសន្ន។ គួរកត់សម្គាល់ថា ស្ត្រី៧៧% នៅក្នុងពន្ធនាគារដែលឃ្លាំមើលដោយអង្គការលីកាដូ មិនទាន់ត្រូវបានផ្តន្ទាទោស ឬទទួលបានសាលក្រមស្ថាពរនៅឡើយ។

[125] CEDAW Committee, above n 2, para. 45 (a)-(c).
[126] LICADHO, "Cambodia's Capacity Crisis: Overcrowded Prisons and the Need for Reform", February 18, 2025, online: <https://www.licadho-cambodia.org/articles/20250218/198/index.html>.
[127] World Prison Brief, "Highest to Lowest - Occupancy level (based on official capacity)", online: <https://www.prisonstudies.org/highest-to-lowest/occupancy-level?field_region_taxonomy_tid=All>.
[128] See, LICADHO, "Imprisonment Must be the Last Resort for Minors, Mothers With Children", May 31, 2024, online: <https://www.licadho-cambodia.org/pressrelease.php?perm=525>.

# អនុសាសន៍

ចាំបាច់ត្រូវមានវិធានការផ្សេងៗបន្តបន្ទាប់ដើម្បីធានាបានការលើកកម្ពស់ ការការពារ និងលទ្ធភាពទទួលបានពេញលេញនូវសិទ្ធិរបស់ស្ត្រី ក្មេងស្រី និងអ្នកមិនកំណត់អត្តសញ្ញាណភេទស្រី ឬប្រុស ស្របតាមអនុសញ្ញា ស៊ីដ និងសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការ ស៊ីដ។ ទោះជាយ៉ាងនេះក្តី វិធានការជាអាទិភាពខាងក្រោមនេះ ត្រូវបានស្នើទៅរដ្ឋាភិបាលកម្ពុជា៖

- ធ្វើការនៅគ្រប់កម្រិតនៃសង្គម និងស្ថាប័ននានា ដើម្បីលុបបំបាត់ផ្នត់គំនិតយេនឌ័រជុំវិញតួនាទី និងទំនួលខុសត្រូវរបស់ស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុស។ ធានាថាមតិយោបល់របស់អាជ្ញាធរព្រមទាំងច្បាប់ និងគោលនយោបាយមិនមានការរើសអើង និងមិនជំរុញឱ្យផ្នត់គំនិតយេនឌ័រនៅមានបន្តទៀត។

- អនុម័តច្បាប់គ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើងដែលធានាយន្តការផ្លូវច្បាប់ សម្រាប់ការអនុវត្តសិទ្ធិស្ត្រី និងគ្របដណ្តប់ការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅក្នុងវិស័យសាធារណៈ ឯកជន និងទម្រង់នៃការរើសអើងត្រួតគ្នាផ្សេងទៀត។

- បែងចែកធនធានមនុស្ស បច្ចេកទេស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ប្រកបដោយការប្តេជ្ញាក្នុងរយៈពេលវែង ដែលចេញពីថវិកាជាតិ សម្រាប់ការអនុវត្តផែនការសកម្មភាព សមធម៌យេនឌ័រ និងគោលនយោបាយ និងការប្តេជ្ញាចិត្តនានារបស់កម្ពុជា។

- បង្កើនភាពតំណាងរបស់ស្ត្រីក្នុងវិស័យនយោបាយ និងការតាក់តែងច្បាប់នៅថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំដើម្បីធានាឱ្យមានតំណាងស្មើភាពគ្នា តាមរយៈវិធានការពិសេសបណ្តោះអាសន្ន ដូចជាការកំណត់គោលដៅតាមរយៈសកម្មភាពវិជ្ជមាន ការប្រព្រឹត្តដោយអនុគ្រោះ ប្រព័ន្ធកូតា និង/ឬការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលពាក់ព័ន្ធទាំងអស់ ដើម្បីដាក់ចេញលក្ខខណ្ឌតម្រូវការផ្នែកច្បាប់ជាកាតព្វកិច្ច ដើម្បីជំនួសស្ត្រី និងបុរសនៅក្នុងបញ្ជីបេក្ខជនគណបក្សនយោបាយ ដោយស្ត្រីស្ថិតនៅលេខរៀងទី០១ សម្រាប់ ៥០% នៃបញ្ជីគណបក្សនីមួយៗ។

- បញ្ចប់គ្រប់ទម្រង់នៃការយាយី អំពើហិង្សា និងការបំភិតបំភ័យចំពោះអ្នកនយោបាយជាស្ត្រីដែលមានទស្សនៈជំទាស់ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អ្នកសារព័ត៌មាន សកម្មជនដីធ្លី ពលកម្ម និងបរិស្ថាន និងអ្នកការពារសិទ្ធិមនុស្សជាស្ត្រីដទៃទៀត។ ដោះលែងស្ត្រីអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនពីពន្ធនាគារ ទម្លាក់ចោលគ្រប់ការចោទប្រកាន់ទាំងអស់ប្រឆាំងពួកគេ និងអនុញ្ញាតឱ្យអាជ្ញាប័ណ្ណប្រព័ន្ធផ្សព្វផ្សាយ ដែលបានដកហូតដំណើរការឡើងវិញ។

- ពិនិត្យសើរើជាបន្ទាន់ និងគ្រប់ជ្រុងជ្រោយនូវក្របខ័ណ្ឌច្បាប់ ជាពិសេសច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដើម្បីកំណត់ និងដាក់ទោសទណ្ឌលើគ្រប់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារ និងហាមឃាត់ការប្រើប្រាសវិធីសាស្ត្រដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ដើម្បីឆ្លើយតបក្នុងករណីអំពើហិង្សាក្នុងគ្រួសារ។

- ពង្រឹងកម្មវិធីបង្ការអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងធានាឱ្យមានលទ្ធភាពគ្រប់ជ្រុងជ្រោយ ទទួលបានសេវាគាំទ្រ ដូចជាតុលាការដោយប្រសិទ្ធភាព ដីកាការពារ និងសេចក្តីសម្រេចរដ្ឋបាល អ្នកតំណាងផ្នែកច្បាប់ ជម្រកសុវត្ថិភាព ជំនួយហិរញ្ញវត្ថុ ការថែទាំសុខភាព ការផ្តល់ប្រឹក្សា និងសេវាផ្សេងៗទៀត។

- ផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការរបស់អង្គការ ILO ឆ្នាំ២០១៩ (លេខ១៩០) និងអនុម័តនិយមន័យផ្លូវច្បាប់ និងដំណោះស្រាយ/សំណងគ្រប់ជ្រុងជ្រោយ នូវគ្រប់ទម្រង់នៃការយាយី ។

- ធ្វើវិសោធនកម្មក្របខណ្ឌច្បាប់ ដើម្បីធ្វើឱ្យសមភាពអាពាហ៍ពិពាហ៍ស្របច្បាប់ និងធានាការទទួលស្គាល់យេនឌ័រស្របច្បាប់ ដោយអនុញ្ញាតឱ្យបុគ្គលម្នាក់អាចកែប្រែឈ្មោះ និងឯកសារសម្គាល់យេនឌ័ររបស់ពួកគេនៅក្នុងគ្រប់ឯកសារអត្តសញ្ញាណទាំងអស់។

- ធ្វើនិយ័តកម្មស្ថាប័នមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព ដោយបង្ការការទទួលយកប្លង់ដីជនជាតិដើមភាគតិចជាទ្រព្យបញ្ចាំ ធ្វើឱ្យល្អប្រសើរនូវការការពារប្រឆាំងនឹងការលក់ដីដោយបង្ខិតបង្ខំស្ត្រីដែលមានសំលេងភាគតិចក្នុងសង្គម រួមទាំងស្ត្រីជនជាតិដើមភាគតិច និងស្ត្រីដែលប្រើបណ្ណសមធម៌ និងជួយសម្រួលការបង្កើតយន្តការបណ្តឹងតវ៉ាឯករាជ្យ ដែលមិនមែនរដ្ឋ មិនមែនតុលាការ ស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស។

- មិនដាក់ទោសព្រហ្មទណ្ឌលើការងារប្រកបរបរផ្លូវភេទ និងនិរាករណ៍គ្រប់ច្បាប់គោលនយោបាយ និងសកម្មភាពដែលដាក់ទណ្ឌកម្ម និងរើសអើងទាំងអស់ ដែលផ្តោតលើស្ត្រីប្រកបរបរផ្លូវភេទ ហើយធានាថា ច្បាប់ជាតិបែងចែកឲ្យដាច់រវាងការងារប្រកបរបរផ្លូវភេទ និងការជួញដូរមនុស្ស។ ធានាថា បុគ្គលិកក្នុងវិស័យកំសាន្ត និងអ្នកប្រកបរបរផ្លូវភេទមានលទ្ធភាពទទួលបានការការពារសិទ្ធិការងារ និងសេវាថែទាំសុខភាពប្រកបដោយគុណភាព។

- ធានាលទ្ធភាពទទួលបានការអប់រំសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ CSE ដោយគ្រប់យុវជនទាំងអស់តាមរយៈធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការបណ្តុះបណ្តាល ការអនុវត្ត និងការត្រួតពិនិត្យស្របតាមការប្តេជ្ញារបស់រដ្ឋាភិបាលកម្ពុជា។

- ធានាឱ្យមានការប្រកាន់ខ្ជាប់វិធានអប្បបរមាតាមស្តង់ដាររបស់អង្គការសហប្រជាជាតិ សម្រាប់អ្នកជាប់ឃុំ (វិធានរបស់លោក Nelson Mandela) និងវិធានអង្គការសហប្រជាជាតិសម្រាប់ប្រព្រឹត្តកម្មលើជនជាប់ឃុំជាស្ត្រី និងវិធានការដាក់ឱ្យនៅក្រៅការឃុំខ្លួនសម្រាប់ជនល្មើសជាស្ត្រី (វិធានបាងកក)។ កាត់បន្ថយភាពចង្អៀតណែនដោយប្រើប្រាស់ជម្រើសជំនួសចំពោះការឃុំខ្លួន និងអនុវត្តការឃុំខ្លួនបណ្តោះអាសន្នជាវិធានការចុងក្រោយ។

# ការវិវឌ្ឍនៃការអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយ នៃអនុសញ្ញា ស៊ី-ដ ឆ្នាំ២០១៩ (CoBs)

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ៦ | SDGs | ទទួលស្គាល់ស្ត្រីជាកំលាំងចលករនៃការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព | | | | បានអនុវត្តរួចហើយ | |
| ៩ក | ក្របខណ្ឌច្បាប់ | និយមន័យខនៃការរើសអើងនៅក្នុងច្បាប់ | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ៩ខ | ក្របខណ្ឌច្បាប់ | ការសិក្សាវាយតម្លៃពីច្បាប់ដែលមានឥទ្ធពលលើយេនឌ័រជាលក្ខណៈប្រព័ន្ធ | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ១១ក | ការទទួលបានយុត្តិធម៌ | ជំនួយផ្នែកច្បាប់ដោយមានការផ្តល់ថវិកាជំនួយពីរដ្ឋក្នុងរយៈពេលវែង សាលាឧទ្ធរណ៍តាមតំបន់ | | | | អនុវត្តបានខ្លះ។ មានថវិកាសម្រាប់ផ្តល់ជំនួយផ្នែកច្បាប់មួយចំនួន ប៉ុន្តែមិនទាន់គ្រប់គ្រាន់ និងមានរយៈពេលយូរនោះទេ។ មានសាលឧទ្ធរណ៍តែ ៤ប៉ុណ្ណោះនៅទូទាំងប្រទេស ដោយពុំមានសាលាឧទ្ធរណ៍ថ្មីត្រូវបានបង្កើតឡើងទេ ចាប់ពីឆ្នាំ ២០២០។ | |
| ១១ខ | ការទទួលបានយុត្តិធម៌ | បញ្ចប់ការទទួលរងស្លាកស្នាមមិនល្អក្នុងការរាយការណ៍ពីការលោតបំពានសិទ្ធិ | | | | រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍បន្តអនុវត្តយុទ្ធនាការដើម្បីលើកទឹកចិត្តឱ្យរាយការណ៍ករណី GBV ប៉ុន្តែការស្តីបន្ទោសចំពោះជនរងគ្រោះនៅតែបន្តនៅគ្រប់កម្រិតនៃសង្គម និងស្ថាប័ន រួមទាំងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌។ មិនមានការគាំទ្រចំពោះការរាយការណ៍ប្រកបដោយសុវត្ថិភាពអំពីអំពើហឹង្សាដែលប្រព្រឹត្តិដោយរដ្ឋនោះទេ។ | |
| ១១គ | ការទទួលបានយុត្តិធម៌ | ផ្សព្វផ្សាយពត៍មានអំពីដំណោះស្រាយ | | | | ក្រសួងកិច្ចការនារី បានជួយធ្វើការផ្សព្វផ្សាយពត៌មានមួយចំនួនអំពីកម្រិតនៃសេវា ដែលរួមមានកម្មវិធីសុវត្ថិភាព GBV បង្កើតឡើងក្នុងឆ្នាំ២០២៤ ប៉ុន្តែមានការជួយតិចតួចក្នុងការទទួលបានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ | |
| ១១ឃ | ការទទួលបានយុត្តិធម៌ | ប្រព័ន្ធយុត្តិធម៌ដែលគិតគូរពីយេនឌ័រ មានស្ត្រីកាន់តែច្រើនទទួលបានវគ្គបណ្តុះបណ្តាលអំពីអនុសញ្ញាស៊ីដ | | | | ប្រព័ន្ធយុត្តិធម៌នៅមិនទាន់មានការឆ្លើយតបយេនឌ័រ ឬយល់ដឹងជ្រួតជ្រាបពីយេនឌ័រ។ អ្នកតំណាងក្នុងប្រព័ន្ធយុត្តិធម៌ ជាស្ត្រីនៅមានចំនួនតិច។ មានកម្មវិធីកសាងសមត្ថភាពខ្លះ ដែលបានផ្តល់ឲ្យបុគ្គលិកចៅក្រម និងមន្ត្រីអនុវត្តច្បាប់។ | |

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្ដីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ១១ង | ការទទួលបានយុត្តិធម៌ | ការស៊ើបអង្កេត និងការដាក់ទោសលើករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវមានលក្ខណៈមិនលំអៀង ឯករាជ្យ និងតាមផ្លូវតុលាការ | | | | ប្រព័ន្ធយុត្តិធម៌ នៅមានលក្ខណៈលំអៀង ឬមិនឯករាជ្យនៅឡើយ។ ករណីនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ មិនត្រូវបានធ្វើការស៊ើបអង្កេតជាប្រចាំឡើយ ហើយជារឿយៗនៅតែមាននិទ្ទណ្ឌភាព។ យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការទូទាត់សំណងក្រៅប្រព័ន្ធតុលាការ ជារឿយៗត្រូវបានយកទៅអនុវត្តខុស ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយគ្រប់ជ្រុងជ្រោយ។ | |
| ១១ច | ការទទួលបានយុត្តិធម៌ | ឱ្យមន្ត្រីដែលជាប់ពាក់ព័ន្ធនឹងអំពើពុករលួយទទួលខុសត្រូវលើទង្វើរបស់ខ្លួន | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ១៣ក | វិវាទ | ភាពត្រឹមត្រូវចំពោះជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងសម័យខ្មែរក្រហម | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ១៣ខ | វិវាទ | ផែនការសកម្មភាពស្ដីពី SCR 1325 | | | | មិនមានផែនការសកម្មភាពជាក់លាក់ត្រូវបានអនុម័តឡើយ។ | |
| ១៣គ | វិវាទ | ស្ត្រីត្រូវចូលរួមក្នុងការកសាងសន្តិភាពនៅគ្រប់ដំណាក់កាលទាំងអស់ | | | | ស្ត្រីមួយចំនួនបានចូលរួមក្នុងដំណាក់កាលខ្លះក្នុងការកសាងសន្តិភាព ប៉ុន្តែពួកគេមិនទទួលបានបានការបញ្ចូលអោយបានចូលរួមពេញលេញនៅគ្រប់ផ្នែកទាំងអស់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនោះទេ។ | |
| ១៥ក | យន្តការដឹកនាំថ្នាក់ជាតិ | ស្វ័យភាពសម្រាប់ CNCW | | | | ពុំទាន់មានការផ្លាស់ប្ដូរនៅឡើយ។ | |
| ១៥ខ | យន្តការដឹកនាំថ្នាក់ជាតិ | ថវិកាជាតិសម្រាប់ការអនុវត្តពេញលេញនូវគោលនយោបាយយេនឌ័រ | | | | ធនធាន និងមូលនិធិនៅមានកម្រិត មិនមានប្រសិទ្ធិភាព និងមិនមានការបែងចែកច្បាស់លាស់។ | |
| ១៥គ | យន្តការដឹកនាំថ្នាក់ជាតិ | ការចូលរួមរបស់អង្គការសង្គមស៊ីវិលនៅក្នុង ផែនការសកម្មភាពជាតិស្ដីពីសមភាពយេនឌ័រ(NPGE) | | | | ចាប់តាំងពីមានការពិគ្រោះយោបល់ចុងក្រោយជាមួយអង្គការសង្គមស៊ីវិលក្នុងឆ្នាំ ២០២១/២០២២ កន្លងមក មិនមានការធ្វើបច្ចុប្បន្នភាពអំពីវឌ្ឍនភាពនោះទេ ហើយឯកសារគោលនយោបាយក៏មិនមានការចែករំលែកផងដែរ។ | |

| ល.រ កថាខណ្ឌនៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ១៥ឃ | យន្តការដឹកនាំថ្នាក់ជាតិ | ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាពលើគោលនយោបាយនានា សកម្មភាពយេនឌ័រនៅថ្នាក់ក្រសួង | | | | គ្មានកម្មវិធីត្រួតពិនិត្យ និងវាយតម្លៃជាក់លាក់ត្រូវបានបង្កើតឡើងទេ។ ទោះយ៉ាងណាក៏ដោយមានសកម្មភាពមួយចំនួនបានធ្វើឡើង ក្នុងការត្រួតពិនិត្យ និងវាយតម្លៃ NAVAW III ។ | |
| ១៧ | ស្ថាប័នសិទ្ធិមនុស្ស | បង្កើតឱ្យមានស្ថាប័នសិទ្ធិមនុស្សស្របតាមគោលការណ៍ទីក្រុងប៉ារីសនីយួយៗ (per Paris Principles) | | | | រដ្ឋាភិបាលកំពុងស្នើឱ្យមាន ស្ថាប័នជាតិសិទ្ធមនុស្ស (NHRI) ក្នុងឆ្នាំកន្លងមក ប៉ុន្តែមិនមានយន្តការដើម្បីធ្វើឱ្យវាស្របតាមគោលការណ៍ទីក្រុងប៉ារីសឡើយ។ បរិយាកាសសិទ្ធិមនុស្ស និងនយោបាយនាពេលបច្ចុប្បន្ន អាចនឹងរារាំងស្ថាប័ននានាក្នុងការដំណើរការប្រកបដោយឯករាជ្យភាព និងប្រសិទ្ធិភាព។ | |
| ១៩ | សង្គមស៊ីវិល | ធានាឱ្យមានទូវសេរីភាពនៃការបញ្ចេញមតិ ការប្រមូលផ្តុំ និងការចូលរួមសមាគម | | | | កម្ពុជាបន្តរំលោភសិទ្ធិស្ត្រី អ្នកការពារសិទ្ធិមនុស្ស សហជីព សកម្មជនដីធ្លី និងបរិស្ថាន និងអ្នកនយោបាយប្រឆាំង។ | |
| ២១ក | វិធានការពិសេសបណ្តោះអាសន្ន | ការបែងចែកដីធ្លីឡើងវិញសម្រាប់ភាពជាម្ចាស់កម្មសិទ្ធិរបស់ស្ត្រីដោយស្មើភាពគ្នា | | | | មិនទាន់មានកិច្ចប្រឹងប្រែងនៅឡើយ។ ស្ត្រីនៅតែបន្តរងគ្រោះដោយ ការរំលោភដីធ្លី និងបណ្តេញចេញដោយបង្ខំ។ | |
| ២១ខ | វិធានការពិសេសបណ្តោះអាសន្ន | ការផ្តល់ទីសុវត្ថិភាពសម្រាប់ស្ត្រី | | | | ការរំលោភយកដីធ្លី ការបណ្តេញចេញដោយបង្ខំ និងការតាំងទីលំនៅថ្មីដែលមិនមានសេវាគ្រប់គ្រាន់ បានធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពទទួលបានសុវត្ថិភាព និងលំនៅដ្ឋានសមរម្យ។ | |
| ២១គ | វិធានការពិសេសបណ្តោះអាសន្ន | កែលម្អឱកាសសេដ្ឋកិច្ចដោយមានការកំណត់កូតា | | | | មិនទាន់មានវិធានការពិសេសបណ្តោះអាសន្ននៅឡើយ។ | |
| ២៣ក | ផ្នត់គំនិត | យុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីលុបបំបាត់ឥរិយាបថនៃការប្រកាន់ភាពជាបុរស | | | | មិនមានយុទ្ធសាស្ត្រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ។ មន្ត្រីជាន់ខ្ពស់ បន្តប្រកាន់ខ្ជាប់នូវឥរិយាបថរើសអើង និងអាកប្បកិរិយាបែបបិតាធិបតេយ្យ ចំពោះតួនាទីយេនឌ័រ។ | |

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្ដីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ២៣ខ | ផ្ដត់គំនិត | វិធីសាស្ត្រផ្សេងៗក្នុងការអប់រំយេនឌ័រដោយមិនមានច្បាប់ស្រី | | | | មិនមានកិច្ចប្រឹងប្រែងទេ។ ច្បាប់ស្រីនៅតែបន្តបង្រៀនតាមរូបភាពផ្សេងៗក្នុងសាលារៀន។ | |
| ២៣គ | ផ្ដត់គំនិត | ជំរុញឱ្យមានឥរិយាបថដែលមានលក្ខណៈវិជ្ជមានចំពោះសមភាពយេនឌ័រក្នុងចំណោមយុវវ័យ | | | | រដ្ឋាភិបាល បន្តអនុវត្តយុទ្ធនាការមួយចំនួនតាមបណ្ដាញផ្សព្វផ្សាយសង្គម និងទីសាធារណៈដើម្បីលើកម្ពស់សមភាពនៅក្នុងបរិបទមួយចំនួន។ | |
| ២៥ក | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការវាយតម្លៃពីផលប៉ះពាល់នៃវិធានការ និងដោះស្រាយឫសគល់នៃបញ្ហា | | | | វិធានការដោះស្រាយឫសគល់នៃបញ្ហាមិនត្រូវបានគេវាយតម្លៃជាប្រព័ន្ធទេ។ សកម្មភាពបង្ការដើម្បីដោះស្រាយឫសគល់នៃបញ្ហានៅមានកម្រិត។ ក្រសួងកិច្ចការនារី បានអនុវត្តសកម្មភាពយុទ្ធនាការមួយចំនួនដែលលើកកម្ពស់សមភាព។ | |
| ២៥ខ | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយនូវច្បាប់ស្ដីពីអំពើហិង្សាក្នុងគ្រួសារ ធ្វើវិសោធនកម្មដើម្បីដាក់ទោសទណ្ឌលើរាល់អំពើហិង្សាក្នុងគ្រួសារ សម្របសម្រួលឱ្យមានដីកាការពារ ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព | | | | ផែនទីតម្រង់ទិសឆ្ពោះទៅការធ្វើវិសោធនកម្មច្បាប់អំពើហិង្សាក្នុងគ្រួសារ បានបង្កើតឡើង ប៉ុន្តែមិនបានចេញផ្សាយជាសាធារណៈទេ។ មិនមានព័ត៌មានច្បាស់លាស់អំពីការធ្វើបច្ចុប្បន្នភាពច្បាប់នៅឡើយ។ | |
| ២៥គ | អំពើហិង្សាផ្អែកលើយេនឌ័រ | កែលម្អសេវាសំខាន់ៗនានា | | | | លទ្ធភាពទទួលបានសេវា ដែលមានគុណភាពនៅមានកម្រិត និងមិនគ្រប់គ្រាន់។ ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលបានដាក់ចេញនូវគោលការណ៍ណែនាំស្ដីពីការបង្កើតអង្គភាពសេវាច្រកចេញចូលតែមួយនៅឆ្នាំ២០២៤។ | |
| ២៥ឃ | អំពើហិង្សាផ្អែកលើយេនឌ័រ | ធ្វើការប្រមូលទិន្នន័យដោយប្រព័ន្ធគ្រប់គ្រងអំពីអំពើហិង្សាផ្អែកលើយេនឌ័រ | | | | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ ២០២១-២២ ស្ដីពីអំពើហិង្សាផ្អែកលើយេនឌ័រ នៅតែជាប្រភពចងក្រងទិន្នន័យតែមួយគត់។ | |
| ២៧ក | ការជួញដូរមនុស្ស | ធ្វើការដោះស្រាយបញ្ហាជាឫសគល់នៃកង្វះខាតនូវឱកាសសេដ្ឋកិច្ច | | | | មិនទាន់បានអនុវត្តនៅឡើយ | |

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្ដីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ២៧ខ | ការជួញដូរមនុស្ស | ធ្វើការកែលម្អការកំណត់អត្តសញ្ញាណ និងការណែនាំឱ្យទៅកស្ថាប័នដែលផ្តល់ជំនួយសម្រាប់ជនរងគ្រោះ | | | | កម្ពុជាបានបើកវគ្គបណ្តុះ តាមប្រព័ន្ធអនឡាញដល់មន្ត្រី ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរ ។ ប៉ុន្តែផលប៉ះពាល់របស់វានៅមានកម្រិត ដោយការខកខានក្នុងការឆ្លើយតបអោយបានហ្មត់ចត់ចំពោះការជួញដូរមនុស្ស ក្នុងទម្រង់នៃការឆបោកតាមប្រព័ន្ធអនឡាញ និងការកំណត់អត្តសញ្ញាណអ្នកដែលត្រូវបានជួញដូរឱ្យបានត្រឹមត្រូវថាជាជនរងគ្រោះ។ | |
| ២៧គ | ការជួញដូរមនុស្ស | ការដាក់បញ្ចូលជនរងគ្រោះឱ្យរួមរស់នៅក្នុងសង្គមឡើងវិញ | | | | ការការពារ ការផ្តល់សេវា និងការគាំទ្រនៅតែមានកម្រិត មិនគ្រប់គ្រាន់ និងមិនអាចទទួលបាន។ អ្នកដែលត្រូវបានជួញដូរមួយចំនួនអាចរងគ្រោះថ្នាក់បន្ថែមទៀត និងត្រូវឃុំខ្លួន ដោយសារពួកគេត្រូវបានចាត់ទុកថាជាជនអន្តោប្រវេសន៍ខុសច្បាប់។ | |
| ២៧ឃ | ការជួញដូរមនុស្ស | ការពារស្ត្រីពីការខាតបង់ការការពារសាក្សី | | | | អ្នកដែលត្រូវបានជួញដូរមួយចំនួនអាចរងគ្រោះថ្នាក់បន្ថែមទៀត និងត្រូវឃុំខ្លួនដោយសារពួកគេត្រូវបានចាត់ទុកថាជាជនអន្តោប្រវេសន៍ខុសច្បាប់។ | |
| ២៧ង | ការជួញដូរមនុស្ស | ការដាក់ទោសទណ្ឌលើអ្នកប្រព្រឹត្តអំពើជួញដូរមនុស្ស | | | | មិនមានការកាត់ទោសដែលគេដឹងថាមានពាក់ព័ន្ធនឹងការជួញដូរកំលាំងពលកម្មនោះទេ។ | |
| ២៧ច | ការជួញដូរមនុស្ស | កុំប្រើប្រាស់មិនត្រឹមត្រូវនូវច្បាប់ប្រឆាំងនឹងការជួញដូរមនុស្សលើអ្នកមិនមែនជាអ្នកប្រព្រឹត្តអំពើជួញដូរ | | | | ពុំទាន់បានអនុវត្តនៅឡើយ | |
| ២៩ក | អំពើពេស្យាចារ | ធ្វើការពិនិត្យឡើងវិញនូវច្បាប់ដើម្បីមិនធ្វើឱ្យការប្រកបរបរផ្លូវភេទត្រូវជាប់ទោសទណ្ឌ | | | | ពុំទាន់មានកិច្ចប្រឹងប្រែងនៅឡើយទេ។ | |
| ២៩ខ | អំពើពេស្យាចារ | ដាក់ទោសអ្នកកេងប្រវ័ញ្ចលើអំពើនេះ | | | | មានកិច្ចប្រឹងប្រែងខ្លះៗ។ | |
| ២៩គ | អំពើពេស្យាចារ | ដោះស្រាយបញ្ហាជាឫសគល់ដូចជាភាពក្រីក្រ តម្រូវការវិសមភាព | | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |

| ល.រ កថាខណ្ឌនៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ២៩ឃ | អំពើហិង្សា | ផ្តល់នីតិសម្បទា | | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣១ក | ជីវិតសាធារណៈ | អនុម័តវិធានការពិសេសបណ្តោះអាសន្ន ដូចជាការផ្តល់កូតា | | | | មិនទាន់មានវិធានការពិសេសបណ្តោះអាសន្ននៅឡើយ។ | |
| ៣១ខ | ជីវិតសាធារណៈ | បង្កើតបរិយាកាសដែលជួយដល់ស្ត្រី | | | | អ្នកចូលរួមត្រូវបានបង្ក្រាប។ ស្ត្រី និងក្រុមអ្នកងាយរងគ្រោះនៅតែមានតំណាងតិចតួចបន្ទាប់ពីការបោះឆ្នោតជាតិ ឆ្នាំ២០២៣ និងការបោះឆ្នោតព្រឹទ្ធសភា ឆ្នាំ២០២៤។ | |
| ៣៣ក | សញ្ជាតិ | ការទទួលបានសញ្ជាតិ ការអប់រំ ការងារ ការថែទាំសុខភាព ផ្តល់ជម្រកដល់ស្ត្រីដែលមានសញ្ជាតិជាជនជាតិវៀតណាម និងមានដើមកំណើតខ្មែរ | | | | ស្ត្រីជាច្រើនដែលមានដើមកំណើតជាជនជាតិវៀតណាម និងស្ត្រីខ្មែរក្រោមនៅតែមិនមានរដ្ឋ ហើយប្រឈមមុខនឹងឧបសគ្គក្នុងការទទួលបានការអប់រំ ការងារ ការថែទាំសុខភាព និងលំនៅដ្ឋាន។ | |
| ៣៣ខ | សញ្ជាតិ | សម្របសម្រួលដល់ការធ្វើឯកសារកំណត់អត្តសញ្ញាណ និងសំបុត្រកំណើត ដោយគ្មានការដកហូតឯកសារ | | | | នៅឆ្នាំ២០២៣ ប្រទេសកម្ពុជាបានអនុម័តច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (ច្បាប់ CRVSID) ដែលអាចធ្វើឱ្យប្រសើរឡើងនូវការចុះឈ្មោះជាសកល ប្រសិនបើការអនុវត្តប្រកបដោយប្រសិទ្ធភាព និងគ្មានការរើសអើង។ | |
| ៣៣គ | សញ្ជាតិ | ផ្តល់សច្ចាប័នលើអនុសញ្ញាចំនួន២ ស្តីពីភាពមិនមែនជាពលរដ្ឋនៃប្រទេសណាមួយ (Statelessness) | | | | ពុំទាន់បានអនុវត្តនៅឡើយ | |
| ៣៥ក | ការអប់រំ | បង្កើនការទទួលបានការអប់រំនៅកម្រិតអនុវិទ្យាល័យ លុបបំបាត់កត្តារារាំងសម្រាប់កុមារី | | | | មានកិច្ចប្រឹងប្រែងបន្តបន្ទាប់ | |
| ៣៥ខ | ការអប់រំ | ជំរុញលើកទឹកចិត្តដល់កុមារីឱ្យចូលក្នុងវិធីសាស្ត្រអប់រំ STEAM (មុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា) | | | | គោលនយោបាយ និងកម្មវិធីមួយចំនួនត្រូវបានអនុម័តដើម្បីលើកទឹកចិត្តក្មេងស្រីឱ្យសិក្សាមុខវិជ្ជា STEM ។ ទោះយ៉ាងណាក៏ដោយ ការចូលរួមនៅតែមានកម្រិត។ | |

| ល.រ កថាខណ្ឌនៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ៣៥គ | ការអប់រំ | ផ្តល់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយដល់គ្រូបង្រៀន | | | | ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥ បានដាក់បញ្ចូលអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ី- ដ និងការបណ្តុះបណ្តាលគ្រូនៅក្នុងបញ្ជីសកម្មភាព។ | |
| ៣៧ក | ការងារ | បុគ្គលិកកម្មករស្ថិតក្នុងកិច្ចសន្យាមានថេររយៈពេលកំណត់ ទទួលបានសេរីភាពបង្កើតសហជីព និងអត្ថប្រយោជន៍នៃការឈប់លំហែមាតុភាព restore AC 2-year cap on FDCs | | | | ពុំមានកិច្ចប្រឹងប្រែងនោះទេ។ កិច្ចសន្យាដែលមានរយៈពេលកំណត់នៅតែប្រើជាធម្មតា ដើម្បីកំណត់សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងការជួបជុំ ហើយច្បាប់ក្នុងការកំណត់ការប្រើប្រាស់កិច្ចសន្យាបែបនេះ មិនត្រូវបានអនុវត្តទេ។ | |
| ៣៧ខ | ការងារ | ការពារវិស័យក្រៅប្រព័ន្ធមានដូចជា អ្នកបម្រើការងារតាមផ្ទះនៅក្នុងច្បាប់ស្តីពីការងារ | | | | កម្មករក្នុងស្រុក និងក្រៅប្រព័ន្ធផ្សេងទៀតមិនត្រូវបានការពារច្បាស់លាស់នៅក្រោមច្បាប់ការងារទេ។ កម្ពុជាបានខិតខំប្រឹងប្រែងខ្លះដើម្បីពង្រីកបេឡាជាតិរបបសន្តិសុខសង្គមដល់កម្មករក្រៅប្រព័ន្ធតាមរយៈការបង់ប្រាក់ស្ម័គ្រចិត្តរបស់កម្មករ ប៉ុន្តែមិនច្បាស់ទេថាតើពួកគេអាចទទួលបាន និងការកែលម្អលទ្ធភាពទទួលបានសេវាដោយគ្មានការរើសអើងឬយ៉ាងណា។ | |
| ៣៧គ | ការងារ | ជំរុញលើកទឹកចិត្តឱ្យមានការចែករំលែកតួនាទីជាឪពុកម្តាយដោយមានការឈប់លំហែបិតុភាព | | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៧ឃ | ការងារ | ការតាក់តែងច្បាប់ដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយស្តីពីការបៀតបៀនផ្លូវភេទ ដោយមានដំណោះស្រាយ | | | | ពុំទាន់មានកិច្ចប្រឹងប្រែងថ្មីនៅឡើយ។ | |
| ៣៧ង | ការងារ | ធានាឱ្យមានប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នាយោងតាមអនុសញ្ញាលេខ ១០០ នៃអង្គការអន្តរជាតិខាងផ្នែកការងារ (ILO C100) | | | | ពុំមានកិច្ចខិតខំប្រឹងប្រែងដើម្បីប្រៀបធៀបប្រភេទការងារផ្សេងគ្នាជាមួយនឹងការងារដែលមានតម្លៃស្មើគ្នានោះទេ។ មិនមានការអនុវត្តស្របគ្នានៃច្បាប់ដែលមានស្រាប់ស្តីពីប្រាក់ឈ្នួលស្មើគ្នាសម្រាប់ការងារដូចគ្នានោះដែរ។ | |
| ៣៧ច | ការងារ | ការពារកម្មករចំណាកស្រុកទៅក្រៅប្រទេស | | | | ការបណ្តុះបណ្តាលខ្លះត្រូវបានអនុវត្ត ប៉ុន្តែពលករចំណាកស្រុកនៅក្រៅប្រទេសនៅតែទទួលបានការការពារ និងការគាំទ្រមានកម្រិត។ | |

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ៣៧ឆ | ការងារ | ផ្តល់សច្ចាប័នលើអនុសញ្ញានៃអង្គការអន្តរជាតិខាងផ្នែកការងារ លេខ១៨៣ លេខ១៨៩ លេខ១៩០ | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ៣៩ក | សុខភាព | ការទទួលបានជាសកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ | | | | ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា២០២៤-២០៣៥ សង្កត់ធ្ងន់លើការដាក់បញ្ចូលសិទ្ធិផ្លូវភេទ សុខភាពបន្តពូជ (SRHR) នៅក្នុងកញ្ចប់សេវាសុខភាពសំខាន់ៗ។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តត្រូវតែត្រួតពិនិត្យយ៉ាងដិតដល់ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពងាយស្រួលសម្រាប់ទាំងអស់គ្នា។ បច្ចុប្បន្ននេះ SRHR គ្រប់ជ្រុងជ្រោយ មិនទាន់ពេញមនុស្សគ្រប់គ្នានៅឡើយ ។ | |
| ៣៩ខ | សុខភាព | ការប្រយុទ្ធប្រឆាំងនឹងការទទួលរងស្លាកស្នាមមិនល្អនៃការយកកូនចេញ និងការប្រើប្រាស់វិធីពន្យារកំណើត | | | | ការយល់ដឹងអំពីភាពស្របច្បាប់នៃការរំលូតកូន និងការប្រើប្រាស់វិធីពន្យារកំណើតកំពុងកើនឡើង។ ទោះជាយ៉ាងណាក៏ដោយ ទំនុកចិត្តក្នុងការប្រើសេវាកម្មទាំងនេះនៅមានកម្រិតនៅឡើយ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីបង្កើនការទទួលបានការអប់រំពីសុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ (CSE) នៅក្នុងសាលារៀន ប៉ុន្តែការរីកចម្រើនសំខាន់ៗនៅតែមានភាពចាំបាច់។ | |
| ៣៩គ | សុខភាព | ដោះស្រាយតម្រូវការអាហាររូបត្ថម្ភរបស់ស្ត្រី នៅក្នុងយុទ្ធសាស្ត្រនានា | | | | ពុំមានការផ្លាស់ប្តូរឡើយ។ | |
| ៣៩ឃ | សុខភាព | ការទប់ស្កាត់មហារីកស្បូន | | | | ចាប់តាំងពីខែតុលា ឆ្នាំ២០២៣ វ៉ាក់សាំងការពារជំងឺមហារីកមាត់ស្បូន (HPV) ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃដល់ក្មេងស្រីអាយុប្រាំបួនឆ្នាំទូទាំងប្រទេស។ ការព្រួយបារម្ភនៅតែមាន ចំពោះកង្វះព័ត៌មានទាក់ទងនឹងកម្មវិធី និងផលប៉ះពាល់ដែលអាចកើតមាន ប្រសិនបើដៃគូអភិវឌ្ឍន៍ដកការគាំទ្រមូលនិធិ។ | |

| ល.រ កថាខណ្ឌ នៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ៤១ | ស្ត្រីជនបទ | ធ្វើនិយតកម្មលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងកែលម្អការទទួលបានប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប  ជួយគាំទ្រដល់អាជីពខ្នាតធំដែលមានស្ត្រីជាម្ចាស់ | | | | វិស័យមីក្រូហិរញ្ញវត្ថុមិនត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទេ ដោយមានការអនុវត្តក្នុងរូបភាពកេងប្រវ័ញ្ចជាបន្តបន្ទាប់។ រដ្ឋាភិបាលកម្ពុជា និងអ្នកវិនិយោគអន្តរជាតិ មិនបានផ្តល់ការអនុគ្រោះ ឬដំណោះស្រាយដ៏មានអត្ថន័យណាមួយដល់អ្នកខ្ចីដែលរងផលប៉ះពាល់នោះទេ។ | |
| ៤៣ក | ការប្រែប្រួលអាកាសធាតុ | បញ្ចូលស្ត្រីក្នុងការបង្កើតគោលនយោបាយ | | | | ការបញ្ចូល ស្ត្រីអោយមានសំឡេងក្នុងការបង្កើតគោលនយោបាយនៅមានកម្រិត មិនមានការវិភាគយេនឌ័រឲ្យទូលំទូលាយ។ ក្មេងស្រីមិនត្រូវដាក់បញ្ចូលក្នុងដំណើរការបង្កើតគោលនយោបាយ។ | |
| ៤៣ខ | ការប្រែប្រួលអាកាសធាតុ | បញ្ចូលទស្សនៈវិស័យយេនឌ័រដែលមានលក្ខណៈច្បាស់លាស់ទៅក្នុងគោលនយោបាយ | | | | មានកិច្ចប្រឹងប្រែងលើគោលនយោបាយជាបន្តបន្ទាប់។ | |
| ៤៥ក | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ប្រើវិធីសាស្ត្រផ្សេងទៀតជំនួសដោយការឃុំខ្លួន | | | | ពុំមានការវិវឌ្ឍឡើយ។ ចំនួនអ្នកទោសបន្តកើនឡើង ជម្រើសជំនួសចំពោះការឃុំឃាំងមិនត្រូវបានពិចារណា ឬអនុវត្តឱ្យបានគ្រប់គ្រាន់ទេ។ | |
| ៤៥ខ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | ដោះស្រាយបញ្ហាជាឫសគល និងផលប៉ះពាល់លើកុមារពីការកាត់ឱ្យជាប់ពន្ធនាគារ | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ៤៥ឃ | ស្ត្រីស្ថិតក្នុងការឃុំខ្លួន | កាត់បន្ថយចំនួនមនុស្សលើសចំណុះ សេវា តាមវិធានទីក្រុងបាំងកក និងវិធានណេលសាន់ម៉ានដេឡា (per Bangkok rules and Nelson Mandela rules) | | | | ពុំមានការវិវឌ្ឍឡើយ។ ចំនួនអ្នកជាប់ឃុំក្នុងពន្ធនាគារលើសពីអត្រាផ្លូវការដែលគួរផ្ទុក ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងការទទួលបានសេវាសំខាន់ៗ។ | |
| ៤៧ក | ស្ត្រីពរពោះជំនួស | លុបចោលសេចក្តីសម្រេចក្នុងខែធ្នូ ឆ្នាំ២០១៦ ដើម្បីអនុញ្ញាតឱ្យស្ត្រីពរពោះជំនួសមានសិទ្ធិចិញ្ចឹមក្មេងក្នុងនាមជាកូនបង្កើតរបស់ខ្លួន | | | | មិនមានគម្រោងធ្វើឲ្យប្រសើរទេ។ កម្ពុជាបានបន្តឃុំខ្លួន និងកាត់ទោសស្ត្រីជាអ្នកពពោះជំនួសក្នុងឆ្នាំ២០២៤។ | |

| ល.រ កថាខណ្ឌនៃ CoBs | ប្រធានបទ | សេចក្តីសង្ខេប | ២០២០ កម្រិត | ២០២១ កម្រិត | ២០២២ កម្រិត | ការវិវឌ្ឍឆ្នាំ ២០២៣/២០២៤ | ២០២៤ កម្រិត |
|---|---|---|---|---|---|---|---|
| ៤៧ខ | ស្ត្រីពរពោះជំនួស | ដោះស្រាយបញ្ហាជាឫសគល់ដោយកែលម្អឱកាសនៃការរកប្រាក់ចំណូល | | | | ពុំមានសកម្មភាពឡើយ | |
| ៤៧គ | ស្ត្រីពរពោះជំនួស | | | | | មិនទាន់បានអនុវត្តនៅឡើយ | |
| ៤៧ឃ | ស្ត្រីពរពោះជំនួស | ច្បាប់មិនគួរដាក់ទោសទណ្ឌលើស្ត្រីពរពោះជំនួស | | | | ច្បាប់នៅមិនទាន់ត្រូវបានបញ្ចប់។ កម្ពុជាបន្តកាត់ទោសស្ត្រីពពោះជំនួសក្នុងឆ្នាំ២០២៤។ | |
| ៤៩ក | អាពាហ៍ពិពាហ៍ | វិធានការនានា ផ្តោតលើការបន្ថយអត្រានៃការរៀបអាពាហ៍ពិពាហ៍កុមារ | | | | ដៃគូអភិវឌ្ឍន៍ និងអង្គការក្នុងស្រុក សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី បានធ្វើយុទ្ធនាការអប់រំ និងកម្មវិធីការពារមួយចំនួននៅក្នុងខេត្តរតនគិរី និងស្ទឹងត្រែង ដើម្បីទប់ស្កាត់ការរៀបការរបស់កុមារ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនៅតែមានកម្រិត។ អាពាហ៍ពិពាហ៍កុមារនៅតែបន្ត។ | |
| ៤៩ខ | អាពាហ៍ពិពាហ៍ | លុបចោលមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី | | | | ពុំមានកិច្ចប្រឹងប្រែងដើម្បីលុបចោលទេ។ | |

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (NGO-CEDAW) ជាសម្ព័ន្ធអង្គការឈានមុខគេ ដែលធ្វើការតាមដាន និងលើកកម្ពស់ឱ្យមានការអនុវត្តអនុញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ (ស៊ី-ដ)។ អង្គការនេះបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ដោយសកម្មជនស្រ្តីកម្ពុជាមួយក្រុម នៅក្រោយការវិលត្រឡប់មកវិញរបស់ពួកគាត់ ពីការចូលរួមសន្និសីទពិភពលោកស្តីពីស្រ្តីនៅទីក្រុងប៉េកាំង។ NGO-CEDAW បានពង្រីកសមាជិកភាពរបស់ខ្លួនពី៩អង្គការ ដែលជាអ្នកបង្កើត NGO-CEDAW នេះឡើង រហូតមកដល់ ៣២អង្គការក្នុងស្រុកជាសមាជិក។ NGO-CEDAW ធ្វើការជាមួយបណ្តាញដៃគូជាង ៣០បន្ថែមទៀត ដើម្បីផ្តល់សម្លេងគាំទ្រដល់ក្រុមស្រ្តី និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTIQ+) ដែលងាយរងគ្រោះ ។

ការងាររបស់ NGO-CEDAW រួមមាន៖
ការស្រាវជ្រាវ ការស្វែងរកមតិគាំទ្រ ការលើកកម្ពស់ការយល់ដឹង កសាងសមត្ថភាព និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិករបស់ខ្លួន។ សកម្មភាពសំខាន់ៗរបស់ NGO-CEDAW រួមមានការកសាងសមត្ថភាព ការរៀបចំវេទិកាជជែកដេញដោលថ្នាក់សាកលវិទ្យាល័យប្រចាំឆ្នាំ កម្មវិធីតាំងពិព័រណ៍ការបង្កើតស្នាដៃសិល្បៈ ការតស៊ូមតិដោយផ្ទាល់នៅអង្គការសហប្រជាជាតិ ផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គការជាសមាជិក និងក្រុមគោលដៅជាយុវជន។


**អាសយដ្ឋាន ការិយាល័យ NGO-CEDAW:**
**ផ្ទះលេខ ១៦ ផ្លូវ ៩៩ សង្កាត់ បឹងត្របែក**
**ខណ្ឌចំការមន រាជធានីភ្នំពេញ**

www.ngocedaw.org

ngocedaw.pnh@gmail.com

@TheCambodianNgoCommitteeOnCedaw


NGO-CEDAW